Forte
Life Assurance

# ដំណើរដោយភាពក្លាហាន មោះមុត និងពិសេសប្លែកពីគេ

2025

ក្រុមហ៊ុន ហ្វតតេ ឡាយហ្វ៍ អ៊ីស្យូរ៉ិនស៍ (ខេមបូឌា) ម.ក

## របាយការណ៍ប្រចាំឆ្នាំ

ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025

# មាតិកា


## 1-6 | ទិដ្ឋភាពទូទៅ និងភាពជាអ្នកដឹកនាំ

1 ទិដ្ឋភាពទូទៅនៃក្រុមហ៊ុន
2 សារពីប្រធានក្រុមប្រឹក្សាភិបាល
3 សារពីអគ្គនាយកក្រុមហ៊ុន
5 សូចនាករហិរញ្ញវត្ថុសំខាន់ៗ
6 អំពីក្រុមហ៊ុន

## 8-18 | វត្តមានក្នុងទីផ្សារ និងប្រតិបត្តិការអាជីវកម្ម

8 ពានរង្វាន់ និងសមិទ្ធផលសំខាន់ៗ
9 ផលិតផល និងសេវាកម្មធានារ៉ាប់រង
10 ភាពជាដៃគូ និងបណ្តាញចែកចាយអាជីវកម្ម
11 អតិថិជន
12 បណ្តាញសាខា
13 ក្រមសីលធម៌ និងវិន័យការងារ
14 ទំនួលខុសត្រូវសង្គម
18 ក្របខ័ណ្ឌ និងការប្តេជ្ញាចិត្តលើកិច្ចការ បរិស្ថាន សង្គម និង អភិបាលកិច្ច (ESG)

## 20-32 | របាយការណ៍អភិបាលកិច្ច និងគណៈកម្មាធិការ

20 រចនាសម្ព័ន្ធក្រុមហ៊ុន
26 ប្រវត្តិរូបសង្ខេបថ្នាក់ដឹកនាំ
30 របាយការណ៍គណៈកម្មាធិការសវនកម្ម
31 របាយការណ៍គណៈកម្មាធិការវិនិយោគ
32 អភិបាលកិច្ចសាជីវកម្ម

## 33-40 | ព័ត៌មានហិរញ្ញវត្ថុ និងការគ្រប់គ្រងហានិភ័យ

33 ដើមទុន និងសាធនភាព
34 ព័ត៌មានអំពីការវិនិយោគ
35 ប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង
37 លទ្ធផលអំពីប្រតិបត្តិការអាជីវកម្ម
39 ការធានារ៉ាប់រងបន្ត
40 ការគ្រប់គ្រងហានិភ័យ
41 របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច

# ទិដ្ឋភាពទូទៅនៃក្រុមហ៊ុន ហ្វូតតេ ឡាយហ្វ៍ អ៊ីស្ហួរ៉ិនស៍

ក្នុងនាមជាផ្នែកមួយនៃក្រុមហ៊ុន ហ្វូតតេ ដែលជានិមិត្តរូបគំរូនៃវិស័យធានារ៉ាប់រងនៅកម្ពុជា ហ្វូតតេ ឡាយហ្វ៍ បានសម្រេចនូវរបត់ដ៏សំខាន់មួយក្នុងឆ្នាំ 2025 តាមរយៈការទទួលបានប្រាក់ចំណេញប្រចាំឆ្នាំជាលើកដំបូងបង្អស់ចាប់តាំងពីការបង្កើតក្រុមហ៊ុនមក។

ដំណើរការរបស់ ហ្វូតតេ ក្នុងការផ្តល់នូវការការពារអាយុជីវិត បានចាប់ផ្តើមដំបូងជាមួយការធានារ៉ាប់រងខ្នាតតូច ក្នុងឆ្នាំ 2016 និងបានពង្រីកវិសាលភាពទៅជាធានារ៉ាប់រងអាយុជីវិតពេញលេញនៅក្នុងឆ្នាំ 2019។ ដោយផ្អែកលើកេរដំណែលធានារ៉ាប់រងដ៏យូរអង្វែងបំផុតមួយនៅកម្ពុជា ហ្វូតតេ ជឿជាក់ថា ធានារ៉ាប់រងអាយុជីវិតដែលមានតម្លៃសមរម្យ និងងាយស្រួលទទួលបាន គឺពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយដល់ក្រុមគ្រួសារ ការពារទ្រព្យសម្បត្តិ ប្រាក់សន្សំ ជីវភាពរស់នៅ និងអនាគតរបស់អតិថិជន និងរួមចំណែកគាំទ្រដល់ស្ថិរភាពហិរញ្ញវត្ថុរយៈពេលវែង កំណើនទ្រព្យសម្បត្តិ និងកិច្ចអភិវឌ្ឍន៍របស់សង្គមជាតិផងដែរ។

ស្របពេលដែលកម្ពុជាបាននិងកំពុងបន្តមានវឌ្ឍនភាពទៅមុខ ដំណើរនៃការផ្តល់ការការពារនេះ គឺមានតម្លៃលើសពីសេវាកម្មហិរញ្ញវត្ថុទៅទៀត ពោលគឺវាជាការប្តេជ្ញាចិត្តដ៏មុតមាំក្នុងការជួយដល់ក្រុមគ្រួសារកម្ពុជាក្នុងការកសាងទំនុកចិត្ត រក្សានូវរាល់អ្វីៗដែលអតិថិជនបានខិតខំបង្កើតឡើង និងរៀបចំផែនការហិរញ្ញវត្ថុដ៏រឹងមាំសម្រាប់អនាគត។

## សមិទ្ធផលសំខាន់ៗប្រចាំឆ្នាំ 2025

អតិថិជនដែលទទួលបានការការពារ **~700,000+**

ចំណែកទីផ្សារផ្អែកលើអតិថិជនដែលទទួលបានការការពារ **~50%**

បុព្វលាភធានារ៉ាប់រងដុល **5.3 លានដុល្លារអាមេរិក**

ប្រាក់ចំណេញដំបូងបំផុត **125,491 ដុល្លារអាមេរិក**

កម្រិតសាធនភាព **192%**

លទ្ធផលអំពីប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុនក្នុងឆ្នាំ 2025 នេះ បានកើតចេញពីកំណើននៃផលិតផលដែលផ្តោតលើការការពារសុទ្ធ បណ្តាញចែកចាយអាជីវកម្មដ៏រឹងមាំតាមរយៈបណ្តាដៃគូ ប្រតិបត្តិការអាជីវកម្មកាន់តែល្អប្រសើរ និងមានវិន័យអគ្រាសំណងធានារ៉ាប់រងប្រកបដោយភាពវិជ្ជមាន និងកម្រិតសាធនភាពដ៏រឹងមាំ។




**លោក Charles Cheo**
ប្រធានក្រុមប្រឹក្សាភិបាល
ក្រុមហ៊ុន ហ្វតតេ ឡាយហ្វ៍

# សារពីប្រធានក្រុមប្រឹក្សាភិបាល

"ហ្វតតេ មានមោទនភាពក្រៃលែងក្នុងនាមជាសម្ព័ន្ធក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេមួយដែលត្រូវបានបង្កើតឡើងនៅកម្ពុជា ផ្អែកលើការប្តេជ្ញាចិត្តដ៏យូរអង្វែងក្នុងការផ្តល់កិច្ចការពារដល់ក្រុមគ្រួសារ អាជីវកម្ម និងសហគមន៍នៅទូទាំងប្រទេសកម្ពុជា។ ហ្វតតេ បានចូលរួមផ្តល់ការការពារដល់អតិថិជនជាងមួយលាននាក់នៅទូទាំងប្រទេស ដែលក្នុងនោះរួមមានអតិថិជនប្រមាណ **700,000 នាក់**ទទួលបានការការពារអាយុជីវិតពី ហ្វតតេ ឡាយហ្វ៍។"

យើងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញ និងពង្រឹងភាពធន់ផ្នែកហិរញ្ញវត្ថុនៅកម្ពុជា គាំទ្រដល់ដំណើរនៃកំណើនសេដ្ឋកិច្ចជាតិ ព្រមទាំងពង្រីកលទ្ធភាពទទួលបានកិច្ចការពារពីសេវាធានារ៉ាប់រងដ៏មានគុណតម្លៃ។

វឌ្ឍនភាពទាំងនេះបានឆ្លុះបញ្ចាំងពីភាពរឹងមាំនៃប្រព័ន្ធការងាររួមបញ្ចូលគ្នារបស់ ហ្វតតេ គ្រុប ទំនុកចិត្តពីសំណាក់អតិថិជន ការគាំទ្រពីដៃគូអាជីវកម្ម ព្រមទាំងការប្តេជ្ញាចិត្ត និងលក្ខណៈវិជ្ជាជីវៈខ្ពស់របស់បុគ្គលិកយើង។ តាមរយៈការរួមបញ្ចូលគ្នានូវសមត្ថភាពនៃអាជីវកម្មធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងអាយុជីវិតរបស់ ហ្វតតេ យើងមានលទ្ធភាពយ៉ាងពេញលេញក្នុងការឆ្លើយតបទៅនឹងតម្រូវការផ្នែកកិច្ចការពារដែលកំពុងតែមានបម្រែបម្រួល និងអភិវឌ្ឍជាលំដាប់នៅកម្ពុជា ព្រមទាំងផ្តល់នូវតម្លៃស្ថិលជូនដល់អតិថិជន ដៃគូអាជីវកម្ម និងសហគមន៍ទាំងមូល។

ទិសដៅទៅអនាគត យើងនឹងបន្តធ្វើជាដៃគូអភិវឌ្ឍអាជីវកម្មដ៏គួរឱ្យទុកចិត្តនៅកម្ពុជា តាមរយៈការវិនិយោគលើការធ្វើបរិវត្តកម្មឌីជីថល ការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ការការពារក្រុមគ្រួសារ និងអាជីវកម្មនានាពីហានិភ័យផ្នែកហិរញ្ញវត្ថុ ការគាំទ្រដល់ការសន្សំរយៈពេលវែងនិងការកសាងភាពធន់ ការរួមចំណែកដល់គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ព្រមទាំងការឆ្លើយតបទៅនឹងតម្រូវការផ្នែកកិច្ចការពារដែលកំពុងតែរីកចម្រើនយ៉ាងឆាប់រហ័សរបស់ប្រជាជនកម្ពុជាដែលមានជីវភាពមធ្យម។

ក្នុងនាមក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអតិថិជនសម្រាប់ទំនុកចិត្តជាបន្តបន្ទាប់ ដៃគូអាជីវកម្មសម្រាប់កិច្ចសហប្រតិបត្តិការដ៏ល្អ បុគ្គលិកទាំងអស់សម្រាប់ការប្តេជ្ញាចិត្តខ្ពស់ និងភាគហ៊ុនិកសម្រាប់ការគាំទ្រឥតងាករេ។ យើងនឹងរួមគ្នាបន្តកសាងវិស័យធានារ៉ាប់រងនៅកម្ពុជាឱ្យកាន់តែរឹងមាំ មានលក្ខណៈបរិយាប័ន្ន និងមានភាពធន់ខ្ពស់ជាងមុនសម្រាប់ថ្ងៃអនាគត។

**ដោយសេចក្តីគោរពរាប់អានដ៏ជ្រាលជ្រៅ**

**លោក Charles Cheo**
ប្រធានក្រុមប្រឹក្សាភិបាល



**លោក ព្រូ ស៊ីថន**
អគ្គនាយកក្រុមហ៊ុន
ក្រុមហ៊ុន ហ្វតតេ ឡាយហ្វ៍

# សារពីអគ្គនាយកក្រុមហ៊ុន

"ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វតតេ ឡាយហ្វ៍ កំពុងឈានចូលជំពូកថ្មីមួយប្រកបដោយទំនុកចិត្ត ភាពធន់ និងទិសដៅដ៏ច្បាស់លាស់ឆ្ពោះទៅរកកំណើនប្រកបដោយចីរភាព។ នៅក្នុងឆ្នាំ 2025 ក្រុមហ៊ុនសម្រេចបាននូវរបត់ប្រវត្តិសាស្ត្រដ៏សំខាន់មួយ តាមរយៈលទ្ធផលប្រាក់ចំណេញប្រចាំឆ្នាំជាលើកដំបូងបង្អស់ចាប់តាំងពីការបង្កើតក្រុមហ៊ុនមក ព្រមទាំងបានពង្រីកវិសាលភាពនៃការការពារដល់ក្រុមគ្រួសារកម្ពុជា និយោជិត អតិថិជន ខ្ចីប្រាក់ ម្ចាស់ប្រាក់បញ្ញើ សហគ្រាសធុនតូច និងមធ្យម និងសហគមន៍នានា។"

សមិទ្ធផលនេះឆ្លុះបញ្ចាំងពីភាពរឹងមាំនៃយុទ្ធសាស្ត្ររបស់យើង ទំនុកចិត្តរបស់អតិថិជន និងដៃគូអាជីវកម្ម កិច្ចសហការគ្នាយ៉ាងជិតស្និទ្ធ និងការងារប្រកបដោយវិជ្ជាជីវៈខ្ពស់របស់បុគ្គលិករបស់យើង។ ចាប់តាំងពីឆ្នាំ 2023 មក ក្នុងទិសដៅបន្តកសាងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតមួយឱ្យមានប្រសិទ្ធភាព និងមូលដ្ឋានរឹងមាំសម្រាប់និរន្តរភាពទៅថ្ងៃខាងមុខ យើងបានពង្រឹងគ្រឹះស្ថាប័នឱ្យកាន់តែរឹងមាំ តាមរយៈការពង្រីកនិងបង្កើនប្រសិទ្ធភាពនៃបណ្ដាញចែកចាយ ការតម្រង់ទិសផលប័ត្រអាជីវកម្មឡើងវិញ វិន័យនៃការគ្រប់គ្រងចំណាយ ការធ្វើឱ្យប្រសើរឡើងនៃប្រព័ន្ធអភិបាលកិច្ច និងការលើកកម្ពស់ភាពធន់នៃប្រតិបត្តិការ។

ក្រៅពីការសម្រេចបាននូវប្រាក់ចំណេញក្នុងឆ្នាំ 2025 ក៏បាននាំមកនូវកំណើនក្នុងកម្រិតពីរខ្ទង់ធៀបនឹងឆ្នាំមុនផងដែរ លើបុព្វលាភធានារ៉ាប់រងដុល និងចំនួនអតិថិជនដែលទទួលបានការការពារដោយមានការគាំទ្រពីដៃគូអាជីវកម្មថ្មីៗ ព្រមទាំងកាលានុវត្តភាព។ លទ្ធផលទាំងនេះបានជួយឱ្យ ហ្វតតេ ឡាយហ្វ៍ ត្រៀមលក្ខណៈរួចជាស្រេចសម្រាប់កំណើនយូរអង្វែងប្រកបដោយទំនួលខុសត្រូវ និងឆ្លុះបញ្ចាំងពីវឌ្ឍនភាពជាបន្តបន្ទាប់របស់យើងក្នុងនាមជាក្រុមហ៊ុនដ៏រឹងមាំ និងមាននវានុវត្តន៍កាន់តែប្រសើរ។

គោលបំណងរបស់យើងគឺនៅតែផ្តោតសំខាន់លើតម្លៃមនុស្សជាតិ។ បណ្ណសន្យារ៉ាប់រងនីមួយៗគឺមានតម្លៃលើសពីការការពារផ្នែកហិរញ្ញវត្ថុ ពោលគឺវាតំណាងឱ្យការធានា ក្តីសង្ឃឹម សេចក្តីថ្លៃថ្នូរ និងទំនុកចិត្តសម្រាប់ក្រុមគ្រួសារកម្ពុជា ក្នុងការរៀបចំផែនការសម្រាប់អនាគត។ យើងខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះអតិថិជន ដៃគូអាជីវកម្ម និងបុគ្គលិកទាំងអស់ សម្រាប់ទំនុកចិត្ត កិច្ចសហការ និងការប្តេជ្ញាចិត្តពេញមួយឆ្នាំកន្លងមកនេះ។

ស្របពេលដែលប្រទេសកម្ពុជាបន្តការអភិវឌ្ឍ ហ្វតតេ ឡាយហ្វ៍ នៅតែបន្តប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការពង្រីកសេវាការការពារផ្នែកធានារ៉ាប់រង និងរួមចំណែកដល់សុវត្ថិភាពហិរញ្ញវត្ថុរយៈពេលវែង នាពេលអនាគត យើងនឹងបន្តកសាងក្រុមហ៊ុន ហ្វតតេ ឡាយហ្វ៍ ឱ្យក្លាយជាម៉ាកសញ្ញាធានារ៉ាប់រងដ៏ល្បីល្បាញដែលគ្រប់ក្រុមគ្រួសារទទួលស្គាល់ និងជានិមិត្តរូបគំរូថ្នាក់ជាតិនៃទំនុកចិត្ត ការការពារ និងវឌ្ឍនភាព តាមរយៈការបម្រើអតិថិជនដោយយកចិត្តទុកដាក់ ការគាំទ្រដៃគូអាជីវកម្មតាមរយៈការផ្តល់តម្លៃបន្ថែម ការផ្តល់អំណាចដល់បុគ្គលិករបស់យើងប្រកបដោយគោលបំណងច្បាស់លាស់និងការជួយដល់ក្រុមគ្រួសារកម្ពុជាក្នុងការការពារអនាគតប្រកបដោយទំនុកចិត្ត។

**ដោយសេចក្តីគោរពរាប់អានដ៏ជ្រាលជ្រៅ**

**លោក ព្រួ ស៊ីថន**
អគ្គនាយកក្រុមហ៊ុន

# សូចនាករហិរញ្ញវត្ថុសំខាន់ៗ

លទ្ធផលស្ថានភាពហិរញ្ញវត្ថុប្រចាំឆ្នាំ 2025 បានឆ្លុះបញ្ចាំងពីប្រព័ន្ធប្រតិបត្តិការដ៏រឹងមាំ និងប្រកបដោយវិន័យប្រសើរជាងមុន តាមរយៈការគាំទ្រពីការវាយតម្លៃហានិភ័យធានារ៉ាប់រង ការពង្រីកមូលដ្ឋានអតិថិជនឱ្យកាន់តែទូលំទូលាយ ផលប័ត្រអាជីវកម្មដែលមានលក្ខណៈចម្រុះជាងមុន ការគ្រប់គ្រងហានិភ័យរក្សាទុកប្រកបដោយប្រសិទ្ធភាព ការគ្រប់គ្រងចំណាយបានយ៉ាងត្រឹមត្រូវ ព្រមទាំងការបន្តវិនិយោគលើសមត្ថភាពនៃបណ្តាញចែកចាយអាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល។

| សូចនាករគន្លឹះនៃលទ្ធផលការងារ | ឆ្នាំ 2023 (ដុល្លារអាមេរិក) | ឆ្នាំ 2024 (ដុល្លារអាមេរិក) | ឆ្នាំ 2025 (ដុល្លារអាមេរិក) |
|---|---|---|---|
| បុព្វលាភដុល | 5,413,938 | 4,725,240 | 5,313,510 |
| បុព្វលាភសុទ្ធ | 4,025,049 | 3,692,622 | 5,010,740 |
| សំណងសុទ្ធ | 1,711,882 | 1,531,732 | 2,278,888 |
| ចំណូលពីការវិនិយោគ និងចំណូលផ្សេងៗ | 494,266 | 541,573 | 441,470 |
| ផលចំណេញ/(ខាត) មុនពន្ធលើប្រាក់ចំណូល | (1,182,850) | 1,225 | 183,613 |
| ផលចំណេញ/(ខាត) សុទ្ធប្រចាំឆ្នាំ | (1,241,839) | (50,926) | 125,491 |
| ទ្រព្យសកម្មសរុប | 13,606,569 | 13,119,755 | 12,296,676 |
| មូលធនភាគហ៊ុនិក | 7,209,340 | 7,158,414 | 7,283,905 |
| អនុបាតសំណងធានារ៉ាប់រង | 43.5% | 36.3% | 49.4% |
| អនុបាតចំណាយ | 67% | 52.1% | 39.7% |
| អនុបាតរួម | 142.6% | 112.8% | 105.5% |
| ផលត្រឡប់លើមូលធនភាគហ៊ុនិក | -17.2% | -0.7% | 1.7% |
| ផលត្រឡប់លើទ្រព្យសកម្ម | -9.1% | -0.3% | 1.0% |

ក្រុមហ៊ុនបានកត់ត្រានូវកំណើនជាលំដាប់លើលទ្ធផលនៃផលចំណេញសុទ្ធ រយៈពេលបីឆ្នាំជាប់ៗគ្នាចាប់តាំងពីឆ្នាំ 2023 មក។ នៅក្នុងឆ្នាំ 2025 នេះ គឺជាឆ្នាំដំបូងនៃប្រតិបត្តិការអាជីវកម្មរបស់ខ្លួនដែលក្រុមហ៊ុនទទួលបានផលចំណេញ ដោយសម្រេចបាននូវទឹកប្រាក់ចំនួន **125,491 ដុល្លារអាមេរិក**។ បុព្វលាភធានារ៉ាប់រងដុលបានកើនឡើង **12%** ធៀបនឹងឆ្នាំមុន (ឆ្នាំ 2024)។

ផលចំណេញមុនកាត់ពន្ធបានបង្ហាញពីភាពធន់ដ៏រឹងមាំ ទោះបីជាមានការប្រឈមនានានៅក្នុងទីផ្សារក៏ដោយ។ អនុបាតរួម (Combined ratio) បានប្រសើរឡើងមកត្រឹម **105.5%** ពី **112.8%** និងស្ថិតនៅក្នុងកម្រិតដែលអាចទទួលយកបាន ដែលនេះសបញ្ជាក់ឱ្យឃើញពីការបន្តរក្សាបាននូវវិន័យក្នុងការវាយតម្លៃហានិភ័យ ការគ្រប់គ្រងសំណងធានារ៉ាប់រង និងការធ្វើបរិវត្តកម្មចំណាយឱ្យមានប្រសិទ្ធភាពខ្ពស់។

ក្រុមហ៊ុននៅតែបន្តរក្សាបាននូវស្ថានភាពហិរញ្ញវត្ថុដ៏រឹងមាំ និងស្ថិរភាពល្អ ដោយមានទ្រព្យសកម្មសរុបចំនួន **12.3 លានដុល្លារអាមេរិក** និងមូលធនភាគហ៊ុនិកចំនួន **7.3 លានដុល្លារអាមេរិក** គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025។

សន្ទស្សន៍ផលត្រឡប់លើមូលធនភាគហ៊ុនិក (ROE) និងផលត្រឡប់លើទ្រព្យសកម្ម (ROA) បានកើនឡើងល្អប្រសើររហូតដល់ **1.7% (ពី -0.7%)** និង **1.0% (ពី -0.3%)** រៀងៗខ្លួន ដែលនេះជាសញ្ញាបង្ហាញថា ក្រុមហ៊ុនបានចាប់ផ្តើមបង្កើតផលចំណេញចេញពីមូលនិធិរបស់ភាគហ៊ុនិក និងទ្រព្យសកម្មរបស់ខ្លួនហើយ។



# អំពីក្រុមហ៊ុន ហ្វូតេ ឡាយហ្វ៍ អ៊ឹស្សួរ៉ិនស៍

ក្រុមហ៊ុន ហ្វូតេ ឡាយហ្វ៍ អ៊ិនស្ចួរិនស៍ (ខេមបូឌា) («ហ្វូតេ ឡាយហ្វ៍») គឺជាបុត្រសម្ព័ន្ធធានារ៉ាប់រងអាយុជីវិតរបស់ ហ្វូតេ ដែលជាក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេមួយនៅក្នុងប្រទេសកម្ពុជា។ ហ្វូតេ បានចាប់ផ្តើមដំណើរការផ្តល់កិច្ចការពារអាយុជីវិតតាមរយៈសេវាធានារ៉ាប់រងខ្នាតតូច នៅក្នុងឆ្នាំ 2016 និងបានបង្កើតក្រុមហ៊ុន ហ្វូតេ ឡាយហ្វ៍ ឱ្យក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតឯកទេស នៅក្នុងឆ្នាំ 2019។

ក្នុងឆ្នាំ 2025 ហ្វូតេ ឡាយហ្វ៍ គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតឈានមុខគេមួយនៅកម្ពុជាផ្អែកលើចំនួនអតិថិជនដែលទទួលបានការការពារ ប្រមាណ **700,000 នាក់**នៅទូទាំងប្រទេស។ តាមរយៈផលិតផលធានារ៉ាប់រងជាក់ស្តែង និងភាពងាយស្រួលក្នុងការទទួលបានសេវា ក្រុមហ៊ុនបានជួយដល់ក្រុមគ្រួសារកម្ពុជា បុគ្គលិក អតិថិជនខ្ចីប្រាក់ ម្ចាស់ប្រាក់បញ្ញើ និងសហគមន៍នានា ក្នុងការការពាររាល់វឌ្ឍនភាពរបស់ខ្លួន ព្រមទាំងការរៀបចំផែនការសម្រាប់អនាគតប្រកបដោយភាពជឿជាក់។

វត្តមានក្នុងទីផ្សាររបស់ ហ្វូតេ ឡាយហ្វ៍ ត្រូវបានគាំទ្រតាមរយៈចំណែកទីផ្សារដ៏ធំបំផុតមួយនៃចំនួនអតិថិជនដែលទទួលបានការការពារ ការទូទាត់សំណងធានារ៉ាប់រង និងទំហំទឹកប្រាក់ធានាដ៏រឹងមាំ ដែលនេះស្តែងឱ្យឃើញពីការរួមចំណែកយ៉ាងសំខាន់របស់ក្រុមហ៊ុន នៅក្នុងទិដ្ឋភាពនៃកិច្ចការពារហិរញ្ញវត្ថុនៅកម្ពុជា។ ទិសដៅរបស់ក្រុមហ៊ុននៅតែរក្សាបាននូវភាពច្បាស់លាស់៖ គឺការផ្តល់ជូននូវការការពារស្របតាមតម្រូវការជាក់ស្តែង ក្នុងការជួយពង្រឹងភាពធន់ផ្នែកហិរញ្ញវត្ថុរបស់គ្រួសារនីមួយៗ និងគាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុជាតិឱ្យកាន់តែទូលំទូលាយ។

នៅក្នុងឆ្នាំ 2025 បន្ទាប់ពីការកែសម្រួលយុទ្ធសាស្ត្រលើបណ្តាញចែកចាយ និងរចនាសម្ព័ន្ធផលប័ត្រអាជីវកម្ម ហ្វូតេ ឡាយហ្វ៍ សម្រេចបាននូវប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំក្រោយទូទាត់ពន្ធ ជាលើកដំបូងបំផុតចាប់តាំងពីការបង្កើតក្រុមហ៊ុនមក ទន្ទឹមនឹងការរក្សាបាននូវកំណើនបុព្វលាភធានារ៉ាប់រងនិងចំនួនអតិថិជនដែលទទួលបានការការពារ។ សមិទ្ធផលដ៏សំខាន់នេះឆ្លុះបញ្ចាំងពីប្រព័ន្ធអភិបាលកិច្ចដ៏រឹងមាំ ភាពធន់នៃប្រតិបត្តិការដែលបានកែលម្អកាន់តែប្រសើរ ការអនុវត្តការងារប្រកបដោយវិន័យ និងគំរូប្រតិបត្តិការអាជីវកម្មប្រកបដោយចីរភាព។

ក្រៅពីលទ្ធផលការងារអាជីវកម្ម ហ្វូតេ ឡាយហ្វ៍ ក៏បានរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍវិស័យធានារ៉ាប់រង ការសន្សំ ការចូលនិវត្តន៍ ព្រមទាំងប្រព័ន្ធហិរញ្ញវត្ថុឱ្យកាន់តែរីកចម្រើនទូលំទូលាយ នៅក្នុងប្រទេសកម្ពុជា និងនៅក្នុងតំបន់។ តាមរយៈកិច្ចពិភាក្សា ការចូលរួមសហការជាមួយនិយ័តករ ការអប់រំផ្សព្វផ្សាយជាសាធារណៈ វេទិកាកម្រិតតំបន់ និងការចែករំលែកទស្សនទាន ក្រុមហ៊ុនបានដើរតួជាកាតាលីករជំរុញបរិយាប័ន្នហិរញ្ញវត្ថុ កិច្ចការពាររបស់វិស័យឯកជន ការសន្សំនូវដើមទុនរយៈពេលវែង ការត្រៀមលក្ខណៈសម្រាប់ការចូលនិវត្តន៍ និងការបង្កើតភាពធន់ផ្នែកហិរញ្ញវត្ថុឱ្យកាន់តែរឹងមាំ។

ចក្ខុវិស័យឆ្នាំ 2035 របស់ ហ្វូតេ ឡាយហ្វ៍ គឺការបន្តពង្រីកវិសាលភាពនៃកិច្ចការពារពីសេវាធានារ៉ាប់រង គាំទ្រអតិថិជនក្នុងដំណើរឆ្ពោះទៅរកសេចក្តីថ្លៃថ្នូរផ្នែកហិរញ្ញវត្ថុឱ្យកាន់តែប្រសើរឡើង បំពេញចន្លោះប្រហោងនៃការយល់ដឹងផ្នែកហិរញ្ញវត្ថុ និងពង្រឹងភាពធន់ផ្នែកហិរញ្ញវត្ថុនៅទូទាំងប្រទេស។ សម្រាប់ ហ្វូតេ ឡាយហ្វ៍ រាល់បណ្ណសន្យារ៉ាប់រងនីមួយៗគឺមានតម្លៃលើសពីកិច្ចការពារ ពោលគឺវាតំណាងឱ្យក្តីសង្ឃឹម សេចក្តីថ្លៃថ្នូរ ភាពធន់ និងភាពជឿជាក់សម្រាប់ក្រុមគ្រួសារកម្ពុជាក្នុងការកសាងអនាគតដ៏រឹងមាំ។

ក្រុមហ៊ុនបានទាក់ទាញអតិថិជនតាមរយៈទំនុកចិត្ត និងវិសាលភាពនៃបណ្តាញដៃគូធនាគារ (Bancassurance) ព្រមទាំងបណ្តាញចែកចាយអាជីវកម្មដ៏ទូលំទូលាយ រួមមាន ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានភតិសន្យា អតិថិជនសាជីវកម្ម ក្រុមហ៊ុនជើងសា ដៃគូអាជីវកម្មថ្មី និងដៃគូយុទ្ធសាស្ត្រនានា។ គំរូអាជីវកម្មនេះជួយឱ្យ ហ្វូតេ ឡាយហ្វ៍ អាចផ្តល់សេវាធានារ៉ាប់រងកាន់តែមានភាពងាយស្រួល តម្លៃសមរម្យ និងឆ្លើយតបចំតម្រូវការដែលកំពុងវិវត្តរបស់ប្រជាជន និងសេដ្ឋកិច្ចកម្ពុជា។

វឌ្ឍនភាពរបស់ ហ្វូតេ ឡាយហ្វ៍ ក៏ត្រូវបានទទួលស្គាល់ជាអន្តរជាតិផងដែរ រួមមានការតែងតាំងជាបេក្ខភាពសម្រាប់ពានរង្វាន់ **Qorus Reinvented Distribution Award** និងត្រូវបានផ្តល់កិត្តិនាមជា **ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតរីកចម្រើនលឿនជាងគេ** និងជា **ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតប្រកបដោយនវានុវត្តន៍ជាងគេ** ពីស្ថាប័ន **International Finance Awards** ។

# ចក្ខុវិស័យរបស់យើង

ចក្ខុវិស័យរបស់យើងគឺផ្តល់ការការពារ និងផ្តល់សិទ្ធិអំណាចដល់មនុស្សគ្រប់រូបនៅក្នុងតំបន់ សម្រាប់អនាគតដ៏ល្អប្រសើរ - មនុស្សម្នាក់ - អាជីវកម្មមួយ ក្នុងពេលតែមួយ ។

# បេសកកម្មរបស់យើង

បេសកកម្មរបស់យើងគឺផ្តល់ជូននូវផលិតផល និងសេវាកម្មដែលផ្តោតសំខាន់លើអតិថិជន ប្រកបដោយភាពច្នៃប្រឌិត កសាងសមត្ថភាពមនុស្ស និងរួមចំណែកដល់វឌ្ឍនភាពនៃឧស្សាហកម្មធានារ៉ាប់រងនៅក្នុងទីផ្សារដែលយើងប្រតិបត្តិ ។

# គុណតម្លៃរបស់យើង

គុណតម្លៃរបស់យើងឆ្លុះបញ្ចាំងពីអ្វីដែល Forte តំណាងឱ្យ៖

- **F** ការគិតឆ្ពោះទៅមុខ
- **O** វប្បធម៌ចែករំលែក ទទួលយកមតិកែលម្អ
- **R** ទំនួលខុសត្រូវខ្ពស់
- **T** ទំនុកចិត្ត ភាពជឿជាក់
- **E** ការផ្តល់សិទ្ធិអំណាច



# ពានរង្វាន់ និងសមិទ្ធផលសំខាន់ៗ







## កម្រិតស្តង់ដាជាតិ: AA+ (KH)
## កម្រិតស្តង់ដាអន្តរជាតិ: B+ (2024–2026)

### ស្ថាប័ន GCR Ratings (បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Moody’s)

រក្សាបាននូវចំណាត់ថ្នាក់កម្រិតខ្ពស់បំផុតក្នុងរយៈពេល 3 ឆ្នាំជាប់ៗគ្នា ដែលសបញ្ជាក់ពីភាពធន់ផ្នែកហិរញ្ញវត្ថុ និងការត្រៀមលក្ខណៈរួចជាស្រេចរបស់ក្រុមហ៊ុនក្នុងការការពារអតិថិជនគ្រប់កាលៈទេសៈ។

## នាយកប្រតិបត្តិប្រចាំឆ្នាំ (2024)

### ពានរង្វាន់ថ្នាក់ដឹកនាំឆ្នើមប្រចាំអាស៊ី (Asian Management Excellence Awards)

ផ្តល់កិត្តិយសជូន លោក **យក់ ចំរើនឫទ្ធិ** ចំពោះភាពជាអ្នកដឹកនាំប្រកបដោយនវានុវត្តន៍ និងការផ្តោតលើអតិថិជនជាចម្បងអស់រយៈពេលជាង **30 ឆ្នាំ**។







## Fastest Growing & Most Innovative Life Insurer (2024)

### International Finance Awards

ការផ្តល់ជូននូវពានរង្វាន់ដ៏មានកិត្យានុភាពចំនួនពីរ រួមមាន៖ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតរីកចម្រើនលឿនជាងគេ និងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតប្រកបដោយនវានុវត្តន៍ជាងគេ ដែលបញ្ជាក់ឱ្យឃើញពីគន្លងនៃកំណើនដ៏រឹងមាំ ការប្តេជ្ញាចិត្តចំពោះនវានុវត្តន៍ ព្រមទាំងការបន្តផ្តោតលើការផ្តល់ជូននូវដំណោះស្រាយធានារ៉ាប់រងប្រកបដោយគុណតម្លៃសម្រាប់សង្គមជាតិ។

## ដៃគូវិជ្ជាជីវៈកម្រិតអន្តរជាតិ (2025)

### វិទ្យាស្ថាន CII (Chartered Insurance Institute)

បង្ហាញកាន់តែច្បាស់ពីការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះស្តង់ដាវិជ្ជាជីវៈកម្រិតសកល ការអភិវឌ្ឍសមត្ថភាពបុគ្គលិកប្រកបដោយវិជ្ជាជីវៈ និងភាពជាអ្នកដឹកនាំក្នុងវិស័យនេះក្នុងរយៈពេលវែង។

# ផលិតផល និងសេវាកម្មធានារ៉ាប់រង

## ធានាអនាគតរបស់លោកអ្នកតាមរយៈការការពារអាយុជីវិត ការគាំទ្ររាល់ក្តីស្រមៃ និងការកសាងទំនុកចិត្តផ្នែកហិរញ្ញវត្ថុប្រកបដោយចីរភាព។

ដំណោះស្រាយធានារ៉ាប់រងអាយុជីវិតរបស់យើងត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវកិច្ចការពាររយៈពេលវែង និងសន្តិភាពផ្នែកហិរញ្ញវត្ថុសម្រាប់បុគ្គល ក្រុមគ្រួសារ និងសហគមន៍។

### ផលិតផល៖

- អាយុជីវិតមានកាលកំណត់ជាក្រុម
- អាយុជីវិតខ្នាតតូច
- អាយុជីវិតការពារកម្ចី
- ការពារកម្ចីជាក្រុម
- ហ្វូតតេ ឡាយហ្វ៍ Flexi
- ហ្វូតតេ ឡាយហ្វ៍ Flexi Plus
- អាយុជីវិតលើគម្រោងគាំពារ
- អាយុជីវិតសម្រាប់ការសិក្សា
- អាយុជីវិតការពារជាក្រុមទូលំទូលាយ
- ចំណាយព្យាបាលរបួស
- អត្ថប្រយោជន៍គ្រោះថ្នាក់ និងសុខភាព
- អាយុជីវិតមានកាលកំណត់
- ការពារជំងឺធ្ងន់ធ្ងរជាក្រុម
- ការពារជំងឺធ្ងន់ធ្ងរ
- គ្រុបមេដប្រូ
- គ្រុបមេដប្រូផ្លើស





# ភាពជាដៃគូ និងបណ្តាញចែកចាយអាជីវកម្ម

ក្រុមហ៊ុននៅតែបន្តពង្រីកវិសាលភាពនៃបណ្តាញចែកចាយរបស់ខ្លួនតាមរយៈគំរូនៃកិច្ចសហប្រតិបត្តិការជាដៃគូយុទ្ធសាស្ត្រចំគោលដៅដើម្បីធានាថាដំណោះស្រាយធានារ៉ាប់រងអាយុជីវិតអាចឈានទៅដល់ដៃអតិថិជននៅគ្រប់ស្រទាប់វណ្ណៈក្នុងសង្គម។ យុទ្ធសាស្ត្រចែកចាយរបស់យើងគឺផ្តោតលើការកសាងសម្ព័ន្ធភាពដ៏រឹងមាំជាមួយបណ្តាដៃគូធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាប័នសាជីវកម្ម និងដៃគូអាជីវកម្មថ្មីៗ ដែលអនុញ្ញាតឱ្យយើងផ្តល់ជូននូវសេវាធានារ៉ាប់រងអាយុជីវិតក្នុងនាមជាផ្នែកមួយមិនអាចខ្វះបាននៃផែនការហិរញ្ញវត្ថុនិងកិច្ចការពារសហគមន៍។

ប៊េងកាស្សួរេន ឬដៃគូធានាគារ នៅតែជាក្បាលម៉ាស៊ីនជំរុញកំណើនអាជីវកម្មដ៏សំខាន់ដែលអនុញ្ញាតឱ្យយើងផ្តល់ជូនអតិថិជននូវលទ្ធភាពទទួលបានផលិតផលធានារ៉ាប់រងអាយុជីវិតកាន់តែងាយស្រួលតាមរយៈគ្រឹះស្ថានហិរញ្ញវត្ថុដែលគួរជាទីទុកចិត្ត។ បច្ចុប្បន្ន ក្រុមហ៊ុនកំពុងសហការយ៉ាងជិតស្និទ្ធជាមួយដៃគូធនាគារចំនួន 7 ស្ថាប័នដើម្បីពង្រីកវិសាលភាពគ្របដណ្តប់នៃសេវាកម្មរបស់យើង។ បណ្តាញចែកចាយនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹងនិងលទ្ធភាពទទួលបានសេវា ដែលធ្វើឱ្យកិច្ចការពារកាន់តែមានលក្ខណៈបរិយាប័ន្ន និងរហ័សទាន់ចិត្តតាមតម្រូវការភ្លាមៗរបស់អតិថិជន។

ទន្ទឹមនឹងនេះដែរ ក្រុមហ៊ុនបានពង្រឹងអាជីវកម្មតាមរយៈផលិតផលធានារ៉ាប់រងអាយុជីវិតជាក្រុម និងសាជីវកម្ម ដោយបានសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាស្ថាប័ននានា ដើម្បីផ្តល់នូវដំណោះស្រាយធានារ៉ាប់រងក្នុងការលើកកម្ពស់សុវត្ថិភាពហិរញ្ញវត្ថុ និងសុខុមាលភាពរបស់បុគ្គលិក។ កិច្ចសហការជាមួយដៃគូអាជីវកម្មថ្មីៗ បានជួយពង្រីកវិសាលភាពរបស់យើងឱ្យកាន់តែទូលំទូលាយទៅកាន់សហគមន៍តាមរយៈការផ្តល់នូវដំណោះស្រាយដែលអាចឆ្លើយតបតាមតម្រូវការជាក់ស្តែងជូនដល់ស្ថាប័ន និងសមាគមជាច្រើនផងដែរ។

ការសហការជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់ឥណទានអាចអនុញ្ញាតដល់ក្រុមហ៊ុនក្នុងការគាំទ្រដល់ហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្នតាមរយៈការរួមបញ្ចូលនូវកិច្ចការពារអាយុជីវិតទៅក្នុងផលិតផលកម្ចី ដែលអាចជួយការពារកាតព្វកិច្ចហិរញ្ញវត្ថុ ព្រមទាំងអនាគតក្រុមគ្រួសាររបស់អតិថិជន។

ឈរលើចក្ខុវិស័យដោយផ្តោតលើអតិថិជនជាគោល ក្រុមហ៊ុនបន្តលើកកម្ពស់បណ្តាញចែកចាយរបស់ខ្លួនតាមរយៈការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល និងនវានុវត្តន៍ទៅក្នុងសេវាកម្ម ដើម្បីធានាបាននូវបទពិសោធន៍ដ៏ប្រសើរ គិតចាប់តាំងពីការទិញ រហូតដល់ដំណាក់កាលទាមទារសំណងធានារ៉ាប់រង។

តាមរយៈកិច្ចសហប្រតិបត្តិការជាដៃគូទាំងនេះ ក្រុមហ៊ុនមិនត្រឹមតែពង្រីកវត្តមានទីផ្សារតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបាននិងកំពុងបំពេញបេសកកម្មក្នុងការជំរុញឱ្យសេវាធានារ៉ាប់រងអាយុជីវិតកាន់តែមានភាពងាយស្រួល តម្លៃសមរម្យ សមស្របទៅតាមតម្រូវការ និងអត្ថប្រយោជន៍សម្រាប់ប្រជាជនកម្ពុជា។

# អតិថិជន

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វតតេ ឡាយហ្វ៍ មានគោលដៅចង់ក្លាយជាម៉ាកសញ្ញាធានារ៉ាប់រងអាយុជីវិតដែលគ្រប់គ្នានឹកឃើញមុនគេនៅកម្ពុជា តាមរយៈការគាំទ្រដល់បុគ្គល ក្រុមគ្រួសារ អាជីវកម្ម និងសហគមន៍នានា ក្នុងការសន្សំទ្រព្យសម្បត្តិ ការពារទ្រព្យសម្បត្តិ បង្កើនស្ថិរភាពជីវភាពរស់នៅ និងរៀបចំផែនការសម្រាប់អនាគត។ នៅពីក្រោយបណ្ណសន្យារ៉ាប់រងនីមួយៗ គឺសុទ្ធតែមានរឿងរ៉ាវជីវិតរបស់មនុស្សម្នាក់ៗ ពោលគឺសុវត្ថិភាពហិរញ្ញវត្ថុរបស់ក្រុមគ្រួសារ ភាពកក់ក្តៅក្នុងចិត្តរបស់អតិថិជនកម្ចី ការបារម្ភពីសុវត្ថិភាពរបស់និយោជិត ទំនុកចិត្តរបស់ម្ចាស់អាជីវកម្ម ឬអនាគតរបស់កុមារតូចៗ។ នេះជាមូលហេតុដែលគោលបំណងរបស់យើងមិនត្រឹមតែជាការផ្តល់ជូននូវសេវាកម្មធានារ៉ាប់រងប៉ុណ្ណោះទេប៉ុន្តែគឺដើម្បីឈរនៅក្បែរនិងរួមដំណើរជាមួយអតិថិជននូវរាល់គ្រប់ដំណាក់កាលដ៏សំខាន់ និងការប្រឈមនានាក្នុងឆាកជីវិត។

តាមរយៈកិច្ចសហការជាដៃគូជាមួយធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អតិថិជនសាជីវកម្ម និងដៃគូអាជីវកម្មថ្មីៗ យើងបានធ្វើឱ្យការការពារអាយុជីវិតកាន់តែមានភាពងាយស្រួលក្នុងការទទួលបាននៅទូទាំងប្រទេស រួមទាំងសហគមន៍ដែលមិនទាន់ទទួលបានសេវាកម្មគ្រប់គ្រាន់ផងដែរ។ នាពេលបច្ចុប្បន្ននេះ ហ្វតតេ ឡាយហ្វ៍ បានផ្តល់ការការពារដល់អតិថិជនដែលទទួលបានការការពារប្រមាណ **700,000 នាក់** ជូនដល់អតិថិជនកម្ចី ម្ចាស់ប្រាក់បញ្ញើ បុគ្គលិកអតិថិជនសាជីវកម្ម សហគ្រាសធុនតូច និងមធ្យម ក្រុមគ្រួសារ និងសមាជិកនៃដៃគូអាជីវកម្មនានា ដូចជាសាលារៀនជាដើម។

នៅក្នុងឆ្នាំ 2025 ក្រុមហ៊ុនបានទូទាត់សំណងធានារ៉ាប់រងប្រមាណ **1.6 លានដុល្លារសហរដ្ឋអាមេរិក** ក្នុងនោះគិតជាមធ្យមមានសំណង **12 ករណី**ជារៀងរាល់ថ្ងៃ។ សំណងនីមួយៗដែលបានទូទាត់គឺជាការគាំទ្រជាក់ស្តែងចំពេលដែលក្រុមគ្រួសារអតិថិជនត្រូវការបន្ទាន់បំផុត ដើម្បីជួយអតិថិជនក្នុងការគ្រប់គ្រងភាពមិនប្រាកដប្រជានានាដោយក្តីសង្ឃឹម សេចក្តីថ្លៃថ្នូរ និងភាពកក់ក្តៅក្នុងចិត្តកាន់តែប្រសើរ។ យើងបន្តពង្រឹងទំនាក់ទំនងជាមួយអតិថិជនឱ្យកាន់តែស៊ីជម្រៅ តាមរយៈដំណោះស្រាយធានារ៉ាប់រងដ៏សម្បូរបែប នីតិវិធីដ៏សាមញ្ញ និងសេវាកម្មដ៏រហ័សទាន់ចិត្ត។ស្របពេលដែលប្រទេសកម្ពុជាបន្តមានវឌ្ឍនភាពទៅមុខ ហ្វតតេ ឡាយហ្វ៍ នៅតែបន្តប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការពង្រីកលទ្ធភាពក្នុងការទទួលបានការការពារអាយុជីវិត និងផ្តល់សិទ្ធិអំណាចដល់ប្រជាជនកម្ពុជាក្នុងការការពារអនាគត និងរស់នៅប្រកបដោយភាពជឿជាក់។



# បណ្តាញ

តាមរយៈបណ្តាញសាខា និងទីតាំងផ្តល់សេវាកម្មរបស់ ក្រុមហ៊ុនធានារ៉ាប់រង ហ្វូតេ នៅទូទាំងប្រទេស អតិថិជនរបស់ ហ្វូតេ ឡាយហ្វ៍ អាចទទួលយកសេវា និងដំណោះស្រាយបានយ៉ាងងាយស្រួល។




## រាជធានីភ្នំពេញ

- ក្រុមហ៊ុន ហ្វូតេ ឡាយហ្វ៍ អឹស្សូរ៉ិនស៍ (ខេមបូឌា) ម.ក ទីស្នាក់ការកណ្តាល៖ ជាន់ទី៣A U០៨&០៩ អគារលេខ១១៣C មហាវិថីម៉ៅសេទុង ភូមិ៧ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
- ក្រុមហ៊ុន ហ្វូតេ អ៊ិនស្ទួរិនស៍ (ខេមបូឌា) ទីស្នាក់ការកណ្តាល៖ អគារ វឌ្ឍនៈ កាពីតាល់ ជាន់ទី១៨ លេខ ៦៦ មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។
- ក្រុមហ៊ុន  ហ្វូតេ អ៊ិនស្ទួរិនស៍ (ខេមបូឌា) សាខាដូនពេញ៖ អគារ One Park លេខ#B3A និង#B5 ផ្លូវ R8 ភូមិ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។



# ក្រមសីលធម៌ និងវិន័យការងារ

ក្រុមហ៊ុនបានអនុម័ត និងដាក់ឱ្យអនុវត្តនូវក្រមសីលធម៌ និងវិន័យការងារគ្រប់ជ្រុងជ្រោយមួយ (ហៅកាត់ថា «ក្រមសីលធម៌») ដែលត្រូវបានអនុវត្តចំពោះសមាជិកក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ និងបុគ្គលិកទាំងអស់របស់ក្រុមហ៊ុន។ ក្រមសីលធម៌នេះត្រូវបានរៀបចំឡើងក្នុងគោលបំណងធានាបាននូវការអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន រួមទាំងបទប្បញ្ញត្តិនានាដែលចេញដោយនិយ័តករធានារ៉ាប់រងកម្ពុជា (ន.ធ.ក.) ព្រមទាំងលើកកម្ពស់ការប្រកបការងារប្រកបដោយសីលធម៌ និងលក្ខណៈវិជ្ជាជីវៈខ្ពស់នៅគ្រប់កម្រិតនៃស្ថាប័ន។
ក្រមសីលធម៌នេះបានចែងពីគោលការណ៍គ្រឹះដែលតម្រូវឱ្យបុគ្គលិកគ្រប់រូបបំពេញភារកិច្ចប្រកបដោយភាពស្មោះត្រង់ សុចរិតភាព យកចិត្តទុកដាក់ខ្ពស់និងខិតខំប្រឹងប្រែងអស់ពីសមត្ថភាពប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងរួមគ្នារក្សាការពារកិត្តិនាមរបស់ក្រុមហ៊ុន។ បន្ថែមលើនេះ បុគ្គលិកទាំងអស់ត្រូវតែអនុវត្តតាមរាល់កាតព្វកិច្ចច្បាប់ និងបទប្បញ្ញត្តិ ក៏ដូចជាគោលការណ៍ និងនីតិវិធីផ្ទៃក្នុងរបស់ក្រុមហ៊ុន។

ទន្ទឹមនឹងនេះ ក្រមសីលធម៌បានគ្របដណ្តប់លើចំណុចគន្លឹះសំខាន់ៗនៃកម្រិតវិន័យការងារ រួមមាន ការគ្រប់គ្រងទំនាស់ផលប្រយោជន៍ឱ្យបានត្រឹមត្រូវ ដែលតម្រូវឱ្យបុគ្គលម្នាក់ៗចៀសវាងស្ថានភាពទាំងឡាយណាដែលផលប្រយោជន៍ផ្ទាល់ខ្លួនអាចជះឥទ្ធិពល ឬផ្ទុយពីផលប្រយោជន៍របស់ក្រុមហ៊ុន និងត្រូវបង្ហើបឱ្យដឹង (Disclose) អំពីទំនាស់ផលប្រយោជន៍ជាក់ស្តែង ឬលទ្ធភាពដែលអាចកើតមានស្របតាមគោលការណ៍ផ្ទៃក្នុង។ ក្រមសីលធម៌នេះក៏បានកំណត់កាតព្វកិច្ចយ៉ាងម៉ឺងម៉ាត់ពាក់ព័ន្ធនឹងការរក្សាការសម្ងាត់ និងការការពារទិន្នន័យ ដើម្បីធានាថា រាល់ព័ត៌មានផ្ទៃក្នុងរបស់ក្រុមហ៊ុន ម្ចាស់បណ្ណសន្យារ៉ាប់រង និងដៃគូអាជីវកម្ម ត្រូវបានរក្សាការពារយ៉ាងសុវត្ថិភាព និងប្រើប្រាស់សម្រាប់តែគោលបំណងអាជីវកម្មស្របច្បាប់តែប៉ុណ្ណោះ។

ស្របតាមការរំពឹងទុករបស់ស្ថាប័នប្បញ្ញត្តិករលើក្រមសីលធម៌ទីផ្សារ (Market conduct) ក្រុមហ៊ុនបានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការផ្តល់នូវការគិតគូរ និងការអនុវត្តតាមគោលការណ៍សមធម៌ជូនដល់ម្ចាស់បណ្ណសន្យារ៉ាប់រង រួមទាំងការផ្តល់ព័ត៌មានដែលច្បាស់លាស់ និងត្រឹមត្រូវអំពីផលិតផលធានារ៉ាប់រងការដោះស្រាយសំណងធានារ៉ាប់រងទាន់ពេលវេលា និងប្រកបដោយភាពត្រឹមត្រូវ សមធម៌ ព្រមទាំងការរក្សាស្តង់ដាសេវាកម្មកម្រិតខ្ពស់។

លើសពីនេះទៅទៀត ក្រមសីលធម៌នេះបានបញ្ជាបបញ្ចូលនូវតម្រូវការនានាពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងការប្រឆាំងហិរញ្ញប្បទានដល់ភេរវកម្ម និងការរីករាលដាលអាវុធមហាប្រល័យ (AML/CFT) ឱ្យស្របទៅនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិរបស់ ន.ធ.ក. រួមមាន ការពិនិត្យផ្ទៀងផ្ទាត់ដោយយកចិត្តទុកដាក់លើអតិថិជន (Customer due diligence) ការតាមដានត្រួតពិនិត្យជាប្រចាំ និងការរាយការណ៍អំពីប្រតិបត្តិការដែលមានការសង្ស័យ។

ក្រុមហ៊ុនប្រកាន់ខ្ជាប់នូវគោលការណ៍ «មិនអត់ឱនដាច់ខាត» (Zero-tolerance) ចំពោះអំពើពុករលួយ និងការសូកប៉ាន់គ្រប់ទម្រង់។ រាល់សមាជិកក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ ត្រូវបានហាមឃាត់ដាច់ខាតក្នុងការផ្តល់ ការទាមទារ ឬការទទួលយកនូវផលប្រយោជន៍មិនត្រឹមត្រូវណាមួយ។ គោលការណ៍ណែនាំស្តីពីការផ្តល់ និងការទទួលកាដូ ឬការរៀបចំការទទួលបដិសណ្ឋារកិច្ច ត្រូវបានដាក់ចេញដើម្បីធានាថា រាល់ការអនុវត្តទាំងនោះស្ថិតក្នុងកម្រិតសមហេតុផលមានតម្លាភាពនិងមិនជះឥទ្ធិពលដល់ការសម្រេចចិត្តអាជីវកម្មឡើយ។

បន្ថែមលើនេះ ក្រុមហ៊ុនបានបង្កើតយន្តការរាយការណ៍ពីភាពមិនប្រក្រតី (Whistleblowing mechanism) ដែលអនុញ្ញាតឱ្យបុគ្គលិក និងភាគីពាក់ព័ន្ធនានា អាចរាយការណ៍ដោយភាពស្មោះត្រង់នូវរាល់ការសង្ស័យលើការប្រព្រឹត្តមិនគប្បី ឬការរំលោភបំពានណាមួយលើក្រមសីលធម៌នេះ ក្រោមទម្រង់សម្ងាត់ ដោយមិនមានការបារម្ភពីការគំរាមកំហែង ឬការសងសឹកឡើយ។ ក្រុមហ៊ុនក៏បានរៀបចំនីតិវិធីសមស្រប ដើម្បីធានាថារាល់របាយការណ៍សង្ស័យទាំងនោះ នឹងត្រូវទទួលបានការស៊ើបអង្កេត និងដោះស្រាយយ៉ាងត្រឹមត្រូវបំផុត។

ក្រុមហ៊ុនតែងតែផ្តល់កម្មវិធីបណ្តុះបណ្តាល និងកម្មវិធីលើកកម្ពស់ការយល់ដឹងជាបន្តបន្ទាប់ ដើម្បីធានាថាបុគ្គលិកគ្រប់រូបបានយល់ដឹងច្បាស់ពីកាតព្វកិច្ចរបស់ខ្លួននៅក្រោមក្រមសីលធម៌នេះ ក៏ដូចជាបទប្បញ្ញត្តិជាធរមានដទៃទៀត។ រាល់ការបំពានណាមួយលើក្រមសីលធម៌នេះ នឹងត្រូវប្រឈមមុខនឹងវិធានការវិន័យស្របតាមគោលការណ៍ផ្ទៃក្នុងរបស់ក្រុមហ៊ុន និងច្បាប់ជាធរមាន។

# ទំនួលខុសត្រូវសង្គម

នៅក្រុមហ៊ុន ហ្វូតតេ ឡាយហ្វ៍ យើងជឿជាក់ថា កិច្ចការពារពិតប្រាកដ គឺមានតម្លៃលើសពីបណ្ណសន្យារ៉ាប់រង ពោលគឺការបង្កើតនូវអត្ថប្រយោជន៍វិជ្ជមានប្រកបដោយចីរភាពនៅក្នុងសហគមន៍។

## កិច្ចប្រជុំធានារ៉ាប់រងអាស៊ាន៖ កម្មវិធីវាយកូនហ្គោលសប្បុរសធម៌

ក្នុងឆ្នាំ 2025 ហ្វូតតេ មានមោទនភាពក្នុងការគាំទ្រព្រឹត្តិការណ៍វាយកូនគោលសប្បុរសធម៌អន្តរជាតិ "ASEAN Insurance Leader: Angkor Golf for Hope" ដែលត្រូវបានរៀបចំឡើងទន្ទឹមនឹងកិច្ចប្រជុំធានារ៉ាប់រងអាស៊ាន នៅក្នុងខេត្តសៀមរាប។ ព្រឹត្តិការណ៍នេះបានប្រមូលផ្តុំថ្នាក់ដឹកនាំធានារ៉ាប់រងក្នុងតំបន់ ដើម្បីលើកកម្ពស់សាមគ្គីភាព គាំទ្រដល់សកម្មភាពសប្បុរសធម៌ និងចូលរួមចំណែកដល់សហគមន៍មូលដ្ឋាន ក៏ដូចជាវិស័យទេសចរណ៍ផងដែរ។









## មូលដ្ឋានគ្រឹះនៃវិទ្យាសាស្ត្រគណនាបុព្វលាភធានារ៉ាប់រង៖ ឱកាសលូតលាស់ និងសារៈសំខាន់ក្នុងការធានារ៉ាប់រង

ហ្វូតតេ បន្តគាំទ្រដល់វិស័យអប់រំ និងការអភិវឌ្ឍន៍វិស័យធានារ៉ាប់រង តាមរយៈសិក្ខាសាលាស្តីពីការធានារ៉ាប់រង និងវិទ្យាសាស្ត្រគណនាបុព្វលាភធានារ៉ាប់រង (Actuarial Science) ដែលត្រូវបានរៀបចំឡើងក្រោមកិច្ចសហការជាមួយសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិងសាកលវិទ្យាល័យជាតិបាត់ដំបង ដើម្បីជួយជំរុញទឹកចិត្តដល់យុវជនជំនាន់ក្រោយឱ្យក្លាយជាអ្នកជំនាញវិជ្ជាជីវៈក្នុងវិស័យធានារ៉ាប់រងនៅកម្ពុជា។








## គំនិតផ្តួចផ្តើមគាំទ្រសហគមន៍សម្រាប់គ្រួសារជនភៀសសឹក

ដោយប្រកាន់ខ្ជាប់នូវស្មារតីមនុស្សធម៌ ហ្វតតេ ក៏បានរួមចំណែកផ្តល់ស្បៀងអាហារ គិតជាទឹកប្រាក់សរុបប្រមាណ **USD 10,000** ដល់ក្រុមគ្រួសារភៀសសឹកនៅតាមបណ្តាខេត្តមួយចំនួនជាប់ព្រំដែនកម្ពុជា។ សកម្មភាពសប្បុរសធម៌នេះត្រូវបានប្រគល់ជូនតាមរយៈ និយ័តករធានារ៉ាប់រងកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា និងសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA)។







## កសាងអនាគតដ៏ភ្លឺស្វាង៖ សាងសង់អគារសិក្សាថ្មីនៅខេត្តតាកែវ ក្រោមកិច្ចសហការជាមួយអង្គការទស្សនៈពិភពលោក

លើសពីនេះ ក្រុមហ៊ុនក៏បានឧបត្ថម្ភគាំទ្រដល់ការសាងសង់ថ្នាក់រៀនថ្មី និងបំពាក់គ្រឿងបរិក្ខារសិក្សាដល់សាលាបឋមសិក្សាមួយក្នុងខេត្តតាកែវ ដើម្បីជួយបង្កើតឱកាសអប់រំកាន់តែប្រសើរឡើងសម្រាប់សហគមន៍មូលដ្ឋាន។ គម្រោងនេះត្រូវបានអនុវត្តដោយជោគជ័យ ក្រោមការជួយសម្របសម្រួលផ្នែកកិច្ចការរដ្ឋបាលយ៉ាងយកចិត្តទុកដាក់ពីអង្គការទស្សនៈពិភពលោកកម្ពុជា (World Vision Cambodia)។











### ជំរុញកិច្ចការ ESG ដើម្បីកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាពតាមរយៈកិច្ចសហការជាមួយអង្គការទស្សនៈពិភពលោក អង្គការផ្លែនអន្តរជាតិ និងអង្គការសមាគមអភិរក្សសត្វព្រៃ

ក្រុមហ៊ុនបានចូលរួមគាំទ្រយ៉ាងសកម្មដល់ការលើកកម្ពស់បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) នៅក្នុងប្រទេសកម្ពុជា តាមរយៈការសហការជាមួយអង្គការជាច្រើន ដូចជា ទស្សនៈពិភពលោក (World Vision) អង្គការភ្លែនអន្តរជាតិ (Plan International) និងអង្គការសមាគមអភិរក្សសត្វព្រៃ (WCS)ជាដើម។ ក្រោមកិច្ចសហប្រតិបត្តិការជាដៃគូយុទ្ធសាស្ត្រ និងការសាមគ្គីគ្នាឆ្ពោះទៅរកគោលបំណងតែមួយនេះ យើងមានទិសដៅផ្តល់នូវផលប្រយោជន៍រយៈពេលវែងជូនដល់អតិថិជនរបស់យើង តាមរយៈការលើកកម្ពស់ចំណេះដឹង និងការយល់ដឹងផ្នែកហិរញ្ញវត្ថុនៅតាមសហគមន៍។





### ទំនួលខុសត្រូវការពារអតិថិជនក្នុងគ្រាដ៏លំបាកបំផុត៖ ផ្តល់សំណងធានារ៉ាប់រងអាយុជីវិតជូនដល់ក្រុមគ្រួសារអតីតកីឡាករជម្រើសជាតិ លោក ទេស សម្បត្តិ

ក្រុមហ៊ុនបានប្រគល់សំណងធានារ៉ាប់រងជូនដល់ក្រុមគ្រួសាររបស់អតីតកីឡាករបាល់ទាត់ជម្រើសជាតិកម្ពុជា លោក ទេស សម្បត្តិ តាមរយៈបណ្ណសន្យារ៉ាប់រងអាយុជីវិតមានកាលកំណត់ជាក្រុមជាមួយក្លិបបាល់ទាត់វិសាខា ដែលនេះបានឆ្លុះបញ្ចាំងពីតម្លៃពិតប្រាកដនៃកិច្ចការពារផ្នែកហិរញ្ញវត្ថុក្នុងអំឡុងពេលដ៏លំបាកបំផុតនៃដំណើរជីវិត។






### សំណងធានារ៉ាប់រងប្រមាណ 1.6 លានដុល្លារសហរដ្ឋអាមេរិក ត្រូវបានប្រគល់ជូនប្រជាជនកម្ពុជាជាង 4,500 គ្រួសារ

នៅក្នុងឆ្នាំ 2025 ក្រុមហ៊ុនបានបំពេញកាតព្វកិច្ចទូទាត់សំណងធានារ៉ាប់រងប្រមាណ 1.6 លានដុល្លារអាមេរិកអាមេរិក ជូនដល់អតិថិជនប្រមាណ 4,500 គ្រួសារ ដែលនេះជាការបន្តនូវការប្តេជ្ញាចិត្តរបស់យើងក្នុងការការពារក្រុមគ្រួសារកម្ពុជា ប្រកបដោយការយកចិត្តទុកដាក់ ភាពថ្លៃថ្នូរ និងជាទីទុកចិត្តបំផុត។
















# ក្រុមខ័ណ្ឌ និងការប្តេជ្ញាចិត្តលើកិច្ចការ បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG)

## អភិបាលកិច្ចប្រកបដោយចីរភាព

ក្រុមហ៊ុនបានបញ្ចូលការគិតគូរលើផ្នែកបរិស្ថាន សង្គម និង អភិបាលកិច្ច (“ESG”) ទៅក្នុងដំណើរការអភិបាលកិច្ច ប្រតិបត្តិការ និងការគ្រប់គ្រងហានិភ័យរបស់ខ្លួន ដែលនេះជាផ្នែកមួយនៃការប្តេជ្ញាចិត្តចំពោះការអនុវត្តអាជីវកម្មប្រកបដោយការទទួលខុសត្រូវ និង ចីរភាព។

ក្រុមប្រឹក្សាភិបាល និងថ្នាក់គ្រប់គ្រង បានមើលខុសត្រូវលើកិច្ចការនានាដែលពាក់ព័ន្ធនឹង ESG តាមរយៈក្របខ័ណ្ឌគ្រប់គ្រងហានិភ័យទូលំទូលាយរបស់ក្រុមហ៊ុន រួមទាំងហានិភ័យប្រតិបត្តិការផ្នែក ESG គំនិតផ្តួចផ្តើមផ្នែកចីរភាព អភិបាលកិច្ចនៃការធានារ៉ាប់រង និង អនុលោមភាពតាមបទប្បញ្ញត្តិ។ ការអនុវត្តកិច្ចការ ESG ទាំងនេះ គឺស្របតាមស្តង់ដារអភិបាលកិច្ច និងគោលដៅចីរភាពនៅថ្នាក់ក្រុប (Group-level)។

## ការទទួលខុសត្រូវចំពោះបរិស្ថាន

ក្រុមហ៊ុន នៅតែបន្តអនុវត្តសកម្មភាពប្រតិបត្តិការប្រកបដោយការទទួលខុសត្រូវចំពោះបរិស្ថាន ក្នុងគោលបំណងកាត់បន្ថយការប្រើប្រាស់ធនធាន និងលើកកម្ពស់ការយល់ដឹងអំពីចីរភាពក្នុងចំណោមបុគ្គលិក។ គំនិតផ្តួចផ្តើមសំខាន់ៗក្នុងឆ្នាំរបាយការណ៍នេះរួមមាន៖

- ការកាត់បន្ថយការប្រើប្រាស់ក្រដាស តាមរយៈការបង្កើនការធ្វើបរិវត្តកម្មឌីជីថល (Digitization)
- ការលុបបំបាត់ការប្រើប្រាស់ផលិតផលប្លាស្ទិកដែលប្រើបានតែម្តង (Single-use plastic) នៅតាមការិយាល័យទាំងអស់
- ការតាមដានការបំភាយឧស្ម័នកាបូនពីប្រតិបត្តិការ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់អគ្គិសនី ការដឹកជញ្ជូន និងការធ្វើដំណើរធុរកិច្ច
- កម្មវិធីលើកកម្ពស់ការយល់ដឹងពីបរិស្ថាន និងការចូលរួមក្នុងកិច្ចការចីរភាពរបស់បុគ្គលិក

ក្នុងនាមជាផ្នែកមួយនៃកម្មវិធីត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) នៅទូទាំងសម្ព័ន្ធក្រុមហ៊ុន (Group-wide) ហ្វូតតេ គ្រុប បានកត់ត្រានូវការកាត់បន្ថយការភាយឧស្ម័នកាបូនសរុប (Total carbon footprint) បានចំនួន 6.9% ក្នុងអំឡុងឆ្នាំ 2025 បើធៀបទៅនឹងឆ្នាំមុន ខណៈដែលការប្រើប្រាស់ក្រដាសជារួមបានធ្លាក់ចុះចំនួន 20.9%។

ក្រុមហ៊ុនបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចការធ្វើឱ្យកាន់តែប្រសើរឡើងទាំងនេះ តាមរយៈគំនិតផ្តួចផ្តើមលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការ និងការបង្កើនការអនុវត្តលំហូរការងារតាមប្រព័ន្ធឌីជីថល ដែលរួមបញ្ចូលទាំងការកាត់បន្ថយការភាយឧស្ម័នកាបូនក្នុងកម្រិតទី 2 (Scope 2 emissions) បានរហូតដល់ 42.7% ក្នុងអំឡុងពេលនៃរបាយការណ៍នេះ។

## ទំនួលខុសត្រូវសង្គម

ក្រុមហ៊ុនដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្របរិយាប័ន្នហិរញ្ញវត្ថុ និងភាពធន់ផ្នែកហិរញ្ញវត្ថុនៅទូទាំងប្រទេសកម្ពុជា តាមរយៈការផ្តល់នូវដំណោះស្រាយគាំពារអាយុជីវិតដែលអាចទទួលបានយ៉ាងងាយស្រួល និងមានតម្លៃសមរម្យសម្រាប់បុគ្គល និយោជិត និងក្រុមគ្រួសារ។ តាមរយៈដៃគូយុទ្ធសាស្ត្រ និងបណ្តាញចែកចាយនានា ក្រុមហ៊ុនបន្តពង្រីកវិសាលភាពនៃការទទួលបានកិច្ចការពារផ្នែកធានារ៉ាប់រងដល់ប្រជាជនកម្ពុជាយ៉ាងទូលំទូលាយរួមទាំងក្រុមអតិថិជនដែលតាមទម្លាប់ពីមុនមកអាចនឹងមានកម្រិតក្នុងការទទួលបានការគាំពារផ្នែកធានារ៉ាប់រងផ្លូវការ។

ក្រុមហ៊ុន គឺជាស្ថាប័នឈានមុខគេមួយក្នុងស្រុកដែលផ្តល់ការគាំពារផ្នែកធានារ៉ាប់រងអាយុជីវិតនៅក្នុងប្រទេសកម្ពុជា ហើយបច្ចុប្បន្នបានផ្តល់ការការពារដល់ចំនួនអតិថិជនដែលទទួលបានការការពារច្រើនជាងគេបំផុតនៅក្នុងទីផ្សារធានារ៉ាប់រងអាយុជីវិតនៅកម្ពុជា។ ក្រុមហ៊ុនជឿជាក់យ៉ាងមុតមាំថា ការពង្រីកវិសាលភាពនៃការទទួលបានកិច្ចការពារផ្នែកធានារ៉ាប់រងនេះរួមចំណែកជាវិជ្ជមានដល់ភាពធន់ផ្នែកហិរញ្ញវត្ថុ ស្ថិរភាពសេដ្ឋកិច្ច និងភាពធន់នៃសង្គមនៅតាមសហគមន៍នានាក្នុងស្រុក។

ក្នុងអំឡុងឆ្នាំនៃរបាយការណ៍នេះ ក្រុមហ៊ុនបានបន្តលើកកម្ពស់វប្បធម៌កន្លែងធ្វើការប្រកបដោយទំនួលខុសត្រូវ និងបរិយាប័ន្ន តាមរយៈការបង្កើនទំនាក់ទំនងជាមួយបុគ្គលិក កម្មវិធីលើកកម្ពស់ការយល់ដឹង និងគំនិតផ្តួចផ្តើមអភិវឌ្ឍន៍វិជ្ជាជីវៈ។ អត្រានៃការចូលរួមក្នុងគំនិតផ្តួចផ្តើមលើកកម្ពស់ការយល់ដឹងអំពីបរិស្ថានបានកើនឡើងរហូតដល់ 78% ក្នុងអំឡុងឆ្នាំនៃរបាយការណ៍នេះ។ ជាមួយគ្នានេះដែរ ក្រុមហ៊ុនក៏បានរក្សាយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយ និងការអនុវត្តនានាពាក់ព័ន្ធនឹងសុខុមាលភាពបុគ្គលិក បទដ្ឋានសីលធម៌ ស្តង់ដាប្រឆាំងការសូកប៉ាន់ និងការប្រឆាំងអំពើពុករលួយ ការដោះស្រាយបណ្តឹងតវ៉ា និងការអនុវត្តការងារប្រកបដោយសមធម៌ក្នុងកន្លែងធ្វើការ។

## អភិបាលកិច្ច និងការត្រួតពិនិត្យមើលហានិភ័យ

ក្រុមហ៊ុនបានរក្សានូវក្របខ័ណ្ឌអភិបាលកិច្ច និងការគ្រប់គ្រងហានិភ័យ ដែលត្រូវបានរៀបចំឡើងដើម្បីគាំទ្រដល់ការគ្រប់គ្រងប្រកបដោយភាពហ្មត់ចត់ គណនេយ្យភាព ភាពមានតម្លាភាព និងអនុលោមភាពតាមបទប្បញ្ញត្តិជាធរមាន។ ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងបានត្រួតពិនិត្យមើលយ៉ាងដិតដល់លើហានិភ័យនានាដែលពាក់ព័ន្ធនឹង ESG ក្នុងនាមជាផ្នែកមួយនៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុនឱ្យកាន់តែមានវិសាលភាពទូលំទូលាយ។

ស្តង់ដាអភិបាលកិច្ច និងគោលនយោបាយពាក់ព័ន្ធនឹង ESG ត្រូវបានពិនិត្យឡើងវិញជាទៀងទាត់ ដើម្បីធានាបាននូវការអនុវត្តស្របទៅនឹងការរំពឹងទុកផ្នែកបទប្បញ្ញត្តិ ផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ និងការវិវត្តនៃការអនុវត្តនៅក្នុងវិស័យនេះ។ ក្រុមហ៊ុននៅតែបន្តប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការរក្សាការអនុវត្តអភិបាលកិច្ចដ៏ល្អប្រសើរ និងប្រតិបត្តិការអាជីវកម្មប្រកបដោយទំនួលខុសត្រូវ ព្រមទាំងគាំទ្រដល់កិច្ចការពារម្ចាស់បណ្ណសន្យារ៉ាប់រងរយៈពេលវែង និងភាពធន់នៃប្រតិបត្តិការទាំងមូល។

# រចនាសម្ព័ន្ធក្រុមហ៊ុន



# ក្រុមប្រឹក្សាភិបាល



## លោក Charles Cheo

ប្រធានក្រុមប្រឹក្សាភិបាល

លោក Charles Cheo គឺជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ហ្វតតេ ឡាយហ្វ៍។ ក្នុងនាមជាសមាជិកម្នាក់នៃគ្រួសារស្ថាបនិកដែលបានបង្កើតក្រុមហ៊ុន ហ្វតតេ នៅក្នុងប្រទេសកម្ពុជា នាឆ្នាំ ១៩៩៩ លោកបានចំណាយពេលជាងពីរទសវត្សរ៍ក្នុងការរួមចំណែកកសាងទាំងក្រុមហ៊ុន និងជំរុញការរីកចម្រើននៃវិស័យធានារ៉ាប់រងឱ្យកាន់តែទូលំទូលាយនៅកម្ពុជា។ តាមរយៈការបំពេញការងារក្នុងតំណែងដឹកនាំជាច្រើន រួមទាំងតំណែងជាអគ្គនាយកគ្រុប លោក Charles បានដើរតួជាកម្លាំងចលករដ៏សំខាន់ក្នុងការកសាងក្រុមហ៊ុន ហ្វតតេ ឱ្យក្លាយជាក្រុមហ៊ុនធានារ៉ាប់រងធំជាងគេបំផុតនៅកម្ពុជា។ នៅក្រោមការដឹកនាំរបស់លោក ក្រុមហ៊ុន ហ្វតតេ ត្រូវបានទទួលស្គាល់ចំពោះក្រមសីលធម៌វិជ្ជាជីវៈដ៏រឹងមាំ ការប្តេជ្ញាចិត្តលើការអភិវឌ្ឍធនធានបុគ្គលិកដែលមានសក្តានុពល និងការរួមចំណែកដល់ការលើកកម្ពស់វឌ្ឍនភាពនៃវិស័យធានារ៉ាប់រងក្នុងស្រុក។

លោក Charles ទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រ (BSc) ពីសាលាទំនាក់ទំនង (School of Communications) នៃសាកលវិទ្យាល័យ Boston និងជាសមាជិកនៃវិទ្យាស្ថាន Chartered Insurance Institute (CII) នៃចក្រភពអង់គ្លេស ដោយទទួលបានសញ្ញាបត្រកម្រិតខ្ពស់ Advanced Diploma in Insurance (ACII)។

## លោក ង៉ែត ជូ អភិបាលឯករាជ្យ

ប្រធានគណៈកម្មាធិការវិនិយោគ



លោក ង៉ែត ជូ គឺជាប្រធានគណៈកម្មាធិការវិនិយោគ និងជាអ្នកជំនាញដ៏មានបទពិសោធន៍ក្រាស់ក្រែលជាង 15 ឆ្នាំ ក្នុងវិស័យសេវាកម្មហិរញ្ញវត្ថុ និងការផ្តល់ប្រឹក្សាយោបល់លើផ្នែកយុទ្ធសាស្ត្រ ការស្រាវជ្រាវ ការអភិវឌ្ឍអាជីវកម្ម និងបរិយាប័ន្នហិរញ្ញវត្ថុកម្ពុជា។ លោកមានជំនាញឯកទេសយ៉ាងស៊ីជម្រៅលើការរៀបចំផែនការវិនិយោគ ការវិភាគទីផ្សារ និងកំណើនអាជីវកម្ម ដើម្បីគាំទ្រដល់ការត្រួតពិនិត្យការវិនិយោគឱ្យមានប្រសិទ្ធភាពខ្ពស់។

បច្ចុប្បន្ន លោកកំពុងបម្រើការងារជាទីប្រឹក្សាជាន់ខ្ពស់នៅក្រុមហ៊ុន Emerging Markets Consulting (EMC) ដោយធ្វើការផ្តល់ប្រឹក្សាយោបល់ជូនដល់បណ្តាក្រុមហ៊ុន គ្រឹះស្ថានហិរញ្ញវត្ថុ និងអង្គការអភិវឌ្ឍន៍នានា លើផ្នែកយុទ្ធសាស្ត្រ ការសិក្សាសមិទ្ធិលទ្ធភាព និងការអភិវឌ្ឍផលិតផល។ នាពេលកន្លងមក លោកធ្លាប់បានកាន់តំណែងជាអគ្គនាយកនៃក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច Prevoir Kampuchea Micro-Life Insurance និងធ្លាប់បានដឹកនាំផ្នែកអភិវឌ្ឍន៍ផលិតផលនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ (AMK) ផងដែរ។

លោក ង៉ែត ជូ ធ្លាប់បានបំពេញការងារយ៉ាងទូលំទូលាយជាមួយស្ថាប័នអន្តរជាតិធំៗ ដូចជា USAID, UNDP និងធនាគារពិភពលោក (World Bank)។ លោកទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធុរកិច្ច (MBA) ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង និងបានបញ្ចប់កម្មវិធីសិក្សាអប់រំកម្រិតប្រតិបត្តិ (Executive Education) ពីសាកលវិទ្យាល័យ Harvard ផងដែរ។



## លោក ព្រូ ស៊ីថន អភិបាល

សមាជិកគណៈកម្មាធិការវិនិយោគ

លោក ព្រូ ស៊ីថន គឺជាសមាជិកគណៈកម្មាធិការវិនិយោគ និងជាអគ្គនាយកនៃក្រុមហ៊ុន ហ្វតេ ឡាយហ្វ៍។ ចាប់តាំងពីឆ្នាំ 2012 មក លោកបានដើរតួជាអ្នកត្រួសត្រាយផ្លូវក្នុងវិស័យធានារ៉ាប់រងអាយុជីវិតនៅកម្ពុជា ដោយបានរួមចំណែកបង្កើតក្រុមហ៊ុនធានារ៉ាប់រងអន្តរជាតិដំបូងគេនិងអភិវឌ្ឍដៃគូធនាគារ(Bancassurance)។បន្ទាប់ពីទទួលបានការតែងតាំងជាអគ្គនាយកក្នុងឆ្នាំ 2023 លោកបានដឹកនាំការផ្លាស់ប្តូរទម្រង់អាជីវកម្មរបស់ក្រុមហ៊ុនឱ្យមានចីរភាព និងផ្តោតលើអតិថិជន ដើម្បីជំរុញកំណើន និងបរិយាប័ន្នហិរញ្ញវត្ថុ។

លោក ស៊ីថន តែងតែចូលរួមក្នុងវេទិកាអន្តរជាតិឈានមុខគេ ដូចជា OECD–ADBI, Qorus និង EAIC ដើម្បីចែករំលែកទស្សនវិស័យជាក់ស្តែងស្តីពីការអភិវឌ្ឍវិស័យធានារ៉ាប់រង និងអភិបាលកិច្ច។

លោកទទួលបានសញ្ញាបត្រថ្នាក់អនុបណ្ឌិតពីសាកលវិទ្យាល័យ King’s College London និង Yokohama National University ព្រមទាំងបានបញ្ចប់ការសិក្សាថ្នាក់ប្រតិបត្តិពីសាលាធុរកិច្ច Ivey និង Melbourne។ ការដឹកនាំរបស់លោកទទួលបានការទទួលស្គាល់តាមរយៈពានរង្វាន់ Young Leader of the Year ពី Asia Insurance Review, ពានរង្វាន់ Asian Legal Business 40 Under 40 ព្រមទាំងគ្រឿងឥស្សរិយយស “មុនីសារាភ័ណ្ឌ” នៃព្រះរាជាណាចក្រកម្ពុជា។

## លោក ម៉ៅ សារិន អភិបាល

សមាជិកគណៈកម្មាធិការវិនិយោគ



លោក ម៉ៅ សារិន គឺជាសមាជិកគណៈកម្មាធិការវិនិយោគមានបទពិសោធន៍ជាង 20 ឆ្នាំ ក្នុងវិស័យមូលនិធិវិនិយោគឯកជន ការគ្រប់គ្រងការវិនិយោគ និងអភិវឌ្ឍន៍អភិបាលកិច្ចសាជីវកម្មនៅទូទាំងតំបន់អាស៊ីអាគ្នេយ៍។ ក្នុងនាមជាប្រធានផ្នែកវិនិយោគ នៃស្ថាប័ន Emerging Markets Investment Advisers (EMIA) លោកទទួលបន្ទុកដឹកនាំលើការរៀបចំយុទ្ធសាស្ត្រវិនិយោគការគ្រប់គ្រងផលប័ត្រនៃការវិនិយោគ និងគំនិតផ្តួចផ្តើមផ្នែកបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ព្រមទាំងបម្រើការងារនៅក្នុងគណៈកម្មាធិការគ្រប់គ្រង និងគណៈកម្មាធិការវិនិយោគសំខាន់ៗផងដែរ។

ក្នុងនាមជាសមាជិកស្ថាបនិកម្នាក់របស់ EMIA លោក សារិន មានបទពិសោធន៍យ៉ាងទូលំទូលាយលើវដ្តនៃការវិនិយោគទាំងមូល រួមទាំងការស្វែងរកឱកាសវិនិយោគ ការវាយតម្លៃស្ថានភាពលម្អិត ការរៀបចំរចនាសម្ព័ន្ធ ការអនុវត្តប្រតិបត្តិការអាជីវកម្ម និងការបង្កើតតម្លៃបន្ថែមដោយការវិនិយោគទាំងនោះគ្របដណ្តប់លើវិស័យសេវាកម្មហិរញ្ញវត្ថុ ធានារ៉ាប់រង សេវាថែទាំសុខភាព ព័ស្តុភារ និងកសិឧស្សាហកម្ម។

លោក សារិន ក៏ជាសមាជិកក្រុមប្រឹក្សាភិបាល និងជាទីប្រឹក្សាដ៏សកម្មមួយរូប ដែលត្រូវបានទទួលស្គាល់ចំពោះសមត្ថភាពក្នុងការជំរុញកំណើនយុទ្ធសាស្ត្រ ពង្រឹងអភិបាលកិច្ច និងដឹកនាំធ្វើបរិវត្តកម្មអាជីវកម្ម។ លោកទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធុរកិច្ច (MBA) ពីសាលាធុរកិច្ច NUS Business School ព្រមទាំងទទួលបានសញ្ញាបត្រជំនាញហិរញ្ញវត្ថុកម្រិតខ្ពស់ និងបានបញ្ចប់កម្មវិធីសិក្សាសម្រាប់ថ្នាក់ដឹកនាំប្រតិបត្តិ (Executive Programs) ពីសាកលវិទ្យាល័យ Oxford និងសាកលវិទ្យាល័យ Fudan ផងដែរ។



## លោក ជុំ សុជាតិ អភិបាលឯករាជ្យ

ប្រធានគណៈកម្មាធិការសវនកម្ម

លោក ជុំ សុជាតិ គឺជាប្រធានគណៈកម្មាធិការសវនកម្ម និងជាអ្នកជំនាញដ៏មានបទពិសោធន៍ក្រាស់ក្រែលជាង 20 ឆ្នាំ ក្នុងវិស័យពន្ធដារ សវនកម្ម ការរាយការណ៍ហិរញ្ញវត្ថុ និងសេវាកម្មប្រឹក្សាយោបល់។ លោកនាំមកនូវជំនាញឯកទេសយ៉ាងស៊ីជម្រៅលើផ្នែកច្បាប់ ការអនុលោមតាមបទប្បញ្ញត្តិ ពន្ធដារ និងការត្រួតពិនិត្យសវនកម្ម ដើម្បីគាំទ្រដល់អភិបាលកិច្ច និងការអនុលោមតាមច្បាប់ឱ្យកាន់តែមានភាពរឹងមាំ។

បច្ចុប្បន្ន លោកកំពុងបម្រើការងារជាអ្នកគ្រប់គ្រងផ្នែកពន្ធដារ នៅក្រុមហ៊ុនមេធាវី Rajah & Tann Sok & Heng Law Office ដោយផ្តល់ប្រឹក្សាយោបល់ជូនដល់អតិថិជនជាតិ និងអន្តរជាតិលើការរៀបចំផែនការពន្ធ ការអនុលោមតាមច្បាប់ពន្ធ និងកិច្ចការគតិយុត្តផ្សេងៗ។ មុនពេលកាន់តំណែងនេះ លោកបានកសាងប្រវត្តិការងារយ៉ាងទូលំទូលាយនៅក្រុមហ៊ុន KPMG ទាំងនៅកម្ពុជា និងសហរដ្ឋអាមេរិក មានតួនាទីជាប្រធានគ្រប់គ្រងសវនកម្ម និងក្រោយមកបានបំពេញការងារនៅទីក្រុងញូវយ៉ក ដែលសមិទ្ធផលទាំងនេះធ្វើឱ្យលោកទទួលបានបទពិសោធន៍ផ្នែកសវនកម្ម និងការផ្តល់ប្រឹក្សាកម្រិតអន្តរជាតិ។ លោកបានចាប់ផ្តើមអាជីពដំបូងបង្អស់របស់លោកនៅធនាគារ អេស៊ីលីដា (ACLEDA Bank)។

លោក សុជាតិ គឺជាសវនករសាធារណៈដែលមានការទទួលស្គាល់ជាផ្លូវការ (Certified Public Accountant - CPA) ព្រមទាំងទទួលបានសញ្ញាបត្រផ្នែកគណនេយ្យ និងផ្នែកភាសាអង់គ្លេស ហើយលោកក៏ជាសមាជិកវិជ្ជាជីវៈនៃសមាគមគណនេយ្យករដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិផងដែរ។

## លោក សួន ពិសី អភិបាល

សមាជិកគណៈកម្មាធិការសវនកម្ម



លោក សួន ពិសី គឺជាសមាជិកគណៈកម្មាធិការសវនកម្ម និងជាថ្នាក់ដឹកនាំកម្រិតក្រុមប្រឹក្សាភិបាលដ៏មានសមត្ថភាព និងមានបទពិសោធន៍ជាង ១៦ ឆ្នាំ ក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។ លោកមានជំនាញឯកទេសយ៉ាងស៊ីជម្រៅលើផ្នែកសេវាកម្មហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យឥណទាន យុទ្ធសាស្ត្រអាជីវកម្ម និងការត្រួតពិនិត្យប្រតិបត្តិការ ដើម្បីគាំទ្រដល់អភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានភាពរឹងមាំ។

បច្ចុប្បន្ន លោកកំពុងបម្រើការងារជានាយកប្រតិបត្តិអាជីវកម្ម នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ទទួលបន្ទុកដឹកនាំលើការរៀបចំយុទ្ធសាស្ត្រអាជីវកម្ម ប្រតិបត្តិការឥណទាន និងជំរុញកំណើនអាជីវកម្ម ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ និងសមត្ថភាពប្រកួតប្រជែងរបស់ស្ថាប័ន។ នាពេលកន្លងមក លោកធ្លាប់បានបំពេញការងារជាប្រធានផ្នែកអាជីវកម្មឥណទាន ទទួលបន្ទុកត្រួតពិនិត្យលើការគ្រប់គ្រងផលប័ត្រឥណទាន និងរួមចំណែកដល់ឧត្តមភាពនៃប្រតិបត្តិការអាជីវកម្ម។

លោក ពិសី មានសមត្ថភាពខ្ពស់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ ប្រតិបត្តិការធនាគារ និងការអភិវឌ្ឍសេវាកម្មហិរញ្ញវត្ថុ។ លោកទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធុរកិច្ច (MBA) ឯកទេសហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។



## លោក Robert Trieu អភិបាលឯករាជ្យ
សមាជិកគណៈកម្មាធិការសវនកម្ម

លោក Robert Trieu គឺជាសមាជិកនៃគណៈកម្មាធិការសវនកម្ម និងជាថ្នាក់ដឹកនាំជាន់ខ្ពស់ប្រកបដោយកិត្យានុភាពក្នុងវិស័យធានារ៉ាប់រង ដោយលោកមានប្រវត្តិដឹកនាំដ៏ឆ្នើមជាង 35 ឆ្នាំ នៅទូទាំងតំបន់អាស៊ី និងអាមេរិកខាងជើង។ លោកមានជំនាញឯកទេស និងចក្ខុវិស័យយុទ្ធសាស្ត្រច្បាស់លាស់លើការត្រួតពិនិត្យសវនកម្ម ប្រតិបត្តិការធានារ៉ាប់រង យុទ្ធសាស្ត្របណ្តាញចែកចាយ និងការធ្វើបរិវត្តកម្មអាជីវកម្ម ដើម្បីធានាបាននូវអភិបាលកិច្ចដ៏រឹងមាំ។

លោកធ្លាប់កាន់តួនាទីជាន់ខ្ពស់ជាច្រើននៅតាមបណ្តាក្រុមហ៊ុនធានារ៉ាប់រងលំដាប់ពិភពលោក រួមមាន៖ ក្រុមហ៊ុន Manulife, ក្រុមហ៊ុន RBC Insurance និងក្រុមហ៊ុន MetLife។ ក្នុងនាមជាអតីត នាយកប្រតិបត្តិផ្នែកលក់ នៅក្រុមហ៊ុន មេនូឡាយហ្វ៍ វៀតណាម លោកបានដឹកនាំ និងពង្រីកបណ្តាញទីភ្នាក់ងារដ៏មានសក្តានុពលមួយនៅក្នុងប្រទេស ព្រមទាំងបានលើកកម្ពស់ឧត្តមភាពនៃការជំរុញការអភិវឌ្ឍអាជីវកម្ម និងការរឹតចំណងទំនាក់ទំនងជាយុទ្ធសាស្ត្រជាមួយអតិថិជន។ លើសពីនេះ លោកក៏បានដើរតួនាទីជាថ្នាក់ដឹកនាំយុទ្ធសាស្ត្រ ក្នុងការតម្រង់ទិសដៅប្រតិបត្តិការ និងពង្រីកវិសាលភាពវឌ្ឍនភាពអាជីវកម្ម នៅក្នុងប្រទេសចិន និងកោះតៃវ៉ាន់។

លោក Robert ត្រូវបានទទួលស្គាល់ ចំពោះសមត្ថភាពដឹកនាំក្នុងការកសាងក្រុមការងារប្រកបដោយឧត្តមភាព និងការបង្កើតសមិទ្ធផលកំណើនប្រកបដោយចីរភាព។ លោកទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម (MBA) ពីសាកលវិទ្យាល័យ South Australia (University of South Australia)។

## លោកស្រី Haiming Zhao (Hazel) អភិបាល



លោកស្រី Hazel Zhao គឺជាសមាជិកក្រុមប្រឹក្សាភិបាល។ សព្វថ្ងៃលោកស្រីជា នាយិកាប្រតិបត្តិធុរកិច្ចក្រៅប្រទេសរបស់ក្រុមហ៊ុន ហួតតេ ដែលដឹកនាំការអភិវឌ្ឍអាជីវកម្មអន្តរជាតិ និងការពង្រីកវិសាលភាពយុទ្ធសាស្ត្រក្នុងកម្រិតតំបន់។ លោកស្រីនាំមកនូវបទពិសោធន៍យ៉ាងទូលំទូលាយជាង 35 ឆ្នាំ ទាំងនៅក្នុងវិស័យធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងអាយុជីវិត ព្រមទាំងនៅក្នុងឧស្សាហកម្មនីហរណកម្ម និងអាហរណកម្ម(នាំចេញ-នាំចូល)ដោយគ្របដណ្តប់ទាំងនៅក្នុងប្រទេសកម្ពុជា និងប្រទេសចិន។

ចាប់តាំងពីការចូលរួមជាមួយក្រុមហ៊ុន ហួតតេ នៅក្នុងឆ្នាំ 2003 លោកស្រី បានកាន់តួនាទីជាថ្នាក់ដឹកនាំជាន់ខ្ពស់ជាច្រើន ដោយបានរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើពិពិធកម្មផលប័ត្រពាណិជ្ជកម្មកម្រិតអន្តរជាតិ។ លោកស្រីត្រូវបានទទួលស្គាល់ភាពជាអ្នកដឹកនាំដោយផ្តោតលើការកសាងទំនាក់ទំនងយ៉ាងជិតស្និទ្ធ ព្រមទាំងមានភាពលេចធ្លោក្នុងការបង្កើតកិច្ចសហការជាដៃគូយុទ្ធសាស្ត្រដើម្បីគាំទ្រដល់កំណើនអាជីវកម្មប្រកបដោយចីរភាព។ លោកស្រី Hazel ទទួលបានតំណែងជាអ្នកជំនាញធានារ៉ាប់រងកម្រិត Chartered Insurer និងសញ្ញាបត្រកម្រិតខ្ពស់ផ្នែកធានារ៉ាប់រង Advanced Diploma in Insurance (ACII) ពីចក្រភពអង់គ្លេស ព្រមទាំងសញ្ញាបត្រកម្រិត Associate (AMII) ពីប្រទេសម៉ាឡេស៊ី និងសញ្ញាបត្រជំនាញនានាពីប្រទេសចិនផងដែរ។



## លោក Lee Foo Yeun (Alex) អភិបាល

លោក Alex Lee គឺជាសមាជិកក្រុមប្រឹក្សាភិបាល ដោយលោកបាននាំមកនូវបទពិសោធន៍ដឹកនាំជាង 30 ឆ្នាំ នៅក្នុងវិស័យធានារ៉ាប់រង ការគ្រប់គ្រងទ្រព្យសម្បត្តិ ធនាគារ និងការរៀបចំផែនការហិរញ្ញវត្ថុនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ លោកមានជំនាញឯកទេសខ្ពស់ផ្នែកយុទ្ធសាស្ត្រវិនិយោគ ប្រតិបត្តិការធានារ៉ាប់រង ការគ្រប់គ្រងទ្រព្យសម្បត្តិ និងបណ្តាញចែកចាយ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយជំរុញការសម្រេចចិត្តវិនិយោគ និងវឌ្ឍនភាពអាជីវកម្មប្រកបដោយចីរភាព។

បច្ចុប្បន្ន លោកគឺជាអគ្គនាយក នៃសមាគមរៀបចំផែនការហិរញ្ញវត្ថុនៃប្រទេសម៉ាឡេស៊ី (FPAM) ក្នុងការលើកកម្ពស់ស្តង់ដាឧស្សាហកម្ម និងការអនុវត្តវិជ្ជាជីវៈ។ ប្រវត្តិការងាររបស់លោក រួមមានការកាន់តំណែងជាន់ខ្ពស់នៅក្រុមហ៊ុន ហ្វូតេ ឡាយហ្វ៍, ក្រុមហ៊ុនធានារ៉ាប់រង មេនូឡាយហ្វ៍, ក្រុមហ៊ុនធានារ៉ាប់រង អេ អាយ អេ, ធនាគារ Standard Chartered និងធនាគារ OCBC។ លើសពីនេះ លោកក៏ធ្លាប់បានបម្រើការងារនៅស្ថាប័ន InvestKL ផងដែរ ដោយបានរួមចំណែកយ៉ាងសកម្មក្នុងការទាក់ទាញវិនិយោគពីក្រុមហ៊ុនអន្តរជាតិមកកាន់ប្រទេសម៉ាឡេស៊ី។

លោក Alex ទទួលបានបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ព្រមទាំងមានគុណវុឌ្ឍិវិជ្ជាជីវៈសំខាន់ៗ រួមមាន ChFC, CFP, RFP និង ACII។ លោកត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយចំពោះសមត្ថភាពដឹកនាំ ចក្ខុវិស័យយុទ្ធសាស្ត្រ និងការប្តេជ្ញាចិត្តខ្ពស់ឆ្ពោះទៅរកឧត្តមភាពនៅក្នុងវិស័យសេវាកម្មហិរញ្ញវត្ថុ។

# ប្រវត្តិរូបសង្ខេបថ្នាក់ដឹកនាំ





## លោក ព្រូ ស៊ីថន

អគ្គនាយក

លោក ព្រូ ស៊ីថន គឺជាសមាជិកគណៈកម្មាធិការវិនិយោគ។ សព្វថ្ងៃ លោកជាអគ្គនាយក នៃក្រុមហ៊ុន ហ្វតតេ ឡាយហ្វ៍ ដែលជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតឈានមុខគេមួយនៅកម្ពុជា ព្រមទាំងជាថ្នាក់ដឹកនាំមួយរូបដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងវិស័យធានារ៉ាប់រងប្រចាំតំបន់អាស៊ី។ ដំណើរជីវិតការងាររបស់លោកបានឆ្លុះបញ្ចាំងពីបទពិសោធន៍ដ៏លេចធ្លោ និងសម្បូរបែប ដោយបានឆ្លងកាត់ការបម្រើការងារក្នុងវិស័យរដ្ឋ ច្បាប់ បណ្ដាញចែកចាយអាជីវកម្ម និងថ្នាក់ដឹកនាំប្រតិបត្តិ។ បទពិសោធន៍ការងារដ៏ចម្រុះនេះត្រូវបានសម្រេចដោយភាពធន់ ភាពបត់បែន ការរៀនសូត្រជាបន្តបន្ទាប់ និងការប្ដេជ្ញាចិត្តយ៉ាងមុតមាំក្នុងការបន្តពង្រីកការការពារផ្នែកហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់។

ចាប់តាំងពីឆ្នាំ 2012 មក លោកបានដើរតួនាទីជាអ្នកត្រួសត្រាយផ្លូវនៅក្នុងវិស័យធានារ៉ាប់រងអាយុជីវិតនៅកម្ពុជា ដោយបានចូលរួមចំណែកក្នុងការបង្កើតក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតអន្តរជាតិដំបូងបង្អស់នៅក្នុងប្រទេស ការអភិវឌ្ឍដៃគូធនាគារ ឬ ប៊េងកាស្សួរេន និងការបង្កើតនូវគំរូនៃបណ្ដាញចែកចាយអាជីវកម្មថ្មី។ បន្ទាប់ពីត្រូវបានតែងតាំងជាអគ្គនាយកនៃក្រុមហ៊ុន ហ្វតតេ ឡាយហ្វ៍ នៅក្នុងឆ្នាំ 2023 លោកបាននិងកំពុងដឹកនាំការផ្លាស់ប្ដូរទម្រង់អាជីវកម្មរបស់ក្រុមហ៊ុនឱ្យទៅជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដែលមានចីរភាព និងផ្ដោតលើអតិថិជនជាចម្បង ព្រមទាំងជំរុញកំណើនអាជីវកម្ម និងលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្នតាមរយៈផលិតផលប្រកបដោយនវានុវត្តន៍និងកិច្ចសហការជាដៃគូយុទ្ធសាស្ត្រនានា។

ក្រៅពីតួនាទីជាថ្នាក់ដឹកនាំប្រតិបត្តិ លោក ស៊ីថន តែងតែចូលរួមជាវាគ្មិន សរសេរអត្ថបទ និងរួមចំណែកនៅក្នុងវេទិកាអន្តរជាតិ និងក្នុងតំបន់ឈានមុខគេជាច្រើន រួមមាន OECD–ADBI, Qorus, East Asian Insurance Congress, LAWASIA, Insurance Asia និង International Bar Association។ តាមរយៈការចូលរួម និងតួនាទីជាទីប្រឹក្សាទាំងនេះ លោកបានចែករំលែកនូវទស្សនវិស័យជាក់ស្ដែងស្ដីពីការអភិវឌ្ឍវិស័យធានារ៉ាប់រង បរិយាប័ន្នហិរញ្ញវត្ថុ នវានុវត្តន៍នៃបណ្ដាញចែកចាយអាជីវកម្ម អភិបាលកិច្ច និងកំណើននៃទីផ្សារកំពុងអភិវឌ្ឍ។

លោក ព្រូ ស៊ីថន ទទួលបានសញ្ញាបត្រថ្នាក់អនុបណ្ឌិតចំនួនពីរ ផ្នែកធុរកិច្ចអន្តរជាតិ និងច្បាប់ហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ King’s College London និង Yokohama National University ដែលរូបលោកក៏ត្រូវបានបង្ហាញឈ្មោះនៅក្នុងព្រឹត្តិបត្រព័ត៌មានរបស់អតីតនិស្សិតផងដែរ។ លើសពីនេះ លោកបានបញ្ចប់ការសិក្សាថ្នាក់អប់រំកម្រិតប្រតិបត្តិ (Executive Education) ពីសាលាធុរកិច្ច Ivey Business School និង Melbourne Business School។ ការដឹកនាំដ៏ឆ្នើមរបស់លោកត្រូវបានទទួលស្គាល់តាមរយៈពានរង្វាន់កិត្តិយសជាច្រើន រួមមាន៖ ពានរង្វាន់ថ្នាក់ដឹកនាំវ័យក្មេងឆ្នើមប្រចាំឆ្នាំ (Young Leader of the Year) ពីស្ថាប័ន Asia Insurance Review, ពានរង្វាន់ Asian Legal Business 40 Under 40 ព្រមទាំងគ្រឿងឥស្សរិយយស “មុនីសារាភ័ណ្ឌ” នៃព្រះរាជាណាចក្រកម្ពុជា។



## លោក ហុង ប៊ុនហួ

នាយកប្រតិបត្តិហិរញ្ញវត្ថុ

លោក ហុង ប៊ុនហួ គឺជានាយកប្រតិបត្តិហិរញ្ញវត្ថុ ដែលមានបទពិសោធន៍យ៉ាងក្រាស់ក្រែលជាង 20 ឆ្នាំ នៅក្នុងវិស័យធានារ៉ាប់រង។ លោកដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញសមាហរណកម្មប្រតិបត្តិការ និងពង្រឹងវិន័យផ្នែកហិរញ្ញវត្ថុនៅទូទាំងស្ថាប័នទាំងមូល។

ក្នុងនាមជាថ្នាក់ដឹកនាំដែលមានទស្សនវិស័យកែទម្រង់ និងផ្តោតលើលទ្ធផលនៃការអនុវត្តជាក់ស្តែង លោក ប៊ុនហួ បានកសាងនូវស្នាដៃនិងសមិទ្ធផលការងារយ៉ាងលេចធ្លោ ចាប់តាំងពីការចូលរួមជាមួយក្រុមហ៊ុន ហ្វតតេ នៅក្នុងឆ្នាំ 2006។ លោកបានឆ្លងកាត់ និងកាន់តំណែងដឹកនាំសំខាន់ៗជាបន្តបន្ទាប់ ព្រមទាំងបានដើរតួជាកម្លាំងចលករក្នុងការបង្កើតក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច រហូតក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វតតេ ឡាយហ្វ៍ នៅក្នុងឆ្នាំ 2019។

លោក ប៊ុនហួ ទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធុរកិច្ច (MBA) ពីសាកលវិទ្យាល័យន័រតុន សញ្ញាបត្រថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ព្រមទាំងសញ្ញាបត្រវិជ្ជាជីវៈផ្នែកច្បាប់ពាណិជ្ជកម្មកម្ពុជា និងពន្ធដារពីសាលាធុរកិច្ច CamEd ផងដែរ។ បច្ចុប្បន្ន លោកកំពុងបន្តការសិក្សាយកសញ្ញាបត្រគណនេយ្យករជំនាញអន្តរជាតិ ACCA។



## លោក លឹម លីហួរ

នាយកប្រតិបត្តិអភិវឌ្ឍដៃគូអាជីវកម្មថ្មី និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

លោក លឹម លីហួរ គឺជានាយកប្រតិបត្តិអភិវឌ្ឍដៃគូអាជីវកម្មថ្មី និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅក្រុមហ៊ុន ហ្វតតេ ឡាយហ្វ៍ មានបទពិសោធន៍យ៉ាងក្រាស់ក្រែលជាង 20 ឆ្នាំ លើបណ្តាញចែកចាយអាជីវកម្មក្នុងវិស័យធានារ៉ាប់រងអាយុជីវិត និងឧស្សាហកម្មទំនិញប្រើប្រាស់រហ័ស (FMCG)។ លោកមានប្រវត្តិការងារដ៏លេចធ្លោក្នុងការកសាងបណ្តាញលក់ដែលមានប្រសិទ្ធភាពខ្ពស់ ព្រមទាំងមានជំនាញវិជ្ជាជីវៈយ៉ាងស៊ីជម្រៅលើផ្នែកដៃគូធនាគារ ឬ បេ៉ងកាស្សួរេន កិច្ចសហប្រតិបត្តិការភាពជាដៃគូ និងលទ្ធផលប្រតិបត្តិការអាជីវកម្ម។

លោក លីហួរ ដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំយុទ្ធសាស្ត្រកំណើនរបស់ក្រុមហ៊ុន ហ្វតតេ ឡាយហ្វ៍ តាមរយៈការពង្រីកកិច្ចសហប្រតិបត្តិការភាពជាដៃគូជាមួយដៃគូអាជីវកម្មថ្មី និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ការបើកបង្ហាញផ្នែកអតិថិជនថ្មីៗ ព្រមទាំងការជំរុញល្បឿននៃការជ្រៀតចូលក្នុងទីផ្សារ។ មុនពេលចូលរួមជាមួយក្រុមហ៊ុន ហ្វតតេ ឡាយហ្វ៍ លោកធ្លាប់បានកាន់តំណែងជាថ្នាក់ដឹកនាំជាន់ខ្ពស់នៅក្រុមហ៊ុន AIA Cambodia និងក្រុមហ៊ុន Manulife Cambodia ដែលនៅទីនោះ លោកបានកសាង និងពង្រីកវិសាលភាពនៃគំរូអាជីវកម្មបេ៉ងកាស្សួរេនដ៏ល្អប្រសើរចាប់តាំងពីដំណាក់កាលដំបូង។



## កញ្ញា អ៊ា យ៉េងគាង

### នាយិកាផ្នែកអាជីវកម្មអត្ថប្រយោជន៍ធានារ៉ាប់រងសម្រាប់បុគ្គលិក

កញ្ញា អ៊ា យ៉េងគាង គឺជានាយិកាផ្នែកអាជីវកម្មអត្ថប្រយោជន៍ធានារ៉ាប់រងសម្រាប់បុគ្គលិក នៅក្រុមហ៊ុន ហ្វូតតេ ឡាយហ្វ៍ មានបទពិសោធន៍ជាង 11 ឆ្នាំ នៅក្នុងវិស័យធានារ៉ាប់រងអាយុជីវិត រួមទាំងបទពិសោធន៍ជំនាញឯកទេសចំនួន 8ឆ្នាំ លើផ្នែកអាជីវកម្មសាជីវកម្ម។ កញ្ញាដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនអាជីវកម្មធានារ៉ាប់រងជាក្រុម ព្រមទាំងពង្រឹងវត្តមានរបស់ក្រុមហ៊ុន ហ្វូតតេ ឡាយហ្វ៍ ឱ្យកាន់តែរឹងមាំនៅក្នុងទីផ្សារ។

ចាប់តាំងពីការចូលរួមជាមួយក្រុមហ៊ុន ហ្វូតតេ ឡាយហ្វ៍ នៅក្នុងឆ្នាំ 2019 កញ្ញា យ៉េងគាង បានជំរុញកំណើនធានារ៉ាប់រងអាយុជីវិតជាក្រុមមានកាលកំណត់ និងលើកកម្ពស់បទពិសោធន៍សេវាកម្មជូនដល់អតិថិជននៅទូទាំងបណ្តាក្រុមហ៊ុនសាជីវកម្ម អង្គការមិនមែនរដ្ឋាភិបាល និងដៃគូស្ថាប័ននានា។ កញ្ញាត្រូវបានទទួលស្គាល់ចំពោះសមត្ថភាពក្នុងការកសាងភាពជាដៃគូប្រកបដោយចីរភាព និងការផ្តល់ជូននូវដំណោះស្រាយអត្ថប្រយោជន៍ធានារ៉ាប់រងសម្រាប់បុគ្គលិកដែលឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។

កញ្ញា យ៉េងគាង ទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធុរកិច្ច ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។



## អ្នកនាង រូ វិច្ឆរ៉ា

### នាយិកាផ្នែកគ្រប់គ្រង និងអភិវឌ្ឍន៍ដៃគូធនាគារ

អ្នកនាង រូ វិច្ឆរ៉ា គឺជានាយិកាផ្នែកគ្រប់គ្រង និងអភិវឌ្ឍន៍ដៃគូធនាគារ នៅក្រុមហ៊ុន ហ្វូតតេ ឡាយហ្វ៍ មានបទពិសោធន៍យ៉ាងទូលំទូលាយលើកិច្ចសហប្រតិបត្តិការភាពជាដៃគូធានារ៉ាប់រង និងយុទ្ធសាស្ត្របណ្តាញចែកចាយអាជីវកម្ម។ អ្នកនាងដើរតួនាទីដ៏សំខាន់ក្នុងការជំរុញកំណើនអាជីវកម្មប៊េងកាស្សួរេន តាមរយៈការពង្រឹងសម្ព័ន្ធភាពយុទ្ធសាស្ត្រជាមួយបណ្តាគ្រឹះស្ថានហិរញ្ញវត្ថុ និងការពង្រីកវិសាលភាពនៃសេវាកម្មដល់អតិថិជន។

អ្នកនាង វិច្ឆរ៉ា ត្រូវបានទទួលស្គាល់ចំពោះសមត្ថភាពក្នុងការកសាងក្រុមការងារដែលមានប្រសិទ្ធភាពខ្ពស់ និងមានប្រវត្តិការងារដ៏លេចធ្លោក្នុងការអភិវឌ្ឍបណ្តាញចែកចាយអាជីវកម្មប៊េងកាស្សួរេនចាប់តាំងពីដំណាក់កាលដំបូងបំផុត។ មុនពេលចូលរួមជាមួយក្រុមហ៊ុន ហ្វូតតេ ឡាយហ្វ៍ អ្នកនាងធ្លាប់បានចំណាយពេល 7ឆ្នាំ នៅក្រុមហ៊ុន Manulife ក្នុងការដឹកនាំកិច្ចសហការជាដៃគូជាមួយគ្រឹះស្ថានធំៗ ដូចជា ធនាគារ ANZ Royal Bank និងធនាគារ ABA Bank ដែលសមិទ្ធផលនេះបានជួយឱ្យកញ្ញាទទួលបានពានរង្វាន់ដ៏មានកិត្យានុភាព Star of Excellence Award ផងដែរ។

លើសពីនេះ អ្នកនាងក៏ធ្លាប់បានបំពេញការងារជាទីប្រឹក្សាផ្នែកកំណើនអាជីវកម្ម គ្រូបង្វឹក និងជាគ្រូឧទ្ទេសនាមផងដែរ។

# របាយការណ៍គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្មនៃក្រុមហ៊ុន ហ្វតេ ឡាយហ្វ៍ អ៊ីស្សូរ៉ិនស៍ (ហៅកាត់ថា "គណៈកម្មាធិការ") សូមធ្វើជូននូវរបាយការណ៍ ដែលបានបញ្ចប់ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 ជូនចំពោះម្ចាស់ភាគហ៊ុនទាំងអស់។គណៈកម្មាធិការប្រតិបត្តិការទៅតាមលក្ខន្តិកៈជាផ្លូវការដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល ដែលក្នុងនោះរួមមានការកំណត់អំពីសមាសភាព សិទ្ធិអំណាច ភារកិច្ច និងកាតព្វកិច្ចក្នុងការរាយការណ៍។

## សមាសភាព និងឯករាជ្យភាព

គណៈកម្មាធិការមានសមាសភាពចំនួន 3 (បី) រូប ដែលក្នុងនោះប្រធានគណៈកម្មាធិការ គឺជាអភិបាលឯករាជ្យ ហើយសមាជិកពីររូបទៀត រួមមានមួយរូបជាអភិបាលឯករាជ្យ និងមួយរូបទៀតជាអភិបាលមិនកាន់តំណែងប្រតិបត្តិនៃក្រុមហ៊ុន ក្រុមហ៊ុនមេ ឬក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន។ គណៈកម្មាធិការបានបើកកិច្ចប្រជុំចំនួន 4 លើកក្នុងអំឡុងឆ្នាំ2025។

## ភារកិច្ច និងការទទួលខុសត្រូវ

ក្នុងកំឡុងឆ្នាំកន្លងទៅ គណៈកម្មាធិការបានបំពេញភារកិច្ចចម្បងៗដូចខាងក្រោម៖

- ពិនិត្យ និងអនុម័តលើផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ដើម្បីធានាឱ្យបាននូវការគ្របដណ្តប់លើហានិភ័យសំខាន់ៗនៅគ្រប់ខ្សែសង្វាក់អាជីវកម្ម និងមុខងារទាំងអស់។
- តាមដានប្រសិទ្ធភាពនៃមុខងារសវនកម្មផ្ទៃក្នុង និងពិនិត្យឡើងវិញនូវរាល់របាយការណ៍សវនកម្មផ្ទៃក្នុងដែលបានចេញក្នុងឆ្នាំនេះ។
- ពិនិត្យរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំដែលបញ្ចប់ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 មុននឹងដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត រួមទាំងការពិនិត្យលើការអនុវត្តគោលនយោបាយគណនេយ្យសំខាន់ៗ និងការវាយតម្លៃលើសេចក្តីសម្រេចសំខាន់ៗ។
- ត្រួតពិនិត្យដំណើរការសវនកម្មឯករាជ្យ រួមទាំងការអនុម័តលើលក្ខខណ្ឌការងាររបស់សវនករឯករាជ្យ ផែនការសវនកម្ម និងលទ្ធផលដែលរកឃើញ។
- វាយតម្លៃលើភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន លើការរាយការណ៍ហិរញ្ញវត្ថុ ការអនុលោមតាមច្បាប់ និងប្រតិបត្តិការអាជីវកម្ម។
- ពិនិត្យលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានរបស់ក្រុមហ៊ុន រួមទាំងតម្រូវការនានារបស់និយ័តករធានារ៉ាប់រងកម្ពុជា (ន.ធ.ក.)។

## សវនករឯករាជ្យ

សវនករឯករាជ្យរបស់ក្រុមហ៊ុនសម្រាប់ឆ្នាំ 2025 គឺ ក្រុមហ៊ុន អ៊ីនស្ទ៍ អ៊ែន យ៉ាំង (ខេមបូឌា) លីមីតធីត។ គណៈកម្មាធិការសូមបញ្ជាក់ថា សវនករឯករាជ្យបានរក្សានូវឯករាជ្យភាពរបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួនក្នុងកំឡុងឆ្នាំនេះ។គណៈកម្មាធិការបានរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសវនករឯករាជ្យនៅគ្រប់ដំណាក់កាលនៃសវនកម្ម រួមមានការពិនិត្យលើផែនការសវនកម្ម វិសាលភាព និងបញ្ហាសវនកម្មសំខាន់ៗ ព្រមទាំងការពិភាក្សាលើលទ្ធផល និងអនុសាសន៍នានា។ គណៈកម្មាធិការក៏បានវាយតម្លៃលើឯករាជ្យភាព និងសមត្ថភាពការងាររបស់សវនករឯករាជ្យ ហើយមានការពេញចិត្តដែលសវនករបានរក្សាសុក្រឹតភាពដោយមិនមានការយោគយល់។

គណៈកម្មាធិការមានភាពជឿជាក់ថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលពិតជាបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ និងយុត្តិធម៌នូវស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលសម្រេចបានរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 ។





# របាយការណ៍គណៈកម្មាធិការវិនិយោគ

គណៈកម្មាធិការវិនិយោគ (ហៅកាត់ថា "គណៈកម្មាធិការ") សូមបង្ហាញនូវរបាយការណ៍ ដែលបានបញ្ចប់ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025។ គណៈកម្មាធិការមានភារកិច្ចទទួលខុសត្រូវក្នុងការត្រួតពិនិត្យលើយុទ្ធសាស្ត្រវិនិយោគ ការបែងចែកទ្រព្យសកម្ម លទ្ធផលនៃផលប័ត្រវិនិយោគ និងធានាឱ្យមានសង្គតិភាពស្របតាមគោលនយោបាយវិនិយោគដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងបទប្បញ្ញត្តិរបស់និយ័តករ។

## សមាសភាព និងឯករាជ្យភាព

គណៈកម្មាធិការវិនិយោគ មានសមាសភាពចំនួន 5 (ប្រាំ) រូប ដែលក្នុងនោះប្រធានគណៈកម្មាធិការ គឺជាអភិបាលឯករាជ្យ ហើយសមាជិក 4 (បួន) រូបទៀត រួមមាន៖ អគ្គនាយក អ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង អភិបាលមិនកាន់តំណែងប្រតិបត្តិ និងមន្ត្រីផ្នែកវិនិយោគ។ គណៈកម្មាធិការបានបើកកិច្ចប្រជុំចំនួន 5 លើក ក្នុងអំឡុងឆ្នាំ2025។

## ភារកិច្ច និងការទទួលខុសត្រូវ

គណៈកម្មាធិការវិនិយោគមានតួនាទី និងភារកិច្ចចម្បងៗដូចខាងក្រោម៖

- រៀបចំ និងកំណត់គោលនយោបាយវិនិយោគ ដោយធានាថាការវិនិយោគទាំងនោះមានសុវត្ថិភាព មានសន្ទនីយភាពខ្ពស់ និងមានភាពចម្រុះ។
- រៀបចំផែនការវិនិយោគបន្តបន្ទាប់សម្រាប់រយៈពេល 3 ឆ្នាំ។
- ពិនិត្យ និងតាមដានរាល់សកម្មភាពវិនិយោគរបស់ក្រុមហ៊ុន។
- វាយតម្លៃលើលទ្ធផលនៃការវិនិយោគ។
- គ្រប់គ្រងប្រសិទ្ធភាពនៃការប្រើប្រាស់ទ្រព្យសកម្ម ដើម្បីបំពេញកាតព្វកិច្ចនានារបស់ក្រុមហ៊ុន។
- រាយការណ៍អំពីលទ្ធផលវិនិយោគប្រចាំត្រីមាស និងប្រចាំឆ្នាំជូនក្រុមប្រឹក្សាភិបាល។
- ពិនិត្យឡើងវិញជាទៀងទាត់លើគោលនយោបាយវិនិយោគ និងផ្តល់អនុសាសន៍ក្នុងការកែសម្រួលគោលនយោបាយទាំងនោះ ដើម្បីធានាឱ្យមានការអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

គណៈកម្មាធិការមានការពេញចិត្តចំពោះផលប័ត្រនៃការវិនិយោគ ដែលនៅតែបន្តរក្សាបាននូវជំហរដ៏សមស្របមួយ ធៀបទៅនឹងស្ថានភាពកាតព្វកិច្ចបំណុល និងតម្រូវការផ្នែកបទប្បញ្ញត្តិរបស់ក្រុមហ៊ុន។ នៅក្នុងឆ្នាំ 2025 ផលប័ត្រនៃការវិនិយោគសម្រេចបាននូវប្រាក់ចំណូលសុទ្ធពីការវិនិយោគ និងចំណូលផ្សេងៗចំនួន 0.44 លានដុល្លារអាមេរិកអាមេរិក ដែលគាំទ្រចម្បងដោយចំណូលការប្រាក់ដ៏មានស្ថិរភាព និងយុទ្ធសាស្ត្របែងចែកទ្រព្យសកម្មប្រកបដោយការប្រុងប្រយ័ត្នខ្ពស់។ លទ្ធផលនៃប្រតិបត្តិការនេះគឺស្ថិតក្នុងកម្រិតរំពឹងទុកយ៉ាងទូលំទូលាយ បើទោះបីជាទីផ្សារបន្តមានភាពប្រែប្រួលក៏ដោយដែលនេះបានឆ្លុះបញ្ចាំងពីការកំណត់ជំហរប្រកបដោយភាពហ្មត់ចត់របស់ក្រុមហ៊ុននិងការផ្តោតសំខាន់លើផលត្រឡប់មកវិញធៀបនឹងហានិភ័យ (Risk-adjusted returns) ជាជាងការធ្វើឱ្យផលទុន (Yield) ឡើងដល់កម្រិតអតិបរមា ព្រមទាំងធានាបាននូវការអនុលោមភាពតាមកម្រិតកំណត់ និងគោលការណ៍ណែនាំនៃការវិនិយោគ។

បន្ថែមលើការពិនិត្យតាមដានលទ្ធផលប្រតិបត្តិការជាប្រចាំ គណៈកម្មាធិការបានយកចិត្តទុកដាក់ខ្ពស់ក្នុងការតាមដានស្ថានភាពទីផ្សារ រួមមានការប្រែប្រួលអត្រាការប្រាក់ និងការវិវត្តនៃឥណទាន ព្រមទាំងបានវាយតម្លៃលើផលជះដែលអាចកើតមានចំពោះផលប័ត្ររបស់ក្រុមហ៊ុន។ នៅក្នុងករណីចាំបាច់ ការកែសម្រួលនានាត្រូវបានធ្វើឡើងដើម្បីរក្សាឱ្យស្របទៅនឹងស្ថានភាពហានិភ័យរបស់ក្រុមហ៊ុន និងដើម្បីការពារទុនវិនិយោគឱ្យមានសុវត្ថិភាព។

# អភិបាលកិច្ចសាជីវកម្ម

របាយការណ៍ប្រចាំឆ្នាំរបស់ ក្រុមហ៊ុន ហ្វតតេ ឡាយហ្វ៍ អឺស្សួរ៉ិនស៍ (ខេមបូឌា) ម.ក (ហៅកាត់ថា «ក្រុមហ៊ុន») ត្រូវបានរៀបចំឡើងស្របតាមក្របខ័ណ្ឌរបាយការណ៍នៃច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា រួមមាន ច្បាប់ស្តីពីការធានារ៉ាប់រង ព្រមទាំងប្រកាស សារាចរ និងសេចក្តីណែនាំពាក់ព័ន្ធនានា ដែលចេញដោយនិយ័តករធានារ៉ាប់រងកម្ពុជា (ន.ធ.ក.)។

ក្រុមហ៊ុនទទួលស្គាល់យ៉ាងច្បាស់ថា ប្រព័ន្ធអភិបាលកិច្ចសាជីវកម្មដ៏ល្អប្រសើរ និងក្របខ័ណ្ឌសីលធម៌ការងារដ៏រឹងមាំ គឺជាកត្តាចាំបាច់មិនអាចខ្វះបានក្នុងការការពារផលប្រយោជន៍របស់ម្ចាស់បណ្ណសន្យារ៉ាប់រង ការរក្សាបាននូវទំនុកចិត្តលើទីផ្សារ និងការធានាឱ្យបាននូវចីរភាពរយៈពេលវែងនៃវិស័យធានារ៉ាប់រង។ ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ បានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការធានាថា ប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុនត្រូវអនុវត្តស្របតាមតម្រូវការច្បាប់ និងបទប្បញ្ញត្តិទាំងស្រុង ព្រមទាំងប្រកាន់ខ្ជាប់នូវស្តង់ដាខ្ពស់បំផុតនៃភាពស្មោះត្រង់ តម្លាភាព គណនេយ្យភាព និងលក្ខណៈវិជ្ជាជីវៈ។

រចនាសម្ព័ន្ធអភិបាលកិច្ចរបស់ក្រុមហ៊ុន ត្រូវបានបង្កើតឡើងស្របតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន គោលការណ៍អភិបាលកិច្ចផ្ទៃក្នុងនិងបទប្បញ្ញត្តិជាធរមានរបស់ន.ធ.ក.។ក្រុមប្រឹក្សាភិបាលរក្សាបាននូវការទទួលខុសត្រូវជារួមលើប្រព័ន្ធអភិបាលកិច្ចរបស់ក្រុមហ៊ុន រួមមាន ការកំណត់ទិសដៅយុទ្ធសាស្ត្រ ការអនុម័ត លើកម្រិតហានិភ័យដែលអាចទទួលយកបាន ការត្រួតពិនិត្យលើលទ្ធផលហិរញ្ញវត្ថុ និងការធានាឱ្យមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការអនុលោមភាពប្រកបដោយប្រសិទ្ធភាព។

ស្របតាមតម្រូវការរបស់ ន.ធ.ក. ក្រុមប្រឹក្សាភិបាលបានរៀបចំយន្តការអភិបាលកិច្ចសមស្រប ដោយក្នុងនោះរួមមានការបង្កើតគណៈកម្មាធិការនានានៅក្រោមក្រុមប្រឹក្សាភិបាល ដូចជា គណៈកម្មាធិការសវនកម្ម និងហានិភ័យ ដើម្បីជួយគាំទ្រដល់ការត្រួតពិនិត្យឱ្យកាន់តែមានប្រសិទ្ធភាពលើរបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងមុខងារអនុលោមភាព។ គណៈកម្មាធិការទាំងនេះដំណើរការការងាររបស់ខ្លួនក្រោមលក្ខខណ្ឌប្រតិបត្តិ(Charters)ដែលបានអនុម័តជាផ្លូវការ និងធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាភិបាលជាទៀងទាត់។

គណៈគ្រប់គ្រងជាន់ខ្ពស់ មានភារកិច្ចទទួលខុសត្រូវលើការដឹកនាំប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុន និងការអនុវត្តយុទ្ធសាស្ត្រ ព្រមទាំងគោលការណ៍នានាដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ ក្រុមហ៊ុនបានកំណត់ខ្សែបន្ទាត់នៃការទទួលខុសត្រូវ និងគណនេយ្យភាពយ៉ាងច្បាស់លាស់ ដើម្បីធានាបាននូវការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងប្រតិបត្តិការយ៉ាងម៉ឺងម៉ាត់។



# ដើមទុន និង សាធនភាព

យោងតាមច្បាប់ស្ដីពីការធានារ៉ាប់រង និងប្រកាសពាក់ព័ន្ធនានាដែលចេញដោយនិយ័តករធានារ៉ាប់រងកម្ពុជា (ន.ធ.ក.) ក្រុមហ៊ុនត្រូវបានតម្រូវឱ្យរក្សានូវកម្រិតអប្បបរមានៃដើមទុនចុះបញ្ជីដែលបានបង់រួច និងកម្រិតសាធនភាពឱ្យបានគ្រប់គ្រាន់ ដើម្បីធានាបាននូវសមត្ថភាពក្នុងការបំពេញកាតព្វកិច្ចជូនដល់ម្ចាស់បណ្ណសន្យារ៉ាប់រង និងម្ចាស់បំណុលផ្សេងៗគ្រប់ពេលវេលា។

## លក្ខខណ្ឌតម្រូវនៃដើមទុនអប្បបរមា

កាលពីថ្ងៃទី 14 ខែធ្នូ ឆ្នាំ 2022 និយ័តករធានារ៉ាប់រងកម្ពុជា (ន.ធ.ក. / IRC) បានចេញប្រកាសលេខ 061 ស្ដីពីកម្រិតសាធនភាព ដែលបានណែនាំនូវវិធីសាស្ត្រថ្មីសម្រាប់គណនាតម្រូវការកម្រិតសាធនភាព ដោយផ្អែកលើប្រាក់បម្រុងគណិតវិទ្យាសុទ្ធ (Net Mathematical Reserve - "NMR") និងចំនួនប្រឈមនឹងហានិភ័យសុទ្ធ (Net Sum at Risk - "NSAR") ដោយកំណត់ទំហំអប្បបរមាត្រឹម 50% នៃដើមទុនអប្បបរមា ចំនួន 7.0 លានដុល្លារសហរដ្ឋអាមេរិក ឬស្មើនឹង 3.5 លានដុល្លារសហរដ្ឋអាមេរិក។

កម្រិតសាធនភាពអប្បបរមាត្រូវបានកំណត់ក្នុងកម្រិត 120% ដែលត្រូវបានគណនាជាផលធៀបរវាងទ្រព្យសកម្មសុទ្ធ ធៀបនឹងតម្រូវការកម្រិតសាធនភាព ដូចដែលបានកំណត់ដោយ ន.ធ.ក.។ ទ្រព្យសកម្មសុទ្ធ គឺជាទ្រព្យសកម្មសរុបដកនឹងបំណុលសរុប និងទ្រព្យសកម្មដទៃទៀតដែលមិនត្រូវបានអនុញ្ញាត។ គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 មូលនិធិភាគហ៊ុនិករសរុបរបស់ក្រុមហ៊ុនមានចំនួន USD 7,283,905 ដែលឆ្លើយតបបានយ៉ាងពេញលេញ និងលើសពីតម្រូវការអប្បបរមានៃបទប្បញ្ញត្តិជាធរមាន។

## កម្រិតសាធនភាព

និយ័តករធានារ៉ាប់រងកម្ពុជា (ន.ធ.ក. / IRC) តម្រូវឱ្យក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដែលទទួលបានអាជ្ញាប័ណ្ណទាំងអស់ រក្សាឱ្យបាននូវកម្រិតសាធនភាពអប្បបរមាជាប្រចាំ។ កម្រិតសាធនភាពនេះ គឺជាទំហំលើសនៃតម្លៃទ្រព្យសកម្មដែលត្រូវបានអនុញ្ញាតធៀបនឹងតម្លៃនៃកាតព្វកិច្ចបំណុល ហើយវាដើរតួជាសូចនាករគន្លឹះក្នុងការបង្ហាញពីភាពរឹងមាំផ្នែកហិរញ្ញវត្ថុ ក៏ដូចជាសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចដោះស្រាយសំណងធានារ៉ាប់រង។

គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 ស្ថានភាពកម្រិតសាធនភាពរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | 2024 (%) | 2025 (%) |
|---|---|---|
| កម្រិតសាធនភាពជាក់ស្ដែង (Actual) | 187% | 192% |
| កម្រិតសាធនភាពអប្បបរមាកំណត់ដោយ ន.ធ.ក. | 120% | 120% |

អនុបាតកម្រិតសាធនភាពរបស់ក្រុមហ៊ុនចំនួន 192% គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 នេះ គឺមានទំហំលើសពីកម្រិតអប្បបរមាដែលបានកំណត់ដោយ ន.ធ.ក. រហូតដល់ 72% ដែលឆ្លុះបញ្ចាំងឱ្យឃើញពីការគ្រប់គ្រងដើមទុនដ៏រឹងមាំ និងភាពធន់ផ្នែកហិរញ្ញវត្ថុជាបន្តបន្ទាប់របស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលសូមបញ្ជាក់អះអាងថា ក្រុមហ៊ុនបានអនុវត្តតាមគ្រប់លក្ខខណ្ឌតម្រូវទាំងអស់របស់ ន.ធ.ក. ពាក់ព័ន្ធនឹងដើមទុនអប្បបរមា និងកម្រិតសាធនភាពយ៉ាងពេញលេញស្របច្បាប់ ពេញមួយឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់កាលពីថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025។ ក្រុមហ៊ុនតែងតែរក្សាបាននូវទុនបម្រុងការពារសមស្របមួយ (Capital buffers) នៅពីលើកម្រិតកំណត់នៃបទប្បញ្ញត្តិជាធរមាននៅគ្រប់ពេលវេលាទាំងអស់ក្នុងអំឡុងពេលរបាយការណ៍នេះ។

ស្ថានភាពភាពគ្រប់គ្រាន់នៃដើមទុនរបស់ក្រុមហ៊ុន ត្រូវបានត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំដោយគណៈគ្រប់គ្រង ព្រមទាំងរាយការណ៍ជូនក្រុមប្រឹក្សាភិបាល។ នៅក្នុងករណីចាំបាច់ វិធានការគ្រប់គ្រងដើមទុននឹងត្រូវចាត់ចែងជាមុនប្រកបដោយភាពសកម្ម ដើម្បីធានាបាននូវអនុលោមភាពជាបន្តបន្ទាប់ ក៏ដូចជាដើម្បីគាំទ្រដល់ការរីកចម្រើន និងសកម្មភាពការវាយតម្លៃហានិភ័យកំណត់បុព្វលាភធានារ៉ាប់រង (Underwriting) របស់ក្រុមហ៊ុនជាលំដាប់។

# ព័ត៌មានអំពីការវិនិយោគ

## យុទ្ធសាស្ត្រនៃការវិនិយោគ

ផ្នែកនេះបង្ហាញព័ត៌មានលម្អិតអំពីទ្រព្យសកម្មវិនិយោគរបស់ក្រុមហ៊ុនធានារ៉ាប់រង ហ្វតេ គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 ស្របតាមតម្រូវការរបស់និយ័តករធានារ៉ាប់រងកម្ពុជា (ន.ធ.ក.) និងស្តង់ដារាយការណ៍ហិរញ្ញវត្ថុជាធរមាន។

យុទ្ធសាស្ត្រវិនិយោគរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើងដើម្បីគាំទ្រដល់កាតព្វកិច្ចស្នូលផ្នែកធានារ៉ាប់រងរបស់ក្រុមហ៊ុនព្រមទាំងបង្កើតឱ្យមានផលទុនប្រកបដោយស្ថិរភាព និងចីរភាពសម្រាប់ម្ចាស់ភាគហ៊ុន។ យុទ្ធសាស្ត្រនេះត្រូវបានគ្រប់គ្រងដោយគោលនយោបាយវិនិយោគដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ដែលបានកំណត់នូវគោលការណ៍ ដែនកំណត់នៃការបែងចែកទ្រព្យសកម្ម ប្រភេទទ្រព្យសកម្មដែលអាចវិនិយោគបាន និងក្របខ័ណ្ឌហានិភ័យក្នុងការគ្រប់គ្រងផលប័ត្រនៃការវិនិយោគ។

ការបែងចែកទ្រព្យសកម្មជាយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 មានដូចខាងក្រោម៖

| **ប្រភេទទ្រព្យសកម្ម** | **ការបែងចែកជាក់ស្តែង** |
|---|---|
| ប្រាក់បញ្ញើនៅធនាគារ | 80% |
| សាច់ប្រាក់ក្នុងដៃ និងនៅធនាគារ | 13% |
| ប្រាក់តម្កល់តាមកាតព្វកិច្ចច្បាប់ | 7% |
| **សរុប** | **100%** |

រាល់ការបែងចែកប្រភេទទ្រព្យសកម្មទាំងអស់ គឺស្ថិតនៅក្នុងដែនកំណត់ដែលបានកំណត់ដោយ ន.ធ.ក. ពេញមួយឆ្នាំនៃរបាយការណ៍នេះ។

## ហានិភ័យប្រឈមក្នុងការវិនិយោគ

ផលប័ត្រវិនិយោគរបស់ក្រុមហ៊ុនទទួលរងនូវហានិភ័យទីផ្សារ ដែលរួមមានហានិភ័យអត្រាការប្រាក់ ហានិភ័យរូបិយប័ណ្ណបរទេស និងហានិភ័យឥណទាន ដែលកើតចេញពីបម្រែបម្រួលអត្រាទីផ្សារ ចលនាអត្រាប្តូរប្រាក់ និងលទ្ធភាពនៃការខកខានមិនបានបំពេញកាតព្វកិច្ច ឬការធ្លាក់ចុះស្ថានភាពឥណទានរបស់អ្នកបោះផ្សាយ និងដៃគូកិច្ចសន្យា។ ចំណូលវិនិយោគ និងតម្លៃទ្រព្យសកម្ម គឺមានភាពឆាប់រហ័ស (ងាយរងឥទ្ធិពល) ទៅនឹងការប្រែប្រួលនៃបរិយាកាសអត្រាការប្រាក់ ខណៈពេលដែលហានិភ័យឥណទានត្រូវបានគ្រប់គ្រងតាមរយៈការធ្វើពិពិធកម្មផលប័ត្រ និងការអនុវត្តស្តង់ដាគុណភាពឥណទានអប្បបរមារបស់ដៃគូកិច្ចសន្យា។ បន្ថែមលើនេះ ក្រុមហ៊ុនក៏ទទួលរងនូវហានិភ័យសន្ទនីយភាពផងដែរដែលត្រូវបានគ្រប់គ្រងដោយការរក្សាទុកនូវផលប័ត្រទ្រព្យសកម្មសន្ទនីយភាពឱ្យមានតុល្យភាពសមស្របទៅនឹងទម្រង់ឥណប្រតិទាននៃបំណុលធានារ៉ាប់រងរបស់ខ្លួន ដើម្បីធានាថា កាតព្វកិច្ចចំពោះម្ចាស់បណ្ណសន្យាធានារ៉ាប់រងអាចត្រូវបានបំពេញនៅពេលដល់កំណត់។ ហានិភ័យទាំងនេះ ស្ថិតនៅក្រោមការតាមដាន និងការគ្រប់គ្រងជាប្រចាំ ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាល។

## ផែនការវិនិយោគ 3 ឆ្នាំរំកិល 2026 – 2028

ទ្រព្យសកម្មរបស់ក្រុមហ៊ុនត្រូវបានបែងចែកទៅតាមខ្សែអាជីវកម្មនីមួយៗ ដើម្បីពង្រឹង និងគាំទ្រដល់បំណុល ព្រមទាំងដើម្បីរៀបចំយុទ្ធសាស្ត្រវិនិយោគសម្រាប់ផ្នែករៀងៗខ្លួន។ យុទ្ធសាស្ត្រវិនិយោគរបស់ក្រុមហ៊ុនគឺផ្អែកលើគោលនយោបាយវិនិយោគតាមប្រភេទទ្រព្យសកម្ម ការព្យាករណ៍អត្រាទីផ្សារសម្រាប់ការវិនិយោគដែលមានចំណូលថេរ និងការប៉ាន់ប្រមាណសម្រាប់ទ្រព្យសកម្មរយៈពេលវែងផ្សេងទៀត។ លំហូរសាច់ប្រាក់ដែលបានប៉ាន់ប្រមាណពីទ្រព្យសកម្មទាំងនេះ រួមបញ្ចូលទាំងលំហូរសាច់ប្រាក់ដែលបានព្យាករណ៍ពីការទិញ ឬការលក់ទ្រព្យសកម្មនាពេលអនាគត ព្រមទាំងអត្រាផលត្រឡប់ដែលរំពឹងទុកលើការវិនិយោគទាំងនោះ។

ដើម្បីកាត់បន្ថយហានិភ័យសន្ទនីយភាពក្រុមហ៊ុនបន្តធ្វើឱ្យអាជីវកម្មនិងការវិនិយោគរបស់ខ្លួនមានលក្ខណៈសម្បូរបែបស្របតាមមាត្រា 4 នៃប្រកាសស្តីពីការវិនិយោគដែលត្រូវបានអនុញ្ញាតសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង។

# ប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង

## ទិដ្ឋភាពទូទៅនៃប្រាក់បម្រុងបច្ចេកទេស

ប្រាក់បម្រុងបច្ចេកទេស គឺជាបំណុលដែលក្រុមហ៊ុនបានត្រៀមទុកដោយឡែក ដើម្បីបំពេញកាតព្វកិច្ចបច្ចុប្បន្ន និងអនាគតជូនដល់ម្ចាស់បណ្ណសន្យារ៉ាប់រង និងអ្នកទាមទារសំណង។ ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដែលមានអាជ្ញាបណ្ណ ហ្វតេ ឡាយហ្វ៍ បានរក្សានូវប្រភេទប្រាក់បម្រុងបច្ចេកទេសស្របតាមបទប្បញ្ញត្តិរបស់ ន.ធ.ក. ដូចខាងក្រោម៖

- **ប្រាក់បម្រុងបុព្វលាភធានារ៉ាប់រងមិនទាន់ទទួលបាន (UPR)៖** គឺជាផ្នែកនៃបុព្វលាភដែលបានសរសេររួច ដែលពាក់ព័ន្ធនឹងរយៈពេលហានិភ័យមិនទាន់ផុតកំណត់ គិតត្រឹមថ្ងៃរាយការណ៍។
- **សំណងដែលបានរាយការណ៍តែមិនទាន់ទូទាត់ (RBNS)៖** គឺជាការត្រៀមទុកសម្រាប់សំណងដែលត្រូវបានរាយការណ៍រួចរាល់ ប៉ុន្តែមិនទាន់បានដោះស្រាយបញ្ចប់ទាំងស្រុង គិតត្រឹមថ្ងៃរាយការណ៍។
- **សំណងដែលកើតឡើងតែមិនទាន់បានរាយការណ៍ (IBNR)៖** គឺជាការប៉ាន់ប្រមាណតាមបែបវិទ្យាសាស្ត្រគណនាធានារ៉ាប់រង (Actuarial) លើសំណងដែលបានកើតឡើងមុនថ្ងៃរាយការណ៍ ប៉ុន្តែមិនទាន់បានរាយការណ៍មកកាន់ក្រុមហ៊ុន។
- **ប្រាក់បម្រុងហានិភ័យមិនទាន់ផុតកំណត់ (URR)៖** គឺជាប្រាក់បម្រុងបន្ថែមដែលត្រូវបានបង្កើតឡើង នៅពេលដែល UPR មិនគ្រប់គ្រាន់ដើម្បីគ្របដណ្តប់លើការរំពឹងទុកនៃសំណង និងចំណាយនាពេលអនាគតលើបណ្ណសន្យារ៉ាប់រងដែលកំពុងមានសុពលភាព។

## បម្រែបម្រួលនៃប្រាក់បម្រុងបច្ចេកទេស

ប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង តំណាងឱ្យកាតព្វកិច្ចប៉ាន់ស្មានរបស់ក្រុមហ៊ុនចំពោះម្ចាស់បណ្ណសន្យារ៉ាប់រង ពាក់ព័ន្ធនឹងសំណងធានារ៉ាប់រងដែលបានកើតឡើង និងបុព្វលាភធានារ៉ាប់រងដែលបានកត់ត្រាប៉ុន្តែមិនទាន់ទទួលបាន (Premiums written but not yet earned) ហើយក៏ជាកត្តារាយតម្លៃដ៏សំខាន់មួយនៃភាពគ្រប់គ្រាន់នៃតារាងតុល្យការរបស់ក្រុមហ៊ុន ក្នុងការឆ្លើយតបទៅនឹងបំណុលធានារ៉ាប់រងរបស់ខ្លួន។ប្រាក់បម្រុងទាំងនេះត្រូវបានកំណត់ឡើងស្របតាមស្តង់ដារអ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង (Actuarial standards) និងលក្ខខណ្ឌតម្រូវផ្នែកបទប្បញ្ញត្តិជាធរមាន ដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មានដ៏ល្អបំផុតរបស់គណៈគ្រប់គ្រងលើលំហូរចេញនៃសំណងធានារ៉ាប់រងនាពេលអនាគត រួមជាមួយទុនបម្រុងការពារសមស្របសម្រាប់ហានិភ័យលម្អៀង (Margin for adverse deviation)។

ក្នុងអំឡុងឆ្នាំនេះ បម្រែបម្រួលនៃប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង គឺត្រូវបានរុញច្រានដោយកំណើននៃបុព្វលាភធានារ៉ាប់រងសុទ្ធដែលបានកត់ត្រា បទពិសោធន៍សំណងធានារ៉ាប់រងនៅទូទាំងខ្សែអាជីវកម្មសំខាន់ៗ និងការពិនិត្យឡើងវិញជាទៀងទាត់របស់លក្ខខណ្ឌចែងនៃប្រាក់បម្រុងសំណងធានារ៉ាប់រងដែលមិនទាន់ដោះស្រាយ (Outstanding claims provisions) ដោយអ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង។

គោលការណ៍កំណត់ប្រាក់បម្រុងរបស់ក្រុមហ៊ុននៅតែបន្តរក្សាភាពហ្មត់ចត់ និងប្រុងប្រយ័ត្នខ្ពស់ ដោយមានការពិនិត្យឡើងវិញលើភាពគ្រប់គ្រាន់នៃប្រាក់បម្រុងជាប្រចាំពីសំណាក់អ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រងដែលបានតែងតាំង។

ប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រងសុទ្ធ គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 មានចំនួន 4,330,832 ដុល្លារសហរដ្ឋអាមេរិក ដែលតំណាងឱ្យកំណើនស្មើនឹង 53% បើធៀបទៅនឹងចំនួន 2,828,245 ដុល្លារសហរដ្ឋអាមេរិក គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2024។ ចំពោះការវិភាគលម្អិតអំពីបម្រែបម្រួលនៃប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង សម្រាប់ឆ្នាំហិរញ្ញវត្ថុបច្ចុប្បន្ន និងឆ្នាំមុន ត្រូវបានបង្ហាញជូននៅក្នុងកំណត់សម្គាល់ទី 16 នៃរបាយការណ៍ហិរញ្ញវត្ថុដែលបានសវនកម្មរួច។

## មតិយោបល់របស់អ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង

ស្របតាមលក្ខខណ្ឌតម្រូវរបស់និយ័តករធានារ៉ាប់រងកម្ពុជា (ន.ធ.ក. / IRC) ក្រុមហ៊ុនបានតែងតាំងលោក Nicholas Yeo មកពីក្រុមហ៊ុន Actomate ដែលជាក្រុមហ៊ុនជំនាញគណនាបុព្វលាភធានារ៉ាប់រងឯករាជ្យ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីធ្វើការវាយតម្លៃផ្នែកគណនាបុព្វលាភធានារ៉ាប់រងលើប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រងរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025។ អ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រងដែលបានតែងតាំងរូបនេះ មានសមត្ថភាព និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសមាជិកជាន់ខ្ពស់ថ្នាក់ Fellow នៃវិទ្យាស្ថាន និងមហាវិទ្យាល័យអ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង (Fellow of the Institute and Faculty of Actuaries - FIA) ព្រមទាំងមានភាពឯករាជ្យ ដាច់ដោយឡែកពីគណៈគ្រប់គ្រងរបស់ក្រុមហ៊ុន។

### វិសាលភាពនៃការពិនិត្យឡើងវិញផ្នែកគណនាធានារ៉ាប់រង

ការងារនេះត្រូវបានអនុវត្តស្របតាមប្រកាសស្តីពីវិធីសាស្ត្រកំណត់ប្រាក់បម្រុងបច្ចេកទេសសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង (មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី 23 ខែធ្នូ ឆ្នាំ 2022)។

វិសាលភាពនៃការពិនិត្យនេះ បានគ្របដណ្តប់លើកាតព្វកិច្ចបំណុលពីរប្រភេទ លើគ្រប់ប្រភេទអាជីវកម្ម៖

- **កាតព្វកិច្ចបំណុលផ្នែកសំណង (Claim Liabilities)៖** រួមមាន ប្រាក់បម្រុងសម្រាប់សំណងដែលបានរាយការណ៍តែមិនទាន់ទូទាត់ (Case Reserves) ប្រាក់បម្រុង IBNR និងចំណាយប្រយោលលើការចាត់ចែងសំណង (ICHE) ដោយគិតទាំងលើមូលដ្ឋានមុនដកការធានារ៉ាប់រងបន្ត ( Gross) និងក្រោយដកការធានារ៉ាប់រងបន្ត (Net)។

- **កាតព្វកិច្ចបំណុលផ្នែកបុព្វលាភ (Premium Liabilities)៖** រួមមាន ប្រាក់បម្រុងហានិភ័យមិនទាន់ផុតកំណត់ (URR) និងការវាយតម្លៃថាតើត្រូវទាមទារឱ្យមានប្រាក់បម្រុងកង្វះខាតបុព្វលាភ (PDR) ដែរឬទេ។ លើសពីនេះ ការវិភាគកម្រិតនៃភាពងាយរងឥទ្ធិពល (Sensitivity Analyses) លើលទ្ធផលទាំងនេះ ក៏ត្រូវបានអនុវត្តផងដែរ។

## សេចក្តីថ្លែងការណ៍របស់អ្នកជំនាញគណនាធានារ៉ាប់រង

ផ្អែកលើការវាយតម្លៃផ្នែកគណនាបុព្វលាភធានារ៉ាប់រងដែលបានធ្វើឡើង គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 លោក Nicholas Yeo ដែលជាសមាជិកជាន់ខ្ពស់ថ្នាក់ Fellow (FIA) បានបង្ហាញការពេញចិត្តចំពោះសម្មតិកម្មទាំងឡាយ ដែលមានលក្ខណៈសមស្របសម្រាប់ការវាយតម្លៃកាតព្វកិច្ចបំណុល។ តាមទស្សនៈជំនាញរបស់លោក ប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 គឺមានទំហំគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងកាតព្វកិច្ចធានារ៉ាប់រងរបស់ក្រុមហ៊ុន ព្រមទាំងអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនានារបស់និយ័តករធានារ៉ាប់រងកម្ពុជា។

ក្រុមប្រឹក្សាភិបាលនិងគណៈគ្រប់គ្រងរបស់ក្រុមហ៊ុនបានពិនិត្យឡើងវិញនូវរបាយការណ៍វាយតម្លៃផ្នែកគណនាបុព្វលាភធានារ៉ាប់រងនេះ ហើយមានការពេញចិត្តជាខ្លាំងដោយប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រងដែលបានអនុវត្ត គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 មានទំហំគ្រប់គ្រាន់ និងត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវស្របតាមការពិតនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ជាងនេះទៅទៀត ការអនុវត្តការកំណត់ប្រាក់បម្រុងរបស់ក្រុមហ៊ុន គឺមានភាពរលូនស្របគ្នាយ៉ាងខ្ជាប់ខ្ជួនទៅនឹងលក្ខខណ្ឌតម្រូវផ្នែកបទប្បញ្ញត្តិរបស់ ន.ធ.ក. ក៏ដូចជាស្តង់ដាអ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រងដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។

ក្រុមហ៊ុននឹងបន្តស្វែងរកសេវាកម្មពីក្រុមហ៊ុនជំនាញគណនាបុព្វលាភធានារ៉ាប់រងឯករាជ្យជាលក្ខណៈប្រចាំឆ្នាំ ព្រមទាំងបន្តតាមដានយ៉ាងដិតដល់លើបទពិសោធន៍នៃបម្រែបម្រួលសំណងធានារ៉ាប់រងជាលក្ខណៈប្រចាំត្រីមាស ដើម្បីធានាឱ្យបានថាប្រាក់បម្រុងទាំងនោះបន្តស្ថិតក្នុងកម្រិតមួយដ៏សមស្របបំផុតនៅគ្រប់ពេលវេលា។



# លទ្ធផលអំពីប្រតិបត្តិការអាជីវកម្ម

ក្រុមហ៊ុនសម្រេចបាននូវលទ្ធផលអំពីប្រតិបត្តិការអាជីវកម្មយ៉ាងរឹងមាំ សម្រាប់ឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់កាលពីថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 ដោយទទួលបានបុព្វលាភធានារ៉ាប់រងដុលចំនួន **5.3 លានដុល្លារសហរដ្ឋអាមេរិក** ព្រមទាំងសម្រេចបាននូវលទ្ធផលការវាយតម្លៃហានិភ័យកំណត់បុព្វលាភធានារ៉ាប់រងដែលមានប្រាក់ចំណេញ តាមរយៈការកំណត់ថ្លៃផលិតផលប្រកបដោយវិន័យ ការគ្រប់គ្រងសំណងធានារ៉ាប់រងប្រកបដោយប្រសិទ្ធភាព និងកំណើននៃការធ្វើពិពិធកម្មផលប័ត្រអាជីវកម្មជាលំដាប់។ លទ្ធផលទាំងនេះបានឆ្លុះបញ្ចាំងពីការផ្តោតយកចិត្តទុកដាក់ជាបន្តបន្ទាប់របស់ក្រុមហ៊ុនលើកំណើនប្រកបដោយចិរភាព ផលចំណេញផ្នែកបច្ចេកទេសធានារ៉ាប់រង និងប្រសិទ្ធភាពប្រតិបត្តិការនៅគ្រប់ខ្សែអាជីវកម្មចម្បងៗទាំងអស់។

## លទ្ធផលប្រតិបត្តិការធានារ៉ាប់រងតាមប្រភេទអាជីវកម្ម

បុព្វលាភធានារ៉ាប់រងដុលសរុបសម្រាប់ឆ្នាំនេះ មានចំនួន **5.3 លានដុល្លារសហរដ្ឋអាមេរិក** ដែលតំណាងឱ្យកំណើន **12%** បើធៀបនឹងឆ្នាំមុន (ឆ្នាំ 2024៖ មានចំនួន **4.7 លានដុល្លារសហរដ្ឋអាមេរិក)**។ កំណើននេះត្រូវបានរុញច្រានជាចម្បងដោយការពង្រីកវិសាលភាពអាជីវកម្មលើផលិតផលអាយុជីវិតមានកាលកំណត់ជាក្រុម (Group Term Life) និងអាយុជីវិតការពារកម្ចី (Group Credit Life)។




## សំណងធានារ៉ាប់រងសុទ្ធដែលបានកើតឡើង

ក្រុមហ៊ុនបានបន្តរក្សានូវវិន័យយ៉ាងម៉ត់ចត់ក្នុងការគ្រប់គ្រងសំណងធានារ៉ាប់រងក្នុងឆ្នាំនេះ។ សំណងធានារ៉ាប់រងសុទ្ធកើតឡើងសរុបបានកើនឡើង 48% ដល់ចំនួន 2,278,888 ដុល្លារសហរដ្ឋអាមេរិក ពីចំនួន 1,531,732 ដុល្លារសហរដ្ឋអាមេរិក កាលពីឆ្នាំមុន ដែលជាចម្បងបណ្តាលមកពីការកើនឡើងនៃប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង។ ដោយឡែក សំណងដែលបានទូទាត់សរុបបានធ្លាក់ចុះមកនៅត្រឹមប្រមាណ 1.6 លានដុល្លារសហរដ្ឋអាមេរិក បើធៀបនឹងចំនួន 2.5 លានដុល្លារសហរដ្ឋអាមេរិក កាលពីឆ្នាំមុន។

ជារួម សមត្ថភាពរបស់ក្រុមហ៊ុនក្នុងការរក្សាកំណើនសំណងធានារ៉ាប់រងសុទ្ធឱ្យស្ថិតក្រោមការគ្រប់គ្រង ទោះបីជាមានការពង្រីកវិសាលភាពផលប័ត្រអាជីវកម្មកាន់តែទូលំទូលាយក៏ដោយនោះ គឺបានសង្កត់ធ្ងន់យ៉ាងច្បាស់ពីភាពរឹងមាំនៃវិន័យវាយតម្លៃហានិភ័យកំណត់បុព្វលាភធានារ៉ាប់រង ក្របខ័ណ្ឌគ្រប់គ្រងសំណងធានារ៉ាប់រងដ៏រឹងមាំ និងការប្តេជ្ញាចិត្តយ៉ាងមុតមាំជាបន្តបន្ទាប់ចំពោះគុណភាពផលប័ត្រអាជីវកម្មនៅគ្រប់ខ្សែអាជីវកម្មទាំងអស់។

## ចំណាយលើការគ្រប់គ្រង និងកម្រៃជើងសា

ក្រុមហ៊ុនបានចាត់ចែង និងគ្រប់គ្រងចំណាយប្រតិបត្តិការរបស់ខ្លួនក្នុងគោលបំណងរក្សាមូលដ្ឋានថ្លៃដើមឱ្យមានប្រសិទ្ធភាព និងអាចពង្រីកវិសាលភាពបាន ដើម្បីគាំទ្រដល់កំណើនអាជីវកម្ម ដោយមិនធ្វើឱ្យប៉ះពាល់ដល់គុណភាពសេវាកម្ម ឬការអនុលោមតាមបទប្បញ្ញត្តិនោះឡើយ។ ចំណាយនានាត្រូវបានតាមដានផ្ទៀងផ្ទាត់ផ្ទៀបនឹងកញ្ចប់ថវិកាប្រចាំខែ ដោយមានការរាយការណ៍អំពីគម្លាតចំណាយជូនដល់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាលជាទៀងទាត់។

## ផលចំណេញពីការធានារ៉ាប់រង

ក្រុមហ៊ុនសម្រេចបាននូវលទ្ធផលការវាយតម្លៃហានិភ័យកំណត់បុព្វលាភធានារ៉ាប់រងយ៉ាងរឹងមាំនៅក្នុងឆ្នាំ 2025 ដោយអនុបាតរួម (Combined ratio) បានប្រសើរឡើងមកត្រឹម 105% ពីចំនួន 112% កាលពីឆ្នាំមុន ដែលឆ្លុះបញ្ចាំងពីវឌ្ឍនភាពដ៏មានសារៈសំខាន់ទាំងក្នុងការគ្រប់គ្រងសំណងធានារ៉ាប់រង និងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយ។

អនុបាតខាតបង់ (Loss ratio) បានកើនឡើងដល់ 49% ពីចំនួន 36% ដែលជាចម្បងបណ្តាលមកពីការកើនឡើងនៃប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រងសម្រាប់កិច្ចសន្យាធានារ៉ាប់រងរយៈពេលវែង។ ដោយឡែក អនុបាតចំណាយ (Expenses ratio) បានកត់ត្រានូវការលោតផ្លោះដ៏ល្អប្រសើរមួយមកត្រឹម 39% ពីចំនួន 52% ដែលបង្ហាញឱ្យឃើញពីកិច្ចខិតខំប្រឹងប្រែងប្រកបដោយជោគជ័យរបស់ក្រុមហ៊ុនក្នុងការបង្កើនប្រសិទ្ធភាពរចនាសម្ព័ន្ធថ្លៃដើម និងការលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការក្នុងអំឡុងឆ្នាំនេះ។

លទ្ធផលការវាយតម្លៃហានិភ័យកំណត់បុព្វលាភធានារ៉ាប់រងដ៏រឹងមាំនេះ ត្រូវបានឆ្លុះបញ្ចាំងកាន់តែច្បាស់តាមរយៈប្រាក់ចំណេញជារួមរបស់ក្រុមហ៊ុន ដោយក្នុងនោះប្រាក់ចំណេញមុនពន្ធលើប្រាក់ចំណូលបានកើនឡើងដល់ 183,613 ដុល្លារសហរដ្ឋអាមេរិក ពីចំនួន 1,225 ដុល្លារសហរដ្ឋអាមេរិក កាលពីឆ្នាំមុន ហើយប្រាក់ចំណេញសុទ្ធបានកើនឡើងដល់ 125,491 ដុល្លារសហរដ្ឋអាមេរិក ដែលគាំទ្រដោយកំណើន 35% នៃបុព្វលាភធានារ៉ាប់រងសុទ្ធរហូតដល់ចំនួន 5,010,740 ដុល្លារសហរដ្ឋអាមេរិក និងចំណូលពីការវិនិយោគចំនួន 441,470 ដុល្លារសហរដ្ឋអាមេរិក។ ទន្ទឹមនឹងនេះ ផលត្រឡប់មកវិញលើមូលនិធិភាគហ៊ុនិក (Return on equity) បានប្រសើរឡើងដល់ 1.7% ពីចំនួន -0.7% ហើយផលត្រឡប់មកវិញលើទ្រព្យសកម្ម (Return on assets) បានប្រសើរឡើងដល់ 1.0% ពីចំនួន -0.3% ដែលបង្ហាញពីសមត្ថភាពកាន់តែខ្ពស់របស់ក្រុមហ៊ុនក្នុងការបង្កើតតម្លៃជូនដល់ភាគហ៊ុនិករបស់ខ្លួន។

ជារួម លទ្ធផលនៃការវាយតម្លៃហានិភ័យកំណត់បុព្វលាភធានារ៉ាប់រងឆ្នាំ 2025 ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តជាបន្តបន្ទាប់របស់ក្រុមហ៊ុនចំពោះភាពមានប្រាក់ចំណេញ ការជ្រើសរើសហានិភ័យប្រកបដោយវិន័យនិងឧត្តមភាពនៃប្រតិបត្តិការ ដែលជួយពង្រឹងជំហរក្រុមហ៊ុនយ៉ាងល្អប្រសើរសម្រាប់និរន្តរភាពនៃលទ្ធផលប្រតិបត្តិការក្នុងបណ្តាឆ្នាំខាងមុខ។

# ការធានារ៉ាប់រងបន្ត

ក្រុមហ៊ុនបានរក្សានូវកម្មវិធីធានារ៉ាប់រងបន្តដ៏រឹងមាំមួយ ក្នុងគោលបំណងការពារមូលធន រក្សាស្ថិរភាពនៃលទ្ធផលប្រតិបត្តិការធានារ៉ាប់រង និងបង្កើនសមត្ថភាពក្នុងការទទួលធានារ៉ាប់រងលើអាជីវកម្ម។ការរៀបចំការធានារ៉ាប់រងបន្តត្រូវបានរចនាឡើងយ៉ាងរចនាសម្ព័ន្ធស្របតាមកម្រិតហានិភ័យដែលក្រុមហ៊ុនអាចទទួលយកបាន ទម្រង់ផលប័ត្រអាជីវកម្ម និងតម្រូវការបទប្បញ្ញត្តិជាធរមាន។

## យុទ្ធសាស្ត្រធានារ៉ាប់រងបន្ត

ក្រុមហ៊ុនបានផ្ទេរការធានារ៉ាប់រងបន្តលើផ្នែកខ្លះនៃហានិភ័យធានារ៉ាប់រងដែលខ្លួនបានទទួលខុសត្រូវ ដើម្បីគ្រប់គ្រងកម្រិតប្រឈមនឹងការខាតបង់ និងការពារមូលធនរបស់ខ្លួន តាមរយៈកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តតាមកិច្ចសន្យា (Treaty Reinsurance) និងការធានារ៉ាប់រងបន្តតាមករណី (Facultative Reinsurance)។ កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តទាំងនេះ ជួយផ្ទេរហានិភ័យមួយផ្នែក និងកំណត់ដែនកំណត់នៃការប្រឈមហានិភ័យពីម្ចាស់បណ្ណសន្យារ៉ាប់រងម្នាក់ៗ។ ចំនួនទឹកប្រាក់នៃហានិភ័យនីមួយៗដែលក្រុមហ៊ុនរក្សាទុកដោយខ្លួនឯង (Retained Risk) គឺអាស្រ័យលើការវាយតម្លៃរបស់ក្រុមហ៊ុនទៅលើកម្មវត្ថុហានិភ័យជាក់លាក់ក្នុងកាលៈទេសៈមួយចំនួន រហូតដល់កម្រិតអតិបរមាដែលផ្អែកលើលក្ខណៈសម្បត្តិនៃការការពារ។

នៅក្រោមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត ក្រុមហ៊ុនធានារ៉ាប់រងបន្តយល់ព្រមទូទាត់សងវិញនូវចំនួនទឹកប្រាក់ដែលបានផ្ទេរ ក្នុងករណីដែលសំណងត្រូវបានទូទាត់។ ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុននៅតែត្រូវទទួលខុសត្រូវចំពោះមុខម្ចាស់បណ្ណសន្យារ៉ាប់រងរបស់ខ្លួន ពាក់ព័ន្ធនឹងការធានារ៉ាប់រងដែលបានផ្ទេរ ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងបន្តណាមួយខកខានមិនបានបំពេញកាតព្វកិច្ចដែលខ្លួនបានទទួលខុសត្រូវ។

## ការជ្រើសរើសដៃគូធានារ៉ាប់រងបន្ត

ការជ្រើសរើសដៃគូធានារ៉ាប់រងបន្ត គឺត្រូវបានគ្រប់គ្រងដោយគោលនយោបាយធានារ៉ាប់រងបន្តដែលអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដែលកំណត់នូវលក្ខខណ្ឌវិនិច្ឆ័យសិទ្ធិទទួលបានអប្បបរមា ដែនកំណត់នៃការប្រមូលផ្តុំ និងដំណើរការពិនិត្យឡើងវិញប្រចាំឆ្នាំ។ ក្របខ័ណ្ឌនៃការជ្រើសរើសក្រុមហ៊ុនធានារ៉ាប់រងបន្តរបស់ក្រុមហ៊ុន ត្រូវបានរចនាឡើងដើម្បីធានាថា ទ្រព្យសកម្មធានារ៉ាប់រងបន្តដែលអាចទាមទារមកវិញបាន (Reinsurance Recoverables) មានភាពមានសុវត្ថិភាព អាចប្រមូលបាន និងត្រូវបានដាក់អាជីវកម្មជាមួយដៃគូកិច្ចសន្យាដែលមានស្ថិរភាពហិរញ្ញវត្ថុរឹងមាំ។

រាល់ក្រុមហ៊ុនធានារ៉ាប់រងបន្តទាំងអស់ដែលចូលរួមក្នុងកម្មវិធីធានារ៉ាប់រងបន្តតាមកិច្ចសន្យា និងតាមករណីរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 បានបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យអប្បបរមាខាងលើទាំងស្រុង។

ក្រុមហ៊ុនសូមបញ្ជាក់ថា ក្រុមហ៊ុនធានារ៉ាប់រងបន្តដែលចូលរួមទាំងអស់ សុទ្ធតែទទួលបានស្ថានភាពអនុម័តដែលមានសុពលភាពពី ន.ធ.ក. សម្រាប់ប្រភេទអាជីវកម្មពាក់ព័ន្ធ មុនពេលឈានទៅដល់ការចុះកិច្ចសន្យាធានារ៉ាប់រងបន្តណាមួយ។



# ការគ្រប់គ្រងហានិភ័យ

ក្រុមហ៊ុនអនុវត្តប្រតិបត្តិការអាជីវកម្មស្ថិតក្រោមក្របខ័ណ្ឌគ្រប់គ្រងហានិភ័យដ៏រឹងមាំមួយ ដែលមើលខុសត្រូវដោយក្រុមប្រឹក្សាភិបាល ដោយក្របខ័ណ្ឌនេះត្រូវបានរចនាឡើងដើម្បីកំណត់ អត្រានុកូលដ្ឋាន វាយតម្លៃ តាមដាន និងកាត់បន្ថយហានិភ័យនានា ដែលអាចរារាំងដល់ការសម្រេចបាននូវគោលដៅហិរញ្ញវត្ថុ និងគោលដៅយុទ្ធសាស្ត្រប្រកបដោយចីរភាពរបស់ខ្លួន។

- ហានិភ័យធានារ៉ាប់រង (Insurance Risk)៖ ត្រូវបានគ្រប់គ្រងតាមរយៈគោលការណ៍ណែនាំនៃការធានារ៉ាប់រងប្រកបដោយវិន័យ ដែនកំណត់សិទ្ធិអំណាចច្បាស់លាស់ ការធ្វើពិពិធកម្មផលប័ត្រអាជីវកម្ម ការកំណត់ថ្លៃបុព្វលាភយ៉ាងសមស្រប និងការរៀបចំការធានារ៉ាប់រងបន្តជាមួយក្រុមហ៊ុនធានារ៉ាប់រងបន្តដែលមានចំណាត់ថ្នាក់ឥណទានចាប់ពីកម្រិត 'A' ឬខ្ពស់ជាងនេះ។ វិធីសាស្ត្រស្ថិតិត្រូវបានយកមកអនុវត្តដើម្បីប៉ាន់ប្រមាណកាតព្វកិច្ចបំណុលផ្នែកសំណង ហើយសំណងនីមួយៗត្រូវបានវាយតម្លៃតាមករណីជាក់ស្តែង (Case-by-case) ព្រមទាំងមានការពិនិត្យឡើងវិញជាប្រចាំនៅពេលមានព័ត៌មានថ្មីៗកើតឡើង។
- ហានិភ័យទីផ្សារ (Market Risk)៖ កើតឡើងជាចម្បងពីបម្រែបម្រួលអត្រាការប្រាក់លើផលប័ត្រនៃការវិនិយោគ និងការប្រែប្រួលអត្រាប្តូរប្រាក់បរទេស។ ក្រុមហ៊ុនដំណើរការអាជីវកម្មភាគច្រើនជាប្រាក់ដុល្លារអាមេរិក ដែលជួយកម្រិតហានិភ័យប្រឈមនឹងការប្រែប្រួលរូបិយប័ណ្ណ និងបានតាមដានស្ថានភាពទ្រព្យសកម្ម និងកាតព្វកិច្ចបំណុលជាទៀងទាត់ ដើម្បីគ្រប់គ្រងផលប៉ះពាល់នៃបម្រែបម្រួលអត្រាការប្រាក់មកលើស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន។
- ហានិភ័យឥណទាន (Credit Risk)៖ ត្រូវបានគ្រប់គ្រងតាមរយៈការកំណត់ដែនកំណត់ឥណទានដៃគូកិច្ចសន្យា ការពិនិត្យឡើងវិញជាទៀងទាត់លើគណនីត្រូវទារ និងគោលការណ៍ណែនាំសម្រាប់ការអនុម័តក្រុមហ៊ុនធានារ៉ាប់រងបន្ត ដោយរួមបញ្ចូលទាំងចំណាត់ថ្នាក់ឥណទានកម្រិតអន្តរជាតិ។ ស្ថិរភាពហិរញ្ញវត្ថុ និងលទ្ធផលនៃការទូទាត់សងរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្ត ត្រូវបានពិនិត្យឡើងវិញជាប្រចាំ។
- ហានិភ័យសាច់ប្រាក់ងាយ (Liquidity Risk)៖ ត្រូវបានគ្រប់គ្រងដោយការរក្សាកម្រិតសាច់ប្រាក់ និងទ្រព្យសកម្មសាច់ប្រាក់ងាយឱ្យបានគ្រប់គ្រាន់ ដើម្បីបំពេញកាតព្វកិច្ចសំណងធានារ៉ាប់រង និងការប្តេជ្ញាចិត្តផ្នែកប្រតិបត្តិការ ទាំងស្ថិតក្នុងស្ថានភាពធម្មតា និងស្ថានភាពមានសម្ពាធហិរញ្ញវត្ថុ។
- ហានិភ័យប្រតិបត្តិការ (Operational Risk)៖ ត្រូវបានកាត់បន្ថយតាមរយៈការកំណត់តួនាទី និងការទទួលខុសត្រូវយ៉ាងច្បាស់លាស់ នីតិវិធីដែលមានឯកសារយោងត្រឹមត្រូវ ដែនកំណត់សិទ្ធិអំណាច ការបណ្តុះបណ្តាលបុគ្គលិក និងការរៀបចំផែនការបន្តនិរន្តរភាពអាជីវកម្ម។
- អនុលោមភាពដើមទុន និងបទប្បញ្ញត្តិ (Capital and Regulatory Compliance)៖ ត្រូវបានតាមដានយ៉ាងសកម្ម ដើម្បីធានាថាម្ចាស់ទៀតក្រុមហ៊ុនរក្សាបាននូវកម្រិតសាធនភាព (Solvency Margin) របស់ខ្លួនឱ្យខ្ពស់ជាងតម្រូវការអប្បបរមា 120% ដូចដែលបានកំណត់ដោយនិយ័តករធានារ៉ាប់រងកម្ពុជា។

នីតិវិធីពិនិត្យផ្ទៀងផ្ទាត់ការយល់ដឹងពីអតិថិជន (Customer Due Diligence) ត្រូវបានយកមកអនុវត្តនៅពេលចាប់ផ្តើមទទួលយកអតិថិជន និងធ្វើឡើងជាបន្តបន្ទាប់ រួមទាំងការផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជន និងការតាមដានប្រតិបត្តិការហិរញ្ញវត្ថុ ដើម្បីអនុលោមតាមបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់ និងការស្វែងយល់ពីអតិថិជន (KYC) ជាធរមាន។

ភាគីពាក់ព័ន្ធ និងដៃគូអាជីវកម្មនានា ត្រូវបានកំណត់អត្តសញ្ញាណ និងគ្រប់គ្រងតាមរយៈនីតិវិធីអភិបាលកិច្ចដែលបានបង្កើតឡើង ដើម្បីធានាថាទំនាស់ផលប្រយោជន៍ត្រូវបានបង្ហាញជាសាធារណៈយ៉ាងត្រឹមត្រូវ ហើយរាល់ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធទាំងអស់ ត្រូវបានអនុវត្តឡើងផ្អែកលើគោលការណ៍តម្លាភាព និងតម្លៃទីផ្សារសេរី (Arm's Length Terms)។

ការបង្ហាញលម្អិតអំពីគោលនយោបាយគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុន ហានិភ័យប្រឈមលក្ខណៈបរិមាណ និងកម្រិតនៃការងាយរងឥទ្ធិពលនៃហានិភ័យហិរញ្ញវត្ថុ ត្រូវបានបង្ហាញជូននៅក្នុងកំណត់ចំណាំភ្ជាប់ជាមួយរបាយការណ៍ហិរញ្ញវត្ថុដែលបានសវនកម្មរួច។



# របាយការណ៍ហិរញ្ញវត្ថុ
# ដែលបានធ្វើសវនកម្ម



ព័ត៌មានហិរញ្ញវត្ថុដែលបានបង្ហាញខាងក្រោមនេះ ត្រូវបានដកស្រង់ចេញពីរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2025។ ក្រុមហ៊ុន អឺនស្ទ៍ អ៊ែន យ៉ាំង (ខេមបូឌា) បានចេញផ្សាយមតិយោបល់សវនកម្មមិនមានបញ្ហា លើសំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ។ ការដកស្រង់នេះមិនរួមបញ្ចូលការលាតត្រដាងទាំងអស់នោះទេ ហើយគួរតែត្រូវបានអានដោយភ្ជាប់ជាមួយរបាយការណ៍ហិរញ្ញវត្ថុពេញលេញដែលបានធ្វើសវនកម្ម និងរបាយការណ៍របស់សវនករចុះថ្ងៃទី30 ខែមីនា ឆ្នាំ 2026។

# ក្រុមហ៊ុន ហ្វតតេ ឡាយហ្វ៍ អឹស្សួរិនស៍ (ខេមបូឌា) ម.ក
(លេខចុះបញ្ជី 00012679)

## ព័ត៌មានទូទៅអំពីក្រុមហ៊ុន

| | | |
|---|---|---|
| ឈ្មោះក្រុមហ៊ុន៖ | ក្រុមហ៊ុន ហ្វតតេ ឡាយហ្វ៍ អឹស្សួរិនស៍ (ខេមបូឌា) ម.ក | |
| លេខចុះបញ្ជីពាណិជ្ជកម្ម៖ | 00012679 | |
| ទីស្នាក់ការចុះបញ្ជី និង ការិយាល័យកណ្តាល៖ | The Point Community Mall ជាន់ទី3A U08&U09 អគារលេខ113C មហាវិថីម៉ៅសេទុង ភូមិ7 សង្កាត់ទូលស្វាយព្រៃ1 ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា<br>ទូរស័ព្ទលេខ៖ (+855) 23 885 077 / 885 066<br>ទូរសារលេខ៖ (+855) 23 982 907<br>សារអេឡិចត្រូនិក៖ info@fortelifeassurance.com | |
| ក្រុមប្រឹក្សាភិបាល៖ | លោក Cheo Huat Leng, Charles Francis | ប្រធានក្រុមប្រឹក្សាភិបាល |
| | លោក ម៉ៅ សារិន | អភិបាល |
| | លោក សួន ពិសី | អភិបាល |
| | លោក Lee Foo Yeun | អភិបាល |
| | លោកស្រី Zhao Haiming | អភិបាល |
| | លោក ព្រូ ស៊ីថន | អភិបាល |
| | លោក ង៉ែត ជូ | អភិបាលឯករាជ្យ |
| | លោក ជុំ សុជាតិ | អភិបាលឯករាជ្យ |
| | លោក Trieu Robert | អភិបាលឯករាជ្យ |
| គណៈគ្រប់គ្រង៖ | លោក ព្រូ ស៊ីថន | ប្រធាននាយកប្រតិបត្តិ |
| | លោក ហុង ប៊ុនហួ | នាយកប្រតិបត្តិហិរញ្ញវត្ថុ |
| | លោក លឹម លីហួរ | នាយកប្រតិបត្តិគ្រប់គ្រងអាជីវកម្ម |
| ធនាគារិកចម្បង៖ | ធនាគារ ស៊ិនហាន<br>ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់<br>ធនាគារ ស៊ីអាយអិមប៊ី | |
| សវនករ៖ | ក្រុមហ៊ុន អឺនស្ទ៍ អ៊ែន យ៉ាំង (ខេមបូឌា) | |

**Forte**
**Life Assurance**

**Live with confidence.**

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមដាក់ជូនរបាយការណ៍របស់ខ្លួនរួមជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរបស់ក្រុមហ៊ុន ហ្វតតេ ឡាយហ្វ៍ អឹស្សួរ៉ែនស៍ (ខេមបូឌា) ម.ក (ហៅកាត់ថា "ក្រុមហ៊ុន") នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់។

### សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន នៅក្នុងអំឡុងការិយបរិច្ឆេទ គឺការធ្វើប្រតិបត្តិការអាជីវកម្មធានារ៉ាប់រងអាយុជីវិត។ នៅថ្ងៃទី6 ខែកុម្ភៈ ឆ្នាំ2019 ក្រុមហ៊ុនបានទទួលនូវអាជ្ញាប័ណ្ណធានារ៉ាប់រងអាយុជីវិតពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី6 ខែកុម្ភៈ ឆ្នាំ2019 ដល់ថ្ងៃទី5 ខែកុម្ភៈ ឆ្នាំ2024។ នៅថ្ងៃទី1 ខែកុម្ភៈ ឆ្នាំ2024 ក្រុមហ៊ុនបានទទួលនូវអាជ្ញាប័ណ្ណធានារ៉ាប់រងអាយុជីវិតអចិន្ត្រៃយ៍ពី និយ័តករធានារ៉ាប់រងកម្ពុជា។

### លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបញ្ចប់ ត្រូវបានកំណត់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

### ភាគលាភ

ក្រុមប្រឹក្សាភិបាលពុំបានផ្តល់អនុសាសន៍ឲ្យមានការទូទាត់ភាគលាភសម្រាប់ការិយបរិច្ឆេទបញ្ចប់នេះទេ។

### ការបោះផ្សាយភាគហ៊ុន និងប័ណ្ណធានា

ប័ណ្ណភាគហ៊ុនធម្មតាដែលត្រូវបានអនុម័ត និងបោះផ្សាយក្នុងអំឡុងការិយបរិច្ឆេទនេះត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

### ទុនបម្រុង និងសំវិធានធន

រាល់ការបន្ថែម ឬ បន្ថយទុនបម្រុង និងសំវិធានធនក្នុងអំឡុងការិយបរិច្ឆេទត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

### គម្រោងក្នុងការផ្តល់ជាជម្រើសភាគហ៊ុនដល់បុគ្គលិក

មិនមានគម្រោងក្នុងការផ្តល់ជាជម្រើសភាគហ៊ុនដល់បុគ្គលិកទេក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

### ភាគហ៊ុនកាន់កាប់ដោយអភិបាល

ពុំមានអភិបាលណាម្នាក់កាន់កាប់ភាគហ៊ុនដោយផ្ទាល់នៅក្នុងមូលធនរបស់ក្រុមហ៊ុននោះទេ។

***របាយការណ៍របស់ក្រុមប្រឹក្សាភិបាល*** (តពីទំព័រមុន)

### អត្ថប្រយោជន៍របស់អភិបាល

ក្នុងអំឡុង និងនាការិយបរិច្ឆេទបញ្ចប់នេះ មិនមានកិច្ចព្រមព្រៀងណាមួយដែលអនុញ្ញាតឲ្យក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុនទទួលបាននូវផលប្រយោជន៍ពីការទិញប័ណ្ណភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុនឡើយ។លាភការរបស់អភិបាលត្រូវបានលាតត្រដាងនៅក្នុង *កំណត់សម្គាល់លេខ 22* នៃរបាយការណ៍ហិរញ្ញវត្ថុ។

### ព័ត៌មានអំពីរបាយការណ៍ហិរញ្ញវត្ថុ

មុនពេលរៀបចំរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងរបាយការណ៍លទ្ធផលពេញលេញ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របតាមលំដាប់ដូចខាងក្រោម៖

(ក) ធានាក្នុងការចាត់វិធានការសមស្របចំពោះការលុបបំណុលអាក្រក់ចេញពីបញ្ជី និងបានធ្វើសំវិធានធនលើបំណុលសង្ស័យ និងធានារាល់បំណុលអាក្រក់ទាំងអស់ ត្រូវបានលុបចោលនិងការធ្វើសំវិធានធនគ្រប់គ្រាន់សម្រាប់បំណុលសង្ស័យ និង

(ខ) ធានាថាទ្រព្យសកម្មរយៈពេលខ្លីណាដែលមិនអាចលក់បានតាមតម្លៃដើម ដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុនត្រូវបានកត់ត្រាតាមតម្លៃប៉ាន់ស្មានដែលទទួលស្គាល់សុទ្ធ។

នាកាលបរិច្ឆេទរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយដែល៖

(ក) នៅមានចំនួនបំណុលអាក្រក់ដែលពុំបានលុបចោល ឬធ្វើសំវិធានធនមិនគ្រប់គ្រាន់សម្រាប់បំណុលសង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។ ឬ

(ខ) តម្លៃនៃទ្រព្យសកម្មរយៈពេលខ្លីនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គឺជាតម្លៃមិនទាន់ត្រឹមត្រូវ នោះឡើយទេ។ ឬ

(គ) វិធីសាស្ត្រវាយតម្លៃទ្រព្យសកម្ម ឬ បំណុលរបស់ក្រុមហ៊ុនគឺជាវិធីសាស្ត្រខុស ឬ មិនសមស្របនោះឡើយ។

### បំណុលយថាភាព

គ្មានបំណុលយថាភាព ឬបំណុលផ្សេងៗរបស់ក្រុមហ៊ុនដែលត្រូវទូទាត់សង ឬ អាចនឹងទូទាត់សងក្នុងរយៈពេល 12ខែ បន្ទាប់ពីការិយបរិច្ឆេទបញ្ចប់ (តាមមតិក្រុមប្រឹក្សាភិបាល) ដែលនឹងអាចប៉ះពាល់ដល់លទ្ធភាពបំពេញកាតព្វកិច្ច លើការសងបំណុលរបស់ក្រុមហ៊ុននៅពេលដែលបំណុលទាំងនោះដល់ថ្ងៃកំណត់សងទេ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះមិនមាន៖

- បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុនដែលបានកើតឡើង ចាប់តាំងពីដំណាច់ឆ្នាំដោយសារ ការដាក់បញ្ចាំសម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ
- បំណុលយថាភាពណាមួយរបស់ក្រុមហ៊ុនដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំមក លើកលែងតែបំណុលយថាភាពដែលបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

# ក្រុមហ៊ុនហ្វតតេ ឡាយហ្វ៍អឺស្សួរ៉ិនស៍ (ខេមបូឌា) ភីអិលស៊ី

(លេខចុះបញ្ជី Co.00012679)

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

## បម្រែបម្រួលនៃកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍នេះ ឬ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលនឹងបណ្តាលឲ្យចំនួនទឹកប្រាក់ ដែលបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះមានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

## មតិយោបល់របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាលៈ

- លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងអំឡុងការិយបរិច្ឆេទនេះ មិនមានការប៉ះពាល់ជាសារវន្តដោយសារ ខ្ទង់ណាមួយ ប្រតិបត្តិការ ឬ ព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយ និង
- គិតត្រឹមការិយបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានព្រឹត្តិការណ៍បន្ទាប់ជាសារវន្តណាមួយដែលបានកើតឡើងនៅចន្លោះដំណាច់ឆ្នាំ និង កាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចប៉ះពាល់ដល់ប្រតិបត្តិការរបស់ក្រុមហ៊ុនលើកលែងតែអ្វីដែលបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## សវនករ

ក្រុមហ៊ុន អឺនស្ទ៍ អ៊ែន យ៉ាំង (ខេមបូឌា) គឺជាសវនកររបស់ក្រុមហ៊ុន។

តំណាងឲ្យក្រុមប្រឹក្សាភិបាល

Cheo Huat Leng, Charles Francis
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី30 ខែមីនា ឆ្នាំ2026

**ក្រុមហ៊ុនហ្វតេ ឡាយហ្វ៍អឹស្សរ៉ែនស៍ (ខេមបូឌា) ភីអិលស៊ី**
(លេខចុះបញ្ជី Co.00012679)

**សេចក្តីបញ្ជាក់របស់ក្រុមប្រឹក្សាភិបាល**

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការធានាអះអាងថា របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (ហៅកាត់ថា “CIFRSs”) ជាមួយនឹងការពន្យារពេលអនុវត្ត CIFRS 17 *កិច្ចសន្យាធានារ៉ាប់រង* និង CIFRS 9 *ឧបករណ៍ហិរញ្ញវត្ថុ* ស្របតាមសេចក្តីជូនដំណឹងរបស់ និយ័តករគណនេយ្យ និងសវនកម្ម (ហៅកាត់ថា "ន.គ.ស") ដែលអនុញ្ញាតឲ្យពន្យារពេលក្នុងការអនុវត្តស្តង់ដាទាំងនេះ។ ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការត្រួតពិនិត្យនូវរាល់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដែលរៀបចំដោយ គណៈគ្រប់គ្រង ដែលត្រូវបានតម្រូវឲ្យ៖

ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តន៍យ៉ាងខ្ជាប់ខ្ជួន។

ខ) អនុវត្តតាម CIFRSs ជាមួយនឹងការពន្យារពេលអនុវត្ត CIFRS 17 និង CIFRS 9 ឬ ប្រសិនបើមានការគម្លាតណាមួយចាកឆ្ងាយពីការបង្ហាញដែលសមស្របនិងត្រឹមត្រូវ គម្លាតទាំងនោះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់ចំនួនឲ្យបានសមស្របនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គ) រក្សាកំណត់ត្រាគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនសមស្របក្នុងការសន្មតថា ក្រុមហ៊ុននឹងអាចបន្តប្រតិបត្តិការអាជីវកម្មនាពេលអនាគតដែលព្យាករណ៍មុនបាន និង

ង) ដាក់ចេញនូវគោលនយោបាយរួមសម្រាប់ក្រុមហ៊ុន អនុម័តរាល់ការសម្រេចចិត្ត និងសកម្មភាពទាំងឡាយ ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការ និងដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន ហើយនឹងត្រូវប្រាកដថាកិច្ចការទាំងនេះត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវក្នុងការធានាថា បញ្ជីគណនេយ្យដែលមានភាពសមស្របត្រូវបាន រក្សាទុក ដែលបានលាតត្រដាងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ របស់ក្រុមហ៊ុន ឲ្យបានត្រឹមត្រូវសមហេតុផលគ្រប់ពេលវេលា ហើយនឹងត្រូវធានាថា បញ្ជីគណនេយ្យទាំងនោះស្របតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។
គណៈគ្រប់គ្រង ក៏មានការទទួលខុសត្រូវក្នុងការការពារថែរក្សាទ្រព្យសកម្មរបស់ក្រុមហ៊ុន និងក្នុងការចាត់វិធានការសមស្របទាំងឡាយក្នុងការទប់ស្កាត់ និងការស្វែងរកការបន្លំ និងភាពមិនប្រក្រតីផ្សេងៗផងដែរ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមតម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

**ក្រុមហ៊ុនហ្វតតេ ឡាយហ្វ៍ អឹស្សួរិនស៍ (ខេមបូឌា) ម.ក**
(លេខចុះបញ្ជី 00012679)

**សេចក្តីបញ្ជាក់របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមមាត្រា 226 នៃច្បាប់ស្តីពីសហគ្រាស ពាណិជ្ជកម្ម

ខ្ញុំបាទឈ្មោះ Cheo Huat Leng, Charles Francis តំណាងឲ្យក្រុមប្រឹក្សាភិបាល សូមបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយនេះ ផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ហើយលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់អនុលោមតាម CIFRSs ជាមួយនឹងការពន្យារពេលអនុវត្ត CIFRS 17 និង CIFRS 9។

Cheo Huat Leng, Charles Francis
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី30 ខែមីនា ឆ្នាំ2026

## ក្រុមហ៊ុនហ្វតតេ ឡាយហ្វ៍ អ៊ីស្នួរិនស៍ (ខេមបូឌា) ម.ក
(លេខចុះបញ្ជី 00012679)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | *កំណត់សម្គាល់* | *2025* | | *2024* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់លេខ 3.1)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់លេខ 3.1)* |
| **ទ្រព្យសកម្ម** | | | | | |
| ទ្រព្យ និងបរិក្ខារ | 6 | 111,753 | 448,465 | 196,803 | 792,132 |
| ទ្រព្យសកម្មអរូបី | 7 | 163,203 | 654,934 | 199,239 | 801,937 |
| សិទ្ធប្រើប្រាស់ទ្រព្យសកម្ម | 8.1 | 65,739 | 263,811 | 115,043 | 463,048 |
| ប្រាក់តម្កល់តាមច្បាប់ | 9 | 700,000 | 2,809,100 | 700,000 | 2,817,500 |
| គណនីធានារ៉ាប់រងត្រូវទទួល | 10 | 620,994 | 2,492,049 | 1,604,076 | 6,456,406 |
| ទ្រព្យសកម្មធានារ៉ាប់រងបន្ត | 11 | 116,746 | 468,502 | 780,933 | 3,143,255 |
| ទ្រព្យសកម្មផ្សេងៗ | 12 | 717,914 | 2,880,988 | 1,312,081 | 5,281,125 |
| ប្រាក់បញ្ញើនៅធនាគារ | 13 | 8,422,285 | 33,798,630 | 7,566,312 | 30,454,406 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | 14 | 1,378,042 | 5,530,083 | 645,268 | 2,597,204 |
| **ទ្រព្យសកម្មសរុប** | | **12,296,676** | **49,346,562** | **13,119,755** | **52,807,013** |
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | 15 | 10,680,000 | 42,720,000 | 10,680,000 | 42,720,000 |
| បុព្វលាភដើមទុន | | 200,000 | 800,000 | 200,000 | 800,000 |
| ខាតបង្គរ | | (3,596,095) | (14,718,967) | (3,721,586) | (15,222,315) |
| លម្អៀងបង្គរពីការបកប្រែរូបិយប័ណ្ណ | | - | 429,278 | - | 514,931 |
| **មូលធនសរុប** | | **7,283,905** | **29,230,311** | **7,158,414** | **28,812,616** |
| **បំណុល** | | | | | |
| បំណុលកិច្ចសន្យាធានារ៉ាប់រង | 16 | 4,447,578 | 17,848,131 | 3,609,178 | 14,526,941 |
| គណនីធានារ៉ាប់រងត្រូវទូទាត់ | 17 | 273,139 | 1,096,107 | 1,491,351 | 6,002,688 |
| គណនីត្រូវទូទាត់ផ្សេងៗ | 18 | 212,386 | 852,305 | 732,161 | 2,946,948 |
| បំណុលពន្ធលើប្រាក់ចំណូល | 19 | 5,599 | 22,469 | 3,975 | 15,999 |
| បំណុលភតិសន្យា | 8.2 | 74,069 | 297,239 | 124,676 | 501,821 |
| **បំណុលសរុប** | | **5,012,771** | **20,116,251** | **5,961,341** | **23,994,397** |
| **មូលធន និងបំណុលសរុប** | | **12,296,676** | **49,346,562** | **13,119,755** | **52,807,013** |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីលេខ 1 ដល់ 28 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

## ក្រុមហ៊ុនហ្វូតតេ ឡាយហ្វ៍ អឹស្សួរ៉ិនស៍ (ខេមបូឌា) ម.ក
(លេខចុះបញ្ជី 00012679)

## របាយការណ៍លទ្ធផលពេញលេញ
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | *កំណត់សម្គាល់* | *2025* | | *2024* | |
|---|---|---|---|---|---|
| | | *ដុល្លាអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់លេខ 3.1)* | *ដុល្លាអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់លេខ 3.1)* |
| បុព្វលាភដុល | 20 | 5,313,510 | 21,312,489 | 4,725,240 | 19,236,452 |
| បម្រែបម្រួលនៃប្រាក់បម្រុងបុព្វលាភមិនទាន់ទទួលស្គាល់ | 20 | (405,521) | (1,626,545) | 518,383 | 2,110,337 |
| បុព្វលាភផ្ទេរទៅក្រុមហ៊ុនធានារ៉ាប់រងបន្ត | 20 | (302,770) | (1,214,410) | (1,032,618) | (4,203,788) |
| **ចំណូលបុព្វលាភសុទ្ធ** | | **4,605,219** | **18,471,534** | **4,211,005** | **17,143,001** |
| ចំណូលកម្រៃជើងសារ | 20 | 1,520 | 6,097 | 44,199 | 179,934 |
| ចំណូលការប្រាក់ | | 410,085 | 1,644,851 | 462,235 | 1,881,759 |
| ចំណូលផ្សេងៗ | | 29,865 | 119,789 | 35,139 | 143,051 |
| **ចំណូលផ្សេងៗ** | | **441,470** | **1,770,737** | **541,573** | **2,204,744** |
| **ចំណូលសរុប** | | **5,046,689** | **20,242,271** | **4,752,578** | **19,347,745** |
| អត្ថប្រយោជន៍ និងសំណងដុលបានទូទាត់ | 20 | (1,598,848) | (6,412,979) | (2,548,601) | (10,375,355) |
| សំណងបានផ្ទេរទៅអ្នកធានារ៉ាប់រងបន្ត | 20 | 417,026 | 1,672,691 | 1,033,612 | 4,207,834 |
| បម្រែបម្រួលដុលនៃបំណុលកិច្ចសន្យាធានារ៉ាប់រងផ្សេងៗ | | (777,257) | (3,117,578) | 241,604 | 983,570 |
| បម្រែបម្រួលនៃបំណុលកិច្ចសន្យាធានារ៉ាប់រងផ្សេងៗបានផ្ទេរទៅអ្នកធានារ៉ាប់រងបន្ត | | (319,809) | (1,282,754) | (258,347) | (1,051,731) |
| **សំណងសុទ្ធ** | | **(2,278,888)** | **(9,140,620)** | **(1,531,732)** | **(6,235,682)** |
| ចំណាយថ្លៃឈ្នួល និងកម្រៃជើងសារ | 12.1 | (743,022) | (2,980,261) | (1,004,841) | (4,090,708) |
| ចំណាយទូទៅ និងរដ្ឋបាល | 21 | (1,832,409) | (7,349,791) | (2,197,297) | (8,945,195) |
| ចំណាយហិរញ្ញវត្ថុ | | (8,757) | (35,124) | (17,483) | (71,173) |
| **កម្រៃជើងសារ និងចំណាយផ្សេងៗសរុប** | | **(2,584,188)** | **(10,365,176)** | **(3,219,621)** | **(13,107,076)** |
| **សំណង កម្រៃជើងសារ និងចំណាយផ្សេងៗសរុប** | | **(4,863,076)** | **(19,505,796)** | **(4,751,353)** | **(19,342,758)** |
| **ចំណេញមុនគិតពន្ធលើប្រាក់ចំណូល** | | **183,613** | **736,475** | **1,225** | **4,987** |
| ចំណាយពន្ធលើប្រាក់ចំណូល | 19 | (58,122) | (233,127) | (52,151) | (212,307) |
| **ចំណេញ (ខាត) សុទ្ធក្នុងគ្រា** | | **125,491** | **503,348** | **(50,926)** | **(207,320)** |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | | - | (85,653) | - | (430,218) |
| **ចំណេញ (ខាត) ពេញលេញសរុបក្នុងគ្រា** | | **125,491** | **417,695** | **(50,926)** | **(637,538)** |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីលេខ 1 ដល់ 28 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

**ក្រុមហ៊ុនហ្វតតេ ឡាយហ្វ៍ អ៊ីស្ហួរិនស៍ (ខេមបូឌា) ម.ក**
(លេខចុះបញ្ជី 00012679)

## របាយការណ៍បម្រែបម្រួលក្នុងមូលធន
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | *ដើមទុន* | | *បុព្វលាភដើមទុន* | | *ខាតបង្គរ* | | *លម្អៀងបង្គរពីការបកប្រែរូបិយប័ណ្ណ* | *សរុប* | |
|---|---|---|---|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល ’កំណត់សម្គាល់លេខ 3.1)* | *ដុល្លារអាមេរិក* | *ពាន់រៀល ’កំណត់សម្គាល់លេខ 3.1)* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ពាន់រៀល ’កំណត់សម្គាល់លេខ 3.1)* | *ពាន់រៀល (កំណត់សម្គាល់ លេខ 3.1)* | *ដុល្លារអាមេរិក* |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2025 | **10,680,000** | **42,720,000** | **200,000** | **800,000** | **(3,721,586)** | **(15,222,315)** | **514,931** | **7,158,414** | **28,812,616** |
| ចំណេញពេញលេញសរុបក្នុងគ្រា | - | - | - | - | 125,491 | 503,348 | (85,653) | 125,491 | 417,695 |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025** | **10,680,000** | **42,720,000** | **200,000** | **800,000** | **(3,596,095)** | **(14,718,967)** | **429,278** | **7,283,905** | **29,230,311** |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2024 | **10,680,000** | **42,720,000** | **200,000** | **800,000** | **(3,670,660)** | **(15,014,995)** | **945,149** | **7,209,340** | **29,450,154** |
| ខាតពេញលេញសរុបក្នុងគ្រា | - | - | - | - | (50,926) | (207,320) | (430,218) | (50,926) | (637,538) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024** | **10,680,000** | **42,720,000** | **200,000** | **800,000** | **(3,721,586)** | **(15,222,315)** | **514,931** | **7,158,414** | **28,812,616** |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីលេខ 1 ដល់ 28 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

**ក្រុមហ៊ុនហ្វតតេ ឡាយហ្វ៍ អឹស្សរ៉ិនស៍ (ខេមបូឌា) ម.ក**
(លេខចុះបញ្ជី 00012679)

**របាយការណ៍បម្រែបម្រួលក្នុងមូលធន**
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | *កំណត់សម្គាល់* | *2025* | | *2024* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 3.1)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 3.1)* |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញមុនគិតពន្ធ | | 183,613 | 736,475 | 1,225 | 4,987 |
| និយ័តកម្មលើ៖ | | | | | |
| រំលស់ទ្រព្យរូបី និងអរូបី | | 219,514 | 880,471 | 164,771 | 670,783 |
| កំណើននៃការប្រាក់លើបំណុលភតិសន្យា | 8.2 | 8,145 | 32,670 | 14,934 | 60,796 |
| ចំណេញលើការបញ្ចប់លើភតិសន្យា | | - | - | (11,478) | (46,727) |
| ចំណូលការប្រាក់ | | (410,085) | (1,644,851) | (462,235) | (1,881,759) |
| បម្រែបម្រួលនៃទុនបង្វិល៖ | | | | | |
| គណនីធានារ៉ាប់រងត្រូវទទួល | | 983,082 | 3,943,142 | (39,284) | (159,925) |
| ទ្រព្យសកម្មធានារ៉ាប់រងបន្ត | | 664,187 | 2,664,054 | 631,609 | 2,571,280 |
| ទ្រព្យសកម្មផ្សេងៗ | | 512,407 | 2,055,264 | (398,775) | (1,623,413) |
| បំណុលកិច្ចសន្យាធានារ៉ាប់រង | | 838,400 | 3,362,822 | (1,133,249) | (4,613,457) |
| គណនីធានារ៉ាប់រងត្រូវទូទាត់ | | (1,218,212) | (4,886,248) | 461,530 | 1,878,889 |
| គណនីត្រូវទូទាត់ផ្សេងៗ | | (519,775) | (2,084,818) | 376,189 | 1,531,465 |
| | | **1,261,276** | **5,058,981** | **(394,763)** | **(1,607,081)** |
| ការប្រាក់បានទទួល | | 453,441 | 1,818,752 | 388,284 | 1,580,704 |
| ការប្រាក់បានបង់ | | (8,145) | (32,670) | (14,934) | (60,796) |
| ពន្ធលើប្រាក់ចំណូលបានបង់ | 19 | (56,498) | (226,613) | (57,841) | (235,471) |
| **លំហូរសាច់ប្រាក់សុទ្ធបានពី (ប្រើប្រាស់ក្នុង)សកម្មភាពប្រតិបត្តិការ** | | **1,650,074** | **6,618,450** | **(79,254)** | **(322,644)** |
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញនៃ៖ | | | | | |
| ទ្រព្យ និងបរិក្ខារ | 6 | (10,720) | (42,998) | (12,396) | (50,464) |
| ទ្រព្យអរូបី | 7 | - | - | (1,861) | (7,576) |
| ការដាក់ប្រាក់បញ្ញើនៅធនាគារ | | (6,216,269) | (24,933,455) | (4,946,312) | (20,136,436) |
| សាច់ប្រាក់ទទួលបានពី៖ | | | | | |
| ការដាក់ប្រាក់បញ្ញើនៅធនាគារ | | 5,360,296 | 21,500,147 | 4,933,511 | 20,084,323 |
| **លំហូរសាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(866,693)** | **(3,476,306)** | **(27,058)** | **(110,153)** |
| **សកម្មភាពហិរញ្ញវត្ថុ** | | | | | |
| ការទូទាត់ប្រាក់ដើមនៃបំណុលភតិសន្យា | 8.2 | **(50,607)** | **(202,985)** | **(83,417)** | **(339,591)** |
| **កំណើន (តំហយ) នៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល សុទ្ធ** | | **732,774** | **2,939,159** | **(189,729)** | **(772,388)** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ | | 645,268 | 2,597,204 | 834,997 | 3,410,963 |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | | - | (6,280) | - | (41,371) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | 14 | **1,378,042** | **5,530,083** | **645,268** | **2,597,204** |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីលេខ 1 ដល់ 28 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

## 2. មូលដ្ឋាននៃការរៀបចំ

### *2.1 មូលដ្ឋាន នៃការរៀបចំ*

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ដោយផ្អែកលើមូលដ្ឋានថ្លៃដើមប្រវត្តិសាស្រ្តលើកលែងតែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប។

ក្រុមហ៊ុន បង្ហាញរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួនទៅតាមលំដាប់នៃសន្ទនីយភាព។

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយតម្លៃសុទ្ធក្រោយការកាត់កងត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែមានសិទ្ធិក្នុងការអនុវត្តស្របច្បាប់ដើម្បីកាត់កងចំនួនដែលបានទទួលស្គាល់ ហើយមានបំណងអាចទូទាត់ជាមូលដ្ឋានសុទ្ធ ឬ កត់ត្រាជាទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (ហៅកាត់ថា "CIFRSs") ជាមួយនឹងការពន្យារពេលអនុវត្ត CIFRS 17 *កិច្ចសន្យាធានារ៉ាប់រង* និង CIFRS 9 *ឧបករណ៍ហិរញ្ញវត្ថុ* ស្របតាមសេចក្តីជូនដំណឹងរបស់ និយ័តករគណនេយ្យនិងសវនកម្ម (ហៅកាត់ថា "ន.គ.ស") ដែលអនុញ្ញាតឲ្យពន្យារពេលក្នុងការអនុវត្តស្តង់ដាទាំងនេះ។ ដូច្នេះហើយ ក្រុមហ៊ុនបានអនុវត្ត CIFRS 4 *កិច្ចសន្យាធានារ៉ាប់រង* ក្នុងការកត់ត្រាគណនេយ្យសម្រាប់កិច្ចសន្យាធានារ៉ាប់រង និង CIAS 39 *ការទទួលស្គាល់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ* ក្នុងការកត់ត្រាគណនេយ្យសម្រាប់ឧបករណ៍។ *(សូមមើលកំណត់សម្គាល់លេខ 4)*

### *2.2 ឆ្នាំសារពើពន្ធ និងការិយបរិច្ឆេទនៃការរាយការណ៍*

ឆ្នាំសារពើពន្ធរបស់ក្រុមហ៊ុនចាប់ផ្តើមនៅថ្ងៃទី1 ខែមករា និងបញ្ចប់នៅថ្ងៃទី31 ខែធ្នូ។

### *2.3 រូបិយប័ណ្ណវាស់វែង និងរូបិយប័ណ្ណបង្ហាញ*

រូបិយបិយវត្ថុជាតិ នៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល ("រៀល")។ ក៏ប៉ុន្តែ ដោយសារក្រុមហ៊ុនធ្វើប្រតិបត្តិការ និងរក្សាកំណត់ត្រាបញ្ជីគណនេយ្យរបស់ខ្លួនដោយផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក ("ដុល្លារអាមេរិក") គណៈគ្រប់គ្រងក្រុមហ៊ុនធ្វើការកំណត់ប្រាក់ដុល្លារអាមេរិក ជារូបិយប័ណ្ណសម្រាប់វាស់វែង និងដើម្បី ឆ្លុះបញ្ចាំងអំពីព្រឹត្តិការណ៍ និងកាលៈទេសៈសេដ្ឋកិច្ចរបស់ក្រុមហ៊ុន។

## 3. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត

### *3.1 រូបិយប័ណ្ណបរទេស*

*រូបិយប័ណ្ណបង្ហាញ*

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណ បង្ហាញរបស់ក្រុមហ៊ុន។

*ប្រតិបត្តិការ និងសមតុល្យ*

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗ ក្រៅពីដុល្លារអាមេរិក ត្រូវបានបកប្រែទៅជារូបិយប័ណ្ណមុខងារតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតពីអត្រាប្តូរប្រាក់ ដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ និងពីការបកប្រែនាចុងការិយបរិច្ឆេទ នៃទ្រព្យសកម្ម និងបំណុលរូបិយវត្ថុផ្សេងដែលមិនមែនជារូបិយប័ណ្ណដុល្លារអាមេរិក ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ប្រាក់លទ្ធផលពេញលេញ។

ការបកប្រែរូបិយប័ណ្ណដុល្លារអាមេរិកទៅជា (ពាន់រៀល) ត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្មនៃកម្ពុជា និងស្តង់ដា CIFRSs ជាមួយនឹងការពន្យារពេលអនុវត្ត CIFRS 17 និង CIFRS 9 ដោយប្រើប្រាស់អត្រាប្តូរប្រាក់នាចុងការិយបរិច្ឆេទ និងអត្រាជាមធ្យមប្រចាំឆ្នាំ។

ទ្រព្យសកម្ម និងបំណុលដែលបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ត្រូវបានបកប្រែតាម អត្រាចុងគ្រានាកាលបរិច្ឆេទរាយការណ៍ ដោយឡែកប្រាក់ចំណូល និងចំណាយ ដែលបានបង្ហាញក្នុងរបាយការណ៍លទ្ធផលពេញលេញ ត្រូវបានបកប្រែតាមអត្រាមធ្យមសម្រាប់ការិយបរិច្ឆេទបញ្ចប់។ ភាពខុសគ្នាដែលកើតឡើងពីការបកប្រែរូបិយប័ណ្ណនេះ ត្រូវទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលពេញលេញ។ ការបកប្រែនេះមិនគួរបកស្រាយថា ដុល្លារអាមេរិកដែលបានបង្ហាញ ឬ ត្រូវបាន ឬ អាចនឹងបកប្រែទៅជាប្រាក់រៀលតាមអត្រា អត្រាផ្សេងទៀតនោះទេ។ តម្លៃទាំងអស់គិតជាប្រាក់រៀលត្រូវបានបង្គត់ទៅជាខ្ទង់ពាន់ ("ពាន់រៀល") លើកលែងតែមានការកំណត់បង្ហាញក្រៅពីនេះ។

## 3. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### *3.1 រូបិយប័ណ្ណបរទេស* (តពីទំព័រមុន)

*ការបង្ហាញជាប្រាក់រៀល (តពីទំព័រមុន)*

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់រៀលដោយផ្អែកលើអត្រាប្តូរប្រាក់អនុវត្តដូចខាងក្រោមក្នុង 1 ដុល្លារអាមេរិកៈ

| | *2025* | *2024* |
|---|---|---|
| អត្រានាចុងគ្រា | 4,013 | 4,025 |
| អត្រាមធ្យម | 4,011 | 4,071 |

### *3.2 ចំណាត់ថ្នាក់នៃផលិតផល*

កិច្ចសន្យាធានារ៉ាប់រង គឺជាកិច្ចសន្យាដែលក្រុមហ៊ុនទទួលធានាហានិភ័យធានារ៉ាប់រងជាសារវន្ត ពីភាគីម្ខាងទៀត (ម្ចាស់ប័ណ្ណសន្យារ៉ាប់រង) ដោយយល់ព្រមសងជូនម្ចាស់ប័ណ្ណសន្យារ៉ាប់រង ឬ អ្នកទទួលផលប្រយោជន៍ ប្រសិនបើមានព្រឹត្តិការណ៍នាពេលអនាគតដែលមិនអាចគ្រោងទុក (ព្រឹត្តិការណ៍ដែលបានធានា) បានកើតឡើង។ ជាគោលការណ៍ណែនាំទូទៅ ក្រុមហ៊ុនកំណត់ថាមានហានិភ័យធានារ៉ាប់រងជាសារវន្ត ដោយប្រៀបធៀប ផលប្រយោជន៍ដែលបានបង់រួច ជាមួយនឹងផលប្រយោជន៍ដែលត្រូវទូទាត់ប្រសិនបើព្រឹត្តិការណ៍ដែលបានធានាមិនបានកើតឡើង។

នៅពេលដែលកិច្ចសន្យាត្រូវបានចាត់ជា កិច្ចសន្យាធានារ៉ាប់រង កិច្ចសន្យានោះនឹងនៅជាកិច្ចសន្យាធានារ៉ាប់រងរហូតដល់អាយុកាលនៃកិច្ចសន្យា ទោះបីជាហានិភ័យធានារ៉ាប់រងមានការថយចុះខ្លាំងក្នុងអំឡុងឆ្នាំក៏ដោយ លើកលែងតែសិទ្ធ និងកាតព្វកិច្ចទាំងអស់ត្រូវបានសងផ្តាច់ ឬផុតកំណត់។ ប៉ុន្តែកិច្ចសន្យាវិនិយោគ អាចត្រូវបានចាត់ថ្នាក់ជាកិច្ចសន្យាធានារ៉ាប់រង បន្ទាប់ពីបានចាប់ផ្តើម ប្រសិនបើហានិភ័យធានារ៉ាប់រងមានភាពជាសារវន្ត។

### *3.3 ទ្រព្យ និងបរិក្ខារ*

ទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាតាមតម្លៃដើម ដករំលស់បង្គរ។ ថ្លៃដើមនៃទ្រព្យសកម្មរួមមានចំណាយលើការទិញ និងចំណាយផ្ទាល់ផ្សេងៗ ដើម្បីធ្វើឲ្យទ្រព្យសកម្មស្ថិតក្នុងលក្ខខណ្ឌអាចដំណើរការ និងទីតាំងទៅតាមអ្វីដែលបានរំពឹងសម្រាប់ប្រើប្រាស់។ តម្លៃយោងត្រូវបានត្រួតពិនិត្យឡើងវិញនៅរៀងរាល់កាលបរិច្ឆេទនីមួយៗ ដើម្បីវាយតម្លៃថាតើ តម្លៃយោងទាំងនេះត្រូវបានកត់ត្រាលើសតម្លៃដែលអាចទទួលបានមកវិញដែរឬទេ ហើយប្រសិនបើតម្លៃយោងលើសពីតម្លៃដែលអាចទទួលបានមកវិញ ទ្រព្យសកម្មទាំងនោះនឹងត្រូវកត់ត្រាបន្ថយតាមតម្លៃដែលអាចទទួលបានមកវិញ។ នៅពេលដែលទ្រព្យសកម្មត្រូវបានលក់ ថ្លៃដើមនិងរំលស់បង្គររបស់ទ្រព្យសកម្មនោះត្រូវបានលុបចេញពីបញ្ជី ហើយលទ្ធផលចំណេញ ឬ ខាតមកពីការលក់នេះត្រូវបានកត់ត្រាក្នុង របាយការណ៍ប្រាក់ចំណេញ ពេញលេញ។

រំលស់នៃទ្រព្យ និងបរិក្ខារត្រូវបានគណនាតាមវិធីសាស្ត្ររំលស់ថេរ លើអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម ដូចខាងក្រោមៈ

| | |
|---|---|
| ការកែលម្អអគារជួល | 5ឆ្នាំ |
| បរិក្ខាការិយាល័យ | 5ឆ្នាំ |
| គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ | 5ឆ្នាំ |
| យានយន្ត | 5ឆ្នាំ |

ថ្លៃជួសជុល និងការថែទាំ ដែលបានកើតឡើងក្នុងការថែរក្សាទ្រព្យ និងបរិក្ខារដើម្បីឲ្យស្ថិតក្នុងលក្ខខណ្ឌអាចដំណើរការជាធម្មតាបានត្រូវកត់ត្រាជាចំណាយនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។ ការកែលម្អ នឹងត្រូវធ្វើមូលធនកម្ម និងរំលស់ទៅតាមអាយុកាលប្រើប្រាស់បន្ថែមរបស់វា។

ទ្រព្យសកម្មដែលបានរំលស់អស់ទាំងស្រុង ត្រូវបានរក្សាទុកនៅក្នុងបញ្ជីគណនីរហូតដល់ទ្រព្យសកម្មទាំងនោះ ត្រូវបានឈប់ប្រើប្រាស់ និងមិនមានការរំលស់លើទ្រព្យសកម្មទាំងនោះទៀតទេ។

## 3. **ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត** (តពីទំព័រមុន)

### *3.4 ទ្រព្យសកម្មអរូបី*

កម្មវិធីកុំព្យូទ័រ និងអាជ្ញាប័ណ្ណត្រូវបានទិញដោយឡែកពីគ្នា និងវាស់វែងទៅតាមថ្លៃដើមនាពេលដំបូង។ តាមការទទួលស្គាល់ដំបូង កម្មវិធីកុំព្យូទ័រ និងអាជ្ញាប័ណ្ណយោងតាមតម្លៃដើមដករំលស់បង្គរ និងការខាតបង់អ៊ឹមភែរមិនបង្គរ។

ប្រសិនបើមានការចង្អុលបង្ហាញថាមានការផ្លាស់ប្តូរជាសារវន្តក្នុងអត្រារំលស់ ឬ អាយុកាលប្រើប្រាស់នៃទ្រព្យសកម្មអរូបី រំលស់ត្រូវបានកែប្រែនាពេលអនាគត ដើម្បីឆ្លុះបញ្ចាំងពីការរំពឹងទុកថ្មី។

រំលស់ត្រូវបានទទួលស្គាល់ក្នុងប្រាក់ចំណេញ ឬ ខាតតាមមូលដ្ឋានវិធីសាស្រ្តរំលស់ថេរដូចខាងក្រោម៖

| | |
|---|---|
| កម្មវិធីកុំព្យូទ័រ | 10ឆ្នាំ |
| អាជ្ញាប័ណ្ណ | 5ឆ្នាំ |

### *3.5 ភតិសន្យា*

ក្រុមហ៊ុនធ្វើការវាយតម្លៃការចាប់ផ្តើមកិច្ចសន្យា ថាតើកិច្ចសន្យាមាន ឬ រួមមានភតិសន្យា ឬទេ។ ជាភតិសន្យា ប្រសិនបើកិច្ចសន្យានោះមានសិទ្ធិគ្រប់គ្រងការប្រើប្រាស់ នៃទ្រព្យសកម្ម ដែលបានកំណត់ក្នុងការិយបរិច្ឆេទមួយជាថ្នូរនឹងថ្លៃឈ្នួល។

*ក្រុមហ៊ុនជាភតិក:*

ក្រុមហ៊ុន អនុវត្តវិធីសាស្រ្តទទួលស្គាល់ និងវាស់វែងតែមួយសម្រាប់ភតិសន្យាទាំងអស់ លើកលែងតែ ការជួលរយៈពេលខ្លី និងការជួលទ្រព្យកម្មដែលមានតម្លៃទាប។ ក្រុមហ៊ុនទទួលស្គាល់បំណុលភតិសន្យាដើម្បីទូទាត់ការជួល និងសិទ្ធិប្រើប្រាស់នៃទ្រព្យសកម្ម ដែលតំណាងឲ្យសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម។

*សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម*

ក្រុមហ៊ុនទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម គិតត្រឹមកាលបរិច្ឆេទចាប់ផ្តើមនៃ ភតិសន្យា(ឧទាហរណ៍៖ កាលបរិច្ឆេទទ្រព្យសកម្មមានសម្រាប់ប្រើប្រាស់)។ សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានវាស់វែងតាមថ្លៃដើមដកការរំលស់បង្គរ និងអ៊ឹមភែរមិនដែលបាត់បង់ និងត្រូវបានកែតម្រូវសម្រាប់ការវាយតម្លៃឡើងវិញនូវបំណុលភតិសន្យា។ ថ្លៃដើមនៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម រួមបញ្ចូលការទទួលស្គាល់ប្រាក់បំណុលភតិសន្យា ថ្លៃដើមដំបូងដែលបានកើតឡើង និងការទូទាត់ភតិសន្យានៅថ្ងៃចាប់ផ្តើម ឬ មុនថ្ងៃចាប់ផ្តើមកាលបរិច្ឆេទ ដកអត្ថប្រយោជន៍ដែលទទួលបាន។
សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានរំលស់ដោយផ្អែកលើវិធីសាស្រ្តរំលស់ថេរ ក្នុងរយៈពេលខ្លីណាមួយនៃរយៈពេលជួល និងការប៉ាន់ស្មានអាយុកាលនៃការប្រើប្រាស់របស់ទ្រព្យសកម្ម ដូចខាងក្រោម៖

| | |
|---|---|
| អាគារការិយាល័យ | រយៈពេលជួល៖ 3ឆ្នាំ និង 5ឆ្នាំ |

សិទ្ធប្រើប្រាស់ទ្រព្យសកម្មក៏នឹងអាចមានអ៊ឹមភែរមិនផងដែរ *(កំណត់សម្គាល់លេខ 3.10)*។

*បំណុលភតិសន្យា*

នៅកាលបរិច្ឆេទចាប់ផ្តើមនៃភតិសន្យា ក្រុមហ៊ុនទទួលស្គាល់បំណុលភតិសន្យា ដែលត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាដែលនិងត្រូវធ្វើឡើងក្នុងរយៈពេលនៃការជួល។ ការទូទាត់ភតិសន្យារួមមានការទូទាត់ថេរ (រួមបញ្ចូលទាំងការទូទាត់ថេរ) ដកថ្លៃជួលដែលអាចទទួលបាន ការទូទាត់ភតិសន្យាអថេរអាស្រ័យលើសន្ទស្សន៍ ឬអត្រាមួយ ទឹកប្រាក់ដែលរំពឹងថានឹងត្រូវបង់ក្រោមការធានាលើតម្លៃនៅសល់។ ការទូទាត់ការជួលក៏រួមបញ្ចូលផងដែរនូវជម្រើសតម្លៃទិញ ដែលសមស្របដែលត្រូវអនុវត្តដោយក្រុមហ៊ុន និងការបង់ប្រាក់ពិន័យសម្រាប់ការបញ្ចប់កិច្ចសន្យាជួលប្រសិនបើរយៈពេលជួលនោះឆ្លុះបញ្ចាំងពីក្រុមហ៊ុន ដែលប្រើជម្រើសដើម្បីបញ្ចប់កិច្ចសន្យា។ ការទូទាត់ភតិសន្យាអថេរ ដែលមិនអាស្រ័យលើអត្រាណាមួយ ត្រូវបានទទួលស្គាល់ជាការចំណាយ (លើកលែងតែការទូទាត់នោះកើតឡើងដើម្បីផលិតសន្និធិ) ក្នុងការិយបរិច្ឆេទដែលព្រឹត្តិការណ៍ ឬ លក្ខខណ្ឌដែលបង្កឲ្យមានការទូទាត់កើតឡើង។

## 3. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### *3.5 ភតិសន្យា* (តពីទំព័រមុន)

ក្នុងការគណនាតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យា ក្រុមហ៊ុនបានប្រើប្រាស់អត្រាការប្រាក់កម្ចីដែលសមស្រប របស់ខ្លួននៅកាលបរិច្ឆេទចាប់ផ្តើមនៃភតិសន្យា ព្រោះអត្រាការប្រាក់ជាក់ស្តែងនៅក្នុងភតិសន្យា មិនអាចកំណត់បានភ្លាមៗ។ បន្ទាប់ពីកាលបរិច្ឆេទចាប់ផ្តើម ចំនួនទឹកប្រាក់នៃបំណុលភតិសន្យាត្រូវបានកើនឡើងដើម្បីទទួលស្គាល់នៃការប្រាក់ និងការកាត់បន្ថយសម្រាប់ការទូទាត់ថ្លៃភតិសន្យា។ លើសពីនេះទៀតតម្លៃយោងនៃបំណុលភតិសន្យា ត្រូវបានវាស់វែងឡើងវិញបើមានការកែប្រែ ការផ្លាស់ប្តូរនៃរយៈពេលរបស់ភតិសន្យា ការផ្លាស់ប្តូរនៃការទូទាត់ភតិសន្យា (ឧទាហរណ៍ ការផ្លាស់ប្តូរការទូទាត់នាពេលអនាគតដែលបណ្តាលមកពីផ្លាស់ប្តូរអត្រាការប្រាក់ ប្រើប្រាស់ដើម្បីកំណត់ការជួលទាំងនោះ) ឬ ការផ្លាស់ការវាយតម្លៃនៃជម្រើស ដើម្បីទិញទ្រព្យសកម្ម។

*ភតិសន្យារយៈពេលខ្លី និងភតិសន្យាទ្រព្យសកម្មតម្លៃទាប*

ក្រុមហ៊ុនបានជ្រើសរើសមិនទទួលស្គាល់សិទ្ធប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យាសម្រាប់ភតិសន្យារយៈពេលខ្លីដែលមានរយៈពេលជួល 12ខែ ឬតិចជាងនេះ និងភតិសន្យាទ្រព្យសកម្មដែលមានតម្លៃទាប។ ក្រុមហ៊ុនទទួលស្គាល់ការទូទាត់ភតិសន្យាដែលពាក់ព័ន្ធនឹង ភតិសន្យាទាំងនេះជាចំណាយតាមវិធីសាស្ត្ររំលស់ថេរលើរយៈនៃពេលភតិសន្យា។

### *3.6 ទ្រព្យសកម្មហិរញ្ញវត្ថុ*

*ការទទួលស្គាល់ និងការវាស់វែង*

ទ្រព្យសកម្មហិរញ្ញវត្ថុក្នុងវិសាលភាពនៃ CIAS 39 ត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មហិរញ្ញវត្ថុក្នុងតម្លៃសមស្របតាមរយៈប្រាក់ចំណេញ ឬខាត។ ក្រុមហ៊ុនកំណត់ចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួននៅពេលទទួលស្គាល់ដំបូង។

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ ត្រូវបានទទួលស្គាល់ដំបូងនៅតម្លៃសមស្រប (ក្នុងករណីការវិនិយោគមិនមានការទទួលស្គាល់តាមតម្លៃសមស្របនៅក្នុងប្រាក់ចំណេញ ឬខាត) រួមទាំងចំណាយប្រតិបត្តិការផ្ទាល់។

ចំណាត់ថ្នាក់អាស្រ័យលើគោលបំណងដែលការវិនិយោគត្រូវបានទិញ ឬ បង្កើតឡើង។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់នៅតម្លៃសមស្របតាមរយៈប្រាក់ចំណេញ ឬ ខាតដែលជាយុទ្ធសាស្ត្រវិនិយោគរបស់ក្រុមហ៊ុន ត្រូវបានចាត់ចែងដើម្បីគ្រប់គ្រងការវិនិយោគហិរញ្ញវត្ថុដោយផ្អែកលើតម្លៃសមស្របជាមូលដ្ឋាន ដោយសារតែបំណុលដែលពាក់ព័ន្ធត្រូវបានគ្រប់គ្រងតាមមូលដ្ឋាននេះផងដែរ។ បំណុលដែលពាក់ព័ន្ធ (រួមបញ្ចូលទាំងវិភាគទានភាគទុនិក) ត្រូវបានគ្រប់គ្រង ឬយោងតាម រំលស់ថ្លៃដើម។

*ការទទួលស្គាល់ និងការវាស់វែង* (តពីទំព័រមុន)

ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមបញ្ចូលដូចជា សាច់ប្រាក់ និងសាច់ប្រាក់សមមូល ទ្រព្យសកម្មធានារ៉ាប់រងបន្ត ប្រាក់បញ្ញើនៅធនាគារ បុព្វលាភធានារ៉ាប់ត្រូវទទួល គណនីត្រូវទទួលពីភាគីពាក់ព័ន្ធ ដែលត្រូវបានចាត់ថ្នាក់ជាឥណទាន និងគណនីត្រូវទទួល។

*ឥណទាន និងគណនីត្រូវទទួល*

ទ្រព្យសកម្មហិរញ្ញវត្ថុមិនមែនកិច្ចសន្យានិស្សន្ទ (non-derivative financial assets) ជាមួយការទូទាត់ ថេរ ឬអាចកំណត់ការទូទាត់ដែលមិនបានស្រង់តម្លៃតាមទីផ្សារត្រូវបានចាត់ទុកជា ឥណទាន និងគណនីត្រូវទទួល។ ការវិនិយោគទាំងនេះត្រូវបានទទួលស្គាល់ដំបូងតាមមូលដ្ឋាន ថ្លៃដើមជាតម្លៃទីផ្សារ ដែលជាចំណាយនៃការទូទាត់ទិញតាមតម្លៃសមស្របនៃការវិនិយោគនេះ។ រាល់ចំណាយប្រតិបត្តិការដែលពាក់ព័ន្ធដោយផ្ទាល់ទាំងអស់ ក៏ត្រូវបានដាក់បញ្ចូលទៅក្នុងថ្លៃដើមវិនិយោគផងដែរ។ បន្ទាប់ពីការវាស់វែងដំបូង ឥណទាន និងគណនីត្រូវទទួលត្រូវបានវាស់វែង ជាបន្តបន្ទាប់តាមរំលស់ថ្លៃដើមដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព (EIR) ដកចេញអ៊ីមភែរមិន។ ចំណេញ និងខាតត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ នៅពេលដែលឥណទាន និងគណនីត្រូវទទួលឈប់ទទួលស្គាល់ ឬ មានអ៊ីមភែរមិនព្រមទាំងតាមរយៈដំណើរការរំលស់។

*អ៊ីមភែរមិននៃទ្រព្យសកម្មហិរញ្ញវត្ថុ*

នៅរៀងរាល់កាលបរិច្ឆេទតារាងតុល្យការនីមួយៗ ក្រុមហ៊ុនធ្វើការវាយតម្លៃថាតើមានភស្តុតាងពិតប្រាកដណាមួយដែលបង្ហាញថាទ្រព្យសកម្មហិរញ្ញវត្ថុមួយ ឬជាក្រុមណាមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានអ៊ីមភែរដែរឬទេ។

**3. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត** (តពីទំព័រមុន)

***3.6 ទ្រព្យសកម្មហិរញ្ញវត្ថុ*** (តពីទំព័រមុន)

*អ៊ីមភែរមិននៃទ្រព្យសកម្មហិរញ្ញវត្ថុ* (តពីទំព័រមុន)

*(ក) តម្លៃយោងទ្រព្យសកម្មតាមរំលស់ថ្លៃដើម*

ប្រសិនបើមានភស្តុតាងដែលអះអាងថាពិតជាមានការខាតដោយសារអ៊ីមភែរមិន លើឥណទាន និងគណនីត្រូវទទួលដែលមានតម្លៃយោងរំលស់ថ្លៃដើមបានកើតឡើង តម្លៃខាតបង់នោះនឹងត្រូវបានវាស់វែងនៃភាពខុសគ្នារវាងតម្លៃក្នុងបញ្ជី និងតម្លៃបច្ចុប្បន្នទ្រព្យសកម្មនៃលំហូរសាច់ប្រាក់នាពេលអនាគត ត្រូវបានប៉ាន់ស្មាន ដែលធ្វើអប្បហារទៅតាមអត្រាការប្រាក់មានប្រសិទ្ធភាព (ឧទាហរណ៍ អត្រាការប្រាក់មានប្រសិទ្ធភាពត្រូវបានគណនាពេលទទួលស្គាល់ដំបូង) របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ តម្លៃយោងនៃទ្រព្យសកម្មនឹងត្រូវបានកាត់បន្ថយតាមរយៈការប្រើគណនីសំវិធានធន។ ការខាតបង់នឹងត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណេញ ឬ ខាត។

នៅគ្រាបន្តបន្ទាប់ ប្រសិនបើចំនួនទឹកប្រាក់ខាតបង់ទៅលើអ៊ីមភែរមិនមានការថយចុះ ហើយការថយចុះនោះ អាចពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ដែលកើតឡើងក្រោយពី អ៊ីមភែរមិននោះត្រូវបានទទួលស្គាល់ នោះចំនួនទឹកប្រាក់ខាតបង់ទៅលើអ៊ីមភែរមិនបាត់បង់ដែលទទួលស្គាល់ពីមុននោះនឹងត្រូវកត់បញ្ច្រាស់មកវិញ ក្នុងកម្រិតមួយដែលតម្លៃចុះបញ្ជីរបស់ទ្រព្យសកម្មនោះមិនលើសពីរំលស់ថ្លៃដើមនៅកាលបរិច្ឆេទចុះកត់ត្រាបញ្ច្រាស់នោះ។ ការកត់ត្រាបញ្ច្រាស់បន្តបន្ទាប់នៃចំនួនការខាតបង់ទៅលើអ៊ីមភែរមិនត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណេញ និងខាត។

*ការឈប់ទទួលស្គាល់នៃទ្រព្យសកម្មហិរញ្ញវត្ថុ*

ទ្រព្យសកម្មហិរញ្ញវត្ថុ (ឬប្រសិនបើមានផ្នែកមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ ផ្នែកនៃទ្រព្យសកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលស្រដៀងគ្នា) ត្រូវឈប់ទទួលស្គាល់នៅពេលដែល៖

- សិទ្ធិទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្មបានផុតកំណត់
- ក្រុមហ៊ុនបានផ្ទេរសិទ្ធិរបស់ខ្លួនក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្ម ឬ បានសន្មតថាកាតព្វកិច្ចដែលត្រូវបង់ នៃលំហូរសាច់ប្រាក់ដែលទទួលបានពេញលេញ ដោយគ្មានការពន្យារពេលជាសារវន្តដល់ភាគីទីបីក្រោមការរៀបចំ ”Pass-through” ឬ
- ណាមួយនៃ (ក) ក្រុមហ៊ុនបានផ្ទេរនូវរាល់ហានិភ័យនិងផលប្រយោជន៍នៃទ្រព្យសកម្មទាំងស្រុង ឬ (ខ) ក្រុមហ៊ុនមិនបានផ្ទេរ ឬរក្សាទុកនូវរាល់ហានិភ័យ និងផលប្រយោជន៍ នៃទ្រព្យសកម្មទេ ប៉ុន្តែបានផ្ទេរការគ្រប់គ្រងទ្រព្យសកម្មនោះវិញ។

នៅពេលដែលក្រុមហ៊ុនបានផ្ទេរសិទ្ធិរបស់ខ្លួន ក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្ម ឬ បានរៀបចំតាមរយៈការឆ្លងកាត់ (pass-though arrangement) ហើយមិនបានផ្ទេរ ឬ រក្សាទុកនូវរាល់ហានិភ័យ និងផលប្រយោជន៍ទ្រព្យសកម្មទាំងអស់ រួមទាំងមិនបានផ្ទេរការគ្រប់គ្រងទ្រព្យសកម្មនោះដែរ ទ្រព្យសកម្មត្រូវបានទទួលស្គាល់ ក្នុងកម្រិតណាមួយដែលក្រុមហ៊ុនបន្តមានការទាក់ទង នៅក្នុងទ្រព្យសកម្មនោះ។ ការបន្តមានទំនាក់ទំនងដែលបង្កើតជាទម្រង់នៃការធានាលើការផ្ទេរទ្រព្យសកម្មត្រូវបានវាស់វែងនៃតម្លៃ ដែលទាបជាងរវាងតម្លៃយោងដើមនៃទ្រព្យសកម្ម ហើយនិងតម្លៃនៃការគិតគូរអតិបរិមាដែលក្រុមហ៊ុនតម្រូវឲ្យសងវិញ។

**3. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត** (តពីទំព័រមុន)

*3.7 គណនីធានារ៉ាប់រងត្រូវទទួល*

គណនីធានារ៉ាប់រងត្រូវទទួល ត្រូវបានទទួលស្គាល់នៅពេលដល់កំណត់ត្រូវបង់ និងត្រូវបានវាស់វែងតាមការទទួលស្គាល់លើកដំបូងតាមតម្លៃទីផ្សារនៃចំនួនទទួលបាន ឬអាចទទួលបាន។ បន្ទាប់ពីការទទួលស្គាល់លើកដំបូង គណនីធានារ៉ាប់រងត្រូវទទួលត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព។ តម្លៃយោងនៃគណនីធានារ៉ាប់រងត្រូវទទួល ត្រូវបានត្រួតពិនិត្យរកអ៊ីមភែរមិន នៅពេលមានព្រឹត្តិការណ៍ ឬកាលៈទេសៈបង្ហាញថាតម្លៃយោងអាចនឹងមិនអាចប្រមូលមកវិញបាន ហើយខាតនៃ អ៊ីមភែរមិនត្រូវបានកត់ត្រាក្នុងចំណេញ ឬ ខាត។

*ធានារ៉ាប់រងបន្ត និងគណនីត្រូវទទួលផ្សេងៗ*

ក្រុមហ៊ុនផ្ទេរហានិភ័យលើការធានារ៉ាប់រង នៅក្នុងដំណើរការអាជីវកម្មធម្មតាសម្រាប់ដំណើរការអាជីវកម្មទាំងអស់របស់ខ្លួន។ ទ្រព្យសកម្មធានារ៉ាប់រងបន្ត គឺសមតុល្យដែលត្រូវទទួលពីក្រុមហ៊ុនធានារ៉ាប់រងបន្ត។ ចំនួនទឹកប្រាក់ ដែលអាចប្រមូលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តត្រូវបានប៉ាន់ស្មានស្របតាមលក្ខណៈ នៃការទាមទារសំណងឬសំណងដែលបានទូទាត់ទាក់ទង នឹងគោលយោបាយរបស់អ្នកធានារ៉ាប់រងហើយស្របតាមកិច្ចសន្យាធានារ៉ាប់រងដែលពាក់ព័ន្ធ។

ទ្រព្យសកម្មធានារ៉ាប់រងបន្ត ត្រូវបានពិនិត្យឡើងវិញចំពោះ អ៊ីមភែរមិន នាកាលបរិច្ឆេទរបាយការណ៍នីមួយៗឬ ញឹកញាប់ជាងនេះនៅពេលដែលការបង្ហាញពីអ៊ីមភែរ មិនកើតឡើងក្នុង អំឡុងការិយបរិច្ឆេទ នៃរបាយការណ៍។ អ៊ីមភែរមិនកើតឡើងនៅពេលដែលមានភស្តុតាងពិតប្រាកដ ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ដែលបានកើតឡើងបន្ទាប់ពីការទទួលស្គាល់ដំបូង នៃទ្រព្យសកម្មធានារ៉ាប់រងបន្តដែលក្រុមហ៊ុនអាចនឹងមិនទទួលបាននូវតម្លៃ ដែលនៅសល់ដោយផ្អែកលើលក្ខខណ្ឌ នៃកិច្ចសន្យា និងព្រឹត្តិការណ៍មានផលប៉ះពាល់ដែលអាចវាស់វែងបានគួរឲ្យទុកចិត្តលើតម្លៃដែលក្រុមហ៊ុននឹងទទួលបានពីអ្នកធានារ៉ាប់រងបន្ត។ ការខាតអ៊ីមភែរមិន ត្រូវបានកត់ត្រានៅក្នុងប្រាក់ចំណេញ ឬខាត។

ការរៀបចំកិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត មិនធ្វើឲ្យក្រុមហ៊ុនគេចពីកាតព្វកិច្ចរបស់ខ្លួនចំពោះម្ចាស់បណ្ណ័សន្យាធានារ៉ាប់រងឡើយ។ បុព្វលាភរ៉ាប់រង និងការទាមទារសំណងត្រូវបានបង្ហាញតាមមូលដ្ឋានដុល និងការធានារ៉ាប់រងបន្តដែលបានផ្ទេរចេញត្រូវបានបង្ហាញដោយឡែក។ ទ្រព្យសកម្មធានារ៉ាប់រងបន្តត្រូវបានឈប់ទទួលស្គាល់នៅពេលដែលសិទ្ធិតាមកិច្ចសន្យាត្រូវបានសងផ្តាច់ ឬ ផុតកំណត់។

*3.8 ភាគីពាក់ព័ន្ធ*

ភាគី ត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធនៅពេលដែលសមាជិកក្រុមប្រឹក្សាភិបាល ឬ ក្រុមហ៊ុនមានលទ្ធភាពដោយផ្ទាល់ ឬ ដោយប្រយោលក្នុងការគ្រប់គ្រងភាគីនោះ ឬមានឥទ្ធិពលជាសារវន្ត ទៅលើភាគីនោះក្នុងការសម្រេចចិត្តលើផ្នែកប្រតិបត្តិការ និងហិរញ្ញវត្ថុ ឬ បញ្ច្រាស់មកវិញ ឬ នៅពេលដែលក្រុមហ៊ុន និងភាគីនោះស្ថិតនៅ ក្រោមការគ្រប់គ្រង ឬឥទ្ធិពលជាសារវន្តតែមួយ។ ភាគីពាក់ព័ន្ធអាចជារូបវន្តបុគ្គល ឬក្រុមហ៊ុន។

ប្រតិបត្តិការសំខាន់ៗជាមួយភាគីពាក់ព័ន្ធទាំងអស់ រួមមានការវិនិយោគ ឥណទាន ការទូទាត់ជាមុន ត្រូវបានបង្ហាញនៅក្នុង *កំណត់សម្គាល់លេខ 22* នៃរបាយការណ៍ហិរញ្ញវត្ថុ។

*3.9 សាច់ប្រាក់ និងសាច់ប្រាក់សមមូល*

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់ក្នុងដៃ សាច់ប្រាក់នៅធនាគារ ប្រាក់បញ្ញើតាមតម្រូវការជាមួយធនាគារ និងការវិនិយោគដែលមានលទ្ធភាពបង្វិលជាសាច់ប្រាក់ខ្ពស់ក្នុងរយៈពេលខ្លី ដែលមានកាលកំណត់ដំបូងរយៈពេល 3ខែ ឬក៏តិចជាងនេះដែលងាយបំលែងទៅជាសាច់ប្រាក់ ហើយដែលអាចប្រឈមនឹងហានិភ័យតិចតួច និងបម្រែបម្រួលតម្លៃ។

*3.10 អ៊ីមភែរមិននៃទ្រព្យសកម្មមិនមែនឧបករណ៍ហិរញ្ញវត្ថុ*

ក្រុមហ៊ុននឹងត្រួតពិនិត្យ នាកាលបរិច្ឆេទរបាយការណ៍នីមួយៗ ថាតើមានភស្តុតាងបង្ហាញថា ទ្រព្យសកម្មអាចនឹងមានការត្រូវបានអ៊ីមភែរដែរ ឬទេ។ ទ្រព្យសកម្មដែលអាចរំលស់ត្រូវបានត្រួតពិនិត្យលើអ៊ីមភែមិននៅពេលដែលព្រឹត្តិការណ៍ ឬបម្រែបម្រួលនៃកាលៈទេសៈបង្ហាញថាតម្លៃយោងមិនអាចប្រមូលមកវិញបាន។ ការខាតអ៊ីមភែរមិន ត្រូវបានទទួលស្គាល់ពេលដែលតម្លៃយោងរបស់ទ្រព្យសកម្មលើសពីតម្លៃដែលប្រមូលបានមកវិញ។ តម្លៃដែលប្រមូលបានវិញ គឺតម្លៃខ្ពស់ជាងនៃតម្លៃសមស្របនៃទ្រព្យសកម្ម ដកថ្លៃដើមដើម្បីលក់ និងតម្លៃនៃការប្រើប្រាស់។ ក្នុងគោលបំណងនៃការវាយតម្លៃលើអ៊ីមភែរមិន ទ្រព្យសកម្មត្រូវបានចាត់ជាក្រុមនៅកម្រិតទាបបំផុតដែលមានលំហូរសាច់ប្រាក់ដែលអាចសម្គាល់បានដាច់ដោយឡែក (ឧបករណ៍បង្កើតសាច់ប្រាក់)។

## 3. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### *3.11 ដើមទុន*

ភាគហ៊ុនធម្មតាដែលបែងចែកភាគលាភតាមការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានចាត់ទុកជាមូលធន។ ការបែងចែកភាគលាភទៅភាគទុនិកត្រូវកត់ត្រាដោយផ្ទាល់ក្នុងមូលធន។

ភាគលាភសម្រាប់ភាគហ៊ុនធម្មតាដែលបានប្រកាសមុនការិយបរិច្ឆេទរបាយការណ៍ ត្រូវកត់ត្រាជាបំណុល។ ភាគលាភដែលបានប្រកាសក្រោយកាលបរិច្ឆេទប៉ុន្តែមុនពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុម័តមិនត្រូវបានកត់ត្រាជាបំណុលទេ។

ប្រាក់កក់សម្រាប់ការទិញភាគហ៊ុននាពេលអនាគត តំណាងឲ្យចំនួនទឹកប្រាក់ដែលទទួលបានពីភាគទុនិកទាក់ទងនឹងផែនការរបស់ក្រុមហ៊ុនក្នុងការបង្កើនដើមទុនភាគហ៊ុនរបស់ខ្លួន។ គណនីនេះត្រូវបានទទួលស្គាល់ដោយផ្អែកលើចំនួនទឹកប្រាក់ដែលទទួលបាន។

### *3.12 សំវិធានធន*

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុន មានកាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ចដែលជាលទ្ធផលនៃព្រឹត្តការណ៍អតីតកាល និងការហូរចេញនៃផលប្រយោជន៍សេដ្ឋកិច្ចអាចកើតឡើងដើម្បីទូទាត់កាតព្វកិច្ចទាំងនោះ។ ប្រសិនបើការប៉ះពាល់ពីការទូទាត់នេះមានភាពសារវន្ត សំវិធានធនត្រូវបានកំណត់ដោយធ្វើ អប្បហារលើលំហូរសាច់ប្រាក់ដែលរំពឹងទុកតាមអត្រាមុនពន្ធ ដែលឆ្លុះបញ្ចាំងការប៉ាន់ស្មាន បច្ចុប្បន្ននៃតម្លៃពេលវេលា នៃសាច់ប្រាក់ និងប្រសិនបើសមរម្យហានិភ័យជាក់លាក់នៃបំណុល។

### *3.13 បំណុលហិរញ្ញវត្ថុ*

*ការទទួលស្គាល់ និងវាស់វែង*

បំណុលហិរញ្ញវត្ថុក្នុងវិសាលភាពនៃ CIAS39 ត្រូវបានចាត់ថ្នាក់ជាបំណុលហិរញ្ញវត្ថុក្នុងតម្លៃសមស្របតាមរយៈប្រាក់ចំណេញ ឬខាតដែលរួមមាន ឥណទាន និងកម្ចី ឬកិច្ចសន្យាធានាហិរញ្ញវត្ថុ។ បំណុលហិរញ្ញវត្ថុទាំងនេះ មិនបានរាប់បញ្ចូលក្នុងបំណុលកិច្ចសន្យាធានារ៉ាប់រងទេ។ ក្រុមហ៊ុនកំណត់ចំណាត់ថ្នាក់នៃបំណុលហិរញ្ញវត្ថុរបស់ខ្លួននៅពេលទទួលស្គាល់ដំបូង។

រាល់បំណុលហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់ដំបូងនៅតម្លៃសមស្រប ហើយក្នុងករណីជាឥណទាន និងកម្ចីចំណាយប្រតិបត្តិការដោយផ្ទាល់ត្រូវបានដកចេញ។

បំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមមានធានារ៉ាប់រង និងគណនីត្រូវទូទាត់ផ្សេងៗរួមទាំងតម្លៃត្រូវ ទូទាត់ទៅភាគីពាក់ពន្ធ។

*ឥណទាន និងកម្ចី*

ក្រោយពេលទទួលស្គាល់ដំបូង ឥណទាន និងកម្ចីមានការប្រាក់ត្រូវបានវាស់វែងជាបន្តបន្ទាប់ដោយរំលស់ដែលប្រើប្រាស់វិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព។ ចំណេញ និងខាតត្រូវទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលពេញលេញ នៅពេលដែលបំណុលត្រូវបានបញ្ចប់ការទទួលស្គាល់ តាមរយៈការរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាពផងដែរ។

រំលស់ថ្លៃដើមត្រូវបានគណនាដោយគិតគូរពីការបញ្ចុះតម្លៃ ឬ បុព្វលាភណាមួយលើការទិញយក និងសេវា ឬ ចំណាយជាផ្នែកសំខាន់នៃវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព។ វិធីសាស្ត្ររំលស់អត្រាការប្រាក់មានប្រសិទ្ធិភាព ត្រូវបានបញ្ចូលទៅក្នុងចំណាយហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

*ការឈប់ទទួលស្គាល់*

បំណុលហិរញ្ញវត្ថុ ត្រូវបានឈប់ទទួលស្គាល់នៅពេលដែលកាតព្វកិច្ចស្ថិតក្រោមការទទួលខុសត្រូវត្រូវបានរំសាយ ឬលុបចោល ឬផុតកំណត់។ នៅពេលបំណុលហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយអ្នកផ្តល់ប្រាក់កម្ចីដូចគ្នាលើលក្ខខណ្ឌខុសគ្នាច្រើន ឬលក្ខខណ្ឌនៃបំណុលដែលមានស្រាប់ត្រូវបានកែប្រែយ៉ាងខ្លាំងដូចជាបម្រែបម្រួល ឬការកែប្រែត្រូវបានចាត់ទុកថាជាការមិនទទួលស្គាល់បំណុលដើម និងការទទួលស្គាល់បំណុលថ្មី និងភាពលម្អៀងគ្នានៃតម្លៃបញ្ជីនីមួយៗត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

## 3. **ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត** (តពីទំព័រមុន)

### *3.14 ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ*

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយតម្លៃយោងសុទ្ធត្រូវបានបង្ហាញនៅរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលក្រុមហ៊ុនមានសិទ្ធតាមផ្លូវច្បាប់ដើម្បីទូទាត់ និងមានបំណងក្នុងការទូទាត់លើមូលដ្ឋានតម្លៃសុទ្ធ ឬ ដើម្បីទទួលស្គាល់ទ្រព្យសកម្ម និងបំណុលនៅពេលដំណាលគ្នា។

### *3.15 បំណុលកិច្ចសន្យាធានារ៉ាប់រង*

បំណុលកិច្ចសន្យាធានារ៉ាប់រង ដែលរួមបញ្ចូលនូវប្រាក់បម្រុងសម្រាប់បុព្វលាភធានារ៉ាប់រងមិនទាន់ទទួលស្គាល់ (unearned premium reserve) ប្រាក់បម្រុងសម្រាប់សំណងមិនទាន់ទូទាត់ (outstanding claim reserve) ប្រាក់បម្រុងសម្រាប់សំណងដែលបានកើតឡើងប៉ុន្តែមិនទាន់បានរាយការណ៍ (IBNR) និងសំវិធានធនសម្រាប់អត្ថប្រយោជន៍ត្រូវបង់ឲ្យម្ចាស់ប័ណ្ណសន្យារ៉ាប់រងនាពេលអនាគត ត្រូវបានគណនាដោយអនុលោមតាមគោលការណ៍គណនាហានិភ័យទទួលស្គាល់ជាទូទៅ (generally accepted actuarial principles)។

ប្រាក់បម្រុងសម្រាប់បុព្វលាភមិនទាន់ទទួលបាន គឺចំណែកនៃបុព្វលាភធានារ៉ាប់រងត្រូវទទួល ឬ ការទទួលដែលទាក់ទងនឹងហានិភ័យដែលមិនទាន់ដល់កាលកំណត់នាការិយបរិច្ឆេទរបាយការណ៍។ សំវិធានធនត្រូវបានទទួលស្គាល់នៅពេលចុះកិច្ចសន្យា និងបុព្វលាភត្រូវបានទទួល ហើយត្រូវបាន ចាត់ទុកជាចំណូលបុព្វលាភតាមរយៈពេលនៃកិច្ចសន្យា ដោយអនុលោមតាមលំនាំសេវាធានា រ៉ាប់រងដែលចែងក្នុងកិច្ចសន្យា។

### *3.15 បំណុលកិច្ចសន្យាធានារ៉ាប់រង* (តពីទំព័រមុន)

ប្រាក់បម្រុងសម្រាប់សំណង រួមបញ្ចូលសំវិធានធនសម្រាប់សំណងមិនទាន់ទូទាត់ និងសម្រាប់ សំណងដែលបានកើតឡើងប៉ុន្តែមិនទាន់បានរាយការណ៍។ សំវិធានធនសម្រាប់សំណងមិនទាន់ទូទាត់ ត្រូវបានបង្កើតឡើងដោយផ្អែកលើការទូទាត់សំណងដែលបានប៉ាន់ស្មានសម្រាប់សំណង នីមួយៗ ដែលក្រុមហ៊ុនធានារ៉ាប់រងត្រូវទទួលខុសត្រូវ ដែលត្រូវជូនដំណឹងដល់ក្រុមហ៊ុនធានារ៉ាប់រង ឬ ស្នើសុំការទូទាត់ប៉ុន្តែមិនទាន់បានដោះស្រាយនៅចុងឆ្នាំសារពើពន្ធ។

អត្ថប្រយោជន៍នាពេលអនាគតត្រូវបង់ទៅឲ្យម្ចាស់ប័ណ្ណសន្យារ៉ាប់រង និងសំវិធានធនលើការកើតឡើងប៉ុន្តែមិនបានរាយការណ៍ត្រូវបានគណនាដោយប្រើវិធីសាស្ត្រជាក់ស្តែងដែលទទួលយក។

នៅកាលបរិច្ឆេទរបាយការណ៍នីមួយៗក្រុមហ៊ុនធ្វើការតេស្តលើភាពគ្រប់គ្រាន់នៃបំណុល (liability adequacy) ដើម្បីកំណត់ថាតើបំណុលធានារ៉ាប់រងដែលទទួលស្គាល់មានគ្រប់គ្រាន់។ ការគណនា នេះប្រើការប៉ាន់ស្មាននាពេលបច្ចុប្បន្ន នៃលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យានាពេលអនាគត ដែលកើត ឡើងក្រោមកិច្ចសន្យាធានារ៉ាប់រងរួមទាំងការទាមទារសំណងដោះស្រាយថ្លៃដើម។ ប្រសិនបើការប៉ាន់ប្រមាណទាំងនេះ បង្ហាញថាបរិមាណបន្ទុកនៃការធានារ៉ាប់រង គឺមិនគ្រប់គ្រាន់នោះកង្វះនេះត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ ដោយរៀបចំសំវិធានធនសម្រាប់ភាពគ្រប់គ្រាន់នៃបំណុល។

### *3.16 អត្ថប្រយោជន៍និយោជិត*

ថ្លៃឈ្នួល ប្រាក់បៀវត្ស ការឈប់សម្រាកប្រចាំឆ្នាំនិងការឈប់សម្រាកថែទាំសុខភាព ប្រាក់លើកទឹកចិត្ត និងអត្ថប្រយោជន៍អរូបិយដែលទទួលបានការទូទាត់ ត្រូវបានគណនាតាមមូលដ្ឋានបង្គរនៅក្នុងអំឡុងពេលដែលសេវាពាក់ព័ន្ធត្រូវបានបំពេញដោយនិយោជិតនៃក្រុមហ៊ុន។

ក្រុមហ៊ុន បានបង្គរប្រាក់បំណាច់អតីតភាពការងារដែលត្រូវបង់ស្មើនឹង15ថ្ងៃ ក្នុងមួយឆ្នាំនៃប្រាក់ឈ្នួលរបស់និយោជិតដូចខាងក្រោម៖

- ស្មើនឹង 3ថ្ងៃដែលត្រូវបង់រៀងរាល់សងរាល់ខែធ្នូ និង
- ស្មើនឹង 3ថ្ងៃដែលត្រូវបង់រៀងរាល់ខែមិថុនា

## 3. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### *3.16 អត្ថប្រយោជន៍និយោជិត* (តពីទំព័រមុន)

ប្រាក់បំណាច់អតីតភាពការងារមិនត្រូវលើសពី 6ខែនៃប្រាក់ឈ្នួលជាមធ្យមរបស់និយោជិតនៃឆ្នាំបន្តបន្ទាប់រៀងគ្នា។ និយោជិតមិនមានសិទ្ធិទទួលបានការទូទាត់ទេ ប្រសិនបើនិយោជិតលាលែងពីមុខតំណែងមុននឹងទទួលបានការទូទាត់។ ការប៉ាន់ស្មានចំនួនទឹកប្រាក់ នៃការបង់លើប្រាក់អតីតភាពការងារត្រូវបានទទួលស្គាល់នៅក្រោមគណនីត្រូវទូទាត់ផ្សេងៗ។

ក្រុមហ៊ុនបានអនុវត្តតាមគំរូ 5ជំហាន សម្រាប់ការទទួលស្គាល់ចំណូលដែលកើតចេញពីកិច្ចសន្យាជាមួយអតិថិជន។ គំរូ 5ជំហាន មានដូចខាងក្រោម៖

(ក) កំណត់អត្តសញ្ញាណកិច្ចសន្យាជាមួយអតិថិជន

(ខ) កំណត់កាតព្វកិច្ចអនុវត្តដែលមាននៅក្នុងកិច្ចសន្យា

(គ) កំណត់តម្លៃប្រតិបត្តិការ

(ឃ) បែងចែកតម្លៃប្រតិបត្តិការទៅនឹងកាតព្វកិច្ចអនុវត្តនៅក្នុងកិច្ចសន្យា

(ង) ទទួលស្គាល់ប្រាក់ចំណូលនៅពេលក្រុមហ៊ុនបានបំពេញកាតព្វកិច្ចអនុវត្ត

ក្រុមហ៊ុនវាយតម្លៃទៅលើការរៀបចំ ចំណូលរបស់ខ្លួនធៀបនឹងលក្ខណៈវិនិច្ឆ័យជាក់លាក់ដើម្បីកំណត់ថាតើក្រុមហ៊ុនកំពុងដើរតួជាម្ចាស់គ្រប់គ្រង ឬ ជាភ្នាក់ងារ។ ក្រុមហ៊ុនបានសន្និដ្ឋានថា ក្រុមហ៊ុនកំពុងដើរតួជាម្ចាស់គ្រប់គ្រងនៅក្នុងការរៀបចំណូលទាំងអស់។

លក្ខន្តិកៈនៃការទទួលស្គាល់ជាក់លាក់ដូចខាងក្រោម ត្រូវតែបំពេញផងដែរមុនពេលចំណូលត្រូវបានទទួលស្គាល់ក្នុងវិសាលភាព CIFRS 15 មាន៖

### *3.17 ការទទួលស្គាល់ចំណូល*

*(ក) ចំណូលពីកម្រៃជើងសារ*

ចំណូលកម្រៃជើងសារ គឺជាកម្រៃដែលបានទទួល និងកម្រៃដែលត្រូវទទួលបានពីក្រុមហ៊ុន ធានារ៉ាប់រងបន្ត ដោយគណនាទៅតាមមូលដ្ឋាននៃបុព្វលាភដុលផ្ទេរឲ្យក្រុមហ៊ុនធានារ៉ាប់រងបន្ត ហើយទទួលស្គាល់ជាចំណូលតាមរយៈពេលនៃការប្រើប្រាស់សេវាដែលពាក់ព័ន្ធ។ ប្រសិនបើកម្រៃនោះបានពីបុព្វលាភ ដែលប្រើពេលអនាគតនោះកម្រៃដែលទទួលបាន ត្រូវបានពន្យារ និងទទួលស្គាល់ជាចំណូលទៅតាមការិយបរិច្ឆេទអនាគត។ ប្រាក់ចំណូលរបស់កម្រៃជើងសារ មិនត្រូវបានទទួលស្គាល់ក្នុងសន្និសញ្ញាធានារ៉ាប់រងឡើងវិញជាមួយនឹងអត្រាបុព្វលាភសុទ្ធនោះទេ។

## 3. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### *3.17 ការទទួលស្គាល់ចំណូល* (តពីទំព័រមុន)

*(ខ) ចំណូលផ្សេងៗ*

ចំណូលផ្សេងៗ ត្រូវទទួលស្គាល់នៅពេលដែលផលប្រយោជន៍សេដ្ឋកិច្ចបន្ទាប់បន្សំដែល ចូលក្នុងក្រុមហ៊ុនតាមការកើនឡើងនៃទ្រព្យសកម្ម ឬ ការថយចុះនៃបំណុល និងដែលជឿជាក់ថានឹងអាចវាស់វែងបាន។

*ប្រាក់ចំណូលក្រៅវិសាលភាពរបស់ CIFRS 15៖*

*ក) បុព្វលាភធានារ៉ាប់រង (Premium)*

បុព្វលាភដុលលើធានារ៉ាប់រងអាយុជីវិត ត្រូវបានទទួលស្គាល់ជាចំណូលនៅពេលដែលដល់កំណត់ត្រូវទទួលពីម្ចាស់ប័ណ្ណសន្យារ៉ាប់រង។ សម្រាប់បុព្វលាភធានារ៉ាប់រងទោលក្រុមហ៊ុន ចំណូលត្រូវបានទទួលស្គាល់នៅពេលដែលកិច្ចសន្យាធានារ៉ាប់រងមានប្រសិទ្ធភាព។

បុព្វលាភធានារ៉ាប់រងដុល ដែលត្រូវបានផ្ទេរទៅអ្នកធានារ៉ាប់រងបន្ត លើកិច្ចសន្យាធានារ៉ាប់រងអាយុជីវិត ត្រូវបានទទួលស្គាល់ជាចំណាយនៅពេលបុព្វលាភមានកាតព្វកិច្ចត្រូវទូទាត់។

បុព្វលាភមិនទាន់ទទួលស្គាល់ គឺជាសមាមាត្រនៃបុព្វលាភរ៉ាប់រង នាការិយបរិច្ឆេទដែលពាក់ព័ន្ធទៅនឹងរយៈពេលនៃហានិភ័យ បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ នេះគឺជាប់ទាក់ទងនឹងប័ណ្ណសន្យារ៉ាប់រងដែលទុនបម្រុងគណិតវិទ្យាមិនទាន់បានគណនា។ បុព្វលាភមិនទាន់ទទួលស្គាល់ ត្រូវបានគណនាតាមសមមាត្រប្រចាំថ្ងៃ។ ចំពោះចំណែកដែលទាក់ទងនឹងការិយបរិច្ឆេទបន្តបន្ទាប់ ត្រូវបានពន្យារទៅជាសំវិធានធនសម្រាប់បុព្វលាភមិនទាន់ទទួលស្គាល់។

*ខ) ចំណូលការប្រាក់*

ចំណូលការប្រាក់ ត្រូវបានទទួលស្គាល់នៅក្នុង របាយការណ៍លទ្ធផលពេញលេញតាមមូលដ្ឋានបង្គរ។

### *3.18 ការទទួលស្គាល់អត្ថប្រយោជន៍ សំណង និងចំណាយ*

*(ក) ចំណាយកម្រៃជើងសារ*

ចំណាយកម្រៃជើងសាររួមបញ្ចូលកម្រៃដែលត្រូវបង់ឲ្យទៅអន្តរការី ដែលបានណែនាំអតិថិជនឲ្យក្រុមហ៊ុន ត្រូវបានគណនាតាមមូលដ្ឋាននៃចំណូលបុព្វលាភដុលដែលបានកត់ត្រា។ ចំណាយកម្រៃជើងសារ ត្រូវបានរំលស់ទៅតាមរយៈពេល និងចំណូលទាក់ទិន ត្រូវបានទទួលស្គាល់ និងចំណែកសមាមាត្រត្រូវទទួលស្គាល់នាការិយបរិច្ឆេទបន្ទាប់ គឺត្រូវពន្យារ និងទទួលស្គាល់ទៅតាមការិយបរិច្ឆេទអនាគត។

*(ខ) សំណង និងអត្ថប្រយោជន៍*

ផលប្រយោជន៍ដុល និងសំណងសម្រាប់កិច្ចសន្យាធានារ៉ាប់រងអាយុជីវិត រួមបញ្ចូលនូវចំណាយ នៃការទាមទារសំណងទាំងអស់ដែលបានកើតឡើងក្នុងការិយបរិច្ឆេទដោយរួមបញ្ចូលទាំង ចំណាយលើការដោះស្រាយការទាមទារសំណងទាំងផ្នែកក្នុង និងផ្នែកក្រៅ ហើយដែលមានការពាក់ព័ន្ធផ្ទាល់ទៅនឹង ដំណើរការនៃការទាមទារសំណង និងការទូទាត់សំណង។ សំណងករណីមរណភាព និងការលះបង់ត្រូវបាន កត់ត្រាតាមការជូនជាដំណឹង។ ប្រាក់សំណងដល់កាលកំណត់ និងធនលាភសមាជិកត្រូវបានទទួលស្គាល់ នៅពេលដល់កំណត់ដែលត្រូវបង់។

*(គ) បុព្វលាភធានារ៉ាប់រងដែលត្រូវបានផ្ទេរទៅអ្នកធានារ៉ាបរងបន្តខាងក្រៅ*

បុព្វលាភធានារ៉ាប់រងដែលត្រូវបានផ្ទេរទៅអ្នកធានារ៉ាបរងបន្តខាងក្រៅ ត្រូវបានទទួលស្គាល់ស្របតាមកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តបន្ទាប់ពីទទួលបានការបញ្ជាក់ពី ក្រុមហ៊ុនធានារ៉ាប់រងបន្ត ដោយស្របតាមការចុះបញ្ជី គណនេយ្យសម្រាប់ចំណូលបុព្វលាភ។

## 3. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### *3.19 ពន្ធ*

*ពន្ធលើប្រាក់ចំណូល*

ពន្ធលើប្រាក់ចំណូលជាទ្រព្យសកម្ម ឬ បំណុលសម្រាប់ការិយបច្ឆេទបច្ចុប្បន្ន និងមុនៗត្រូវបានវាស់វែងជាទឹកប្រាក់ដែលត្រូវបានរំពឹងទុកថាត្រូវបានប្រមូលមកវិញពី ឬ ត្រូវបង់ឲ្យអាជ្ញាធរពន្ធដារ។ អត្រាពន្ធ និងច្បាប់សារពើពន្ធដែលត្រូវបានប្រើដើម្បីគណនាទឹកប្រាក់ទាំងនេះ គឺជាអត្រា និងច្បាប់សារពើពន្ធ ដែលមានសុពលភាព ឬ អនុម័តឲ្យប្រើប្រាស់រហូតដល់កាលបរិច្ឆេទចេញ របាយការណ៍នេះ។

ពន្ធលើប្រាក់ចំណូលពាក់ព័ន្ធនឹងទ្រព្យ ដែលត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន គឺ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍បម្រែបម្រួលមូលធន ប៉ុន្តែមិនមែននៅក្នុងរបាយការណ៍លទ្ធផលនោះទេ។ គណៈគ្រប់គ្រង នឹងធ្វើការវាយតម្លៃជាទៀងទាត់អំពីជំហរលើការប្រកាសពន្ធដែលទាក់ទងនឹងស្ថានភាពដែលច្បាប់សារពើពន្ធ អាស្រ័យទៅលើការបកស្រាយផ្សេងៗគ្នា និងបង្កើតនូវសំវិធានធនតាមពេលសមស្រប។

*ពន្ធពន្យារ*

ពន្ធពន្យារត្រូវបានគណនា ដោយប្រើវិធីសាស្ត្រតារាងតុល្យការលើចំនួនខុសគ្នាបណ្តោះអាសន្ននាកាលបរិច្ឆេទនៃតារាងតុល្យការរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុលសម្រាប់គោលបំណងនៃរបាយការណ៍ហិរញ្ញវត្ថុ និងចំនួនដែលត្រូវបានប្រើសម្រាប់គោលបំណងពន្ធដារ។ តម្លៃនៃពន្ធពន្យារ ដែលបានគណនានោះ គឺផ្អែកលើការរំពឹងទុក នៃលក្ខណៈក្នុងការទទួលស្គាល់ ឬ ការទូទាត់នៃតម្លៃយោងរបស់ទ្រព្យសកម្ម ឬបំណុល ដោយយកអត្រាពន្ធដែលអនុម័តឲ្យប្រើប្រាស់ក្នុងតារាងតុល្យការ។

ពន្ធពន្យារលើប្រាក់ចំណូលជាបំណុល ត្រូវបានទទួលស្គាល់ សម្រាប់ចំនួនខុសគ្នាបណ្តោះ អាសន្នជាប់ពន្ធទាំងអស់ លើកលែងតែនៅពេលពន្ធពន្យារជាបំណុលកើតឡើងពីការទទួលស្គាល់នៅគ្រាដំបូងនៃទ្រព្យសកម្ម ឬបំណុល នៅក្នុងប្រតិបត្តិការមួយដែល វាមិនជះឥទ្ធិពល ដល់ប្រាក់ចំណេញតាមវិធីសាស្ត្រគណនេយ្យ និងប្រាក់ចំណេញ ឬ ខាត។

ពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់លើការកាត់ចេញនូវភាពខុសគ្នាបណ្តោះអាសន្នទាំងអស់ តម្លៃយោងបន្តនៃឥណទានពន្ធ និងតម្លៃពន្ធខាតមិនទាន់ប្រើប្រាស់ រហូតដល់ទំហំមួយ ដែលទំនងថាប្រាក់ចំណេញជាប់ពន្ធនឹង អាចកាត់កងជាមួយភាពខុសគ្នាបណ្តោះអាសន្ន និងតម្លៃយោងបន្តរនៃឥណទានពន្ធ និងតម្លៃពន្ធខាតដែលមិនទាន់ប្រើប្រាស់នោះ អាចត្រូវបានប្រើប្រាស់ លើកលែងតែនៅពេលពន្ធប្រាក់ចំណេញពន្យារជាទ្រព្យសកម្មទាក់ទងនឹងចំនួនខុសគ្នាបណ្តោះអាសន្នជាប់ពន្ធនោះ កើតឡើងពីការទទួលស្គាល់នាគ្រាដំបូង នៃទ្រព្យសកម្ម ឬបំណុល នៃប្រតិបត្តិការមួយនៅខណៈពេលប្រតិបត្តិការកើតឡើងនោះ មិនមានឥទ្ធិពលដល់ប្រាក់ចំណេញ តាមវិធីសាស្ត្រគណនេយ្យ និងប្រាក់ចំណេញ ឬ ខាតសម្រាប់ពន្ធ។

តម្លៃយោងនៃពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យសកម្ម ត្រូវបានពិនិត្យឡើងវិញរៀងរាល់ ចុងការិយបរិច្ឆេទនៃរបាយការណ៍ ហើយនឹងត្រូវបានកាត់បន្ថយមកត្រឹមទំហំមួយ ដែលមិនទំនងថាមានប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់នឹងអាចផ្តល់ឲ្យទ្រព្យសកម្មទាំងអស់ ឬមួយផ្នែកនៃពន្ធលើប្រាក់ចំណេញពន្យារជាទ្រព្យសកម្មដែលអាចប្រើប្រាស់បាន។ ពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យសកម្ម ដែលមិនត្រូវបានទទួលស្គាល់នោះ គឺត្រូវបានវាយតម្លៃឡើងវិញតាមកាលបរិច្ឆេទចុងក្រោយនៃរបាយការណ៍នីមួយៗ និងត្រូវបានទទួលស្គាល់ត្រឹមតែទំហំមួយដែលវាទំនងថាប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតនឹងធ្វើឲ្យពន្ធពន្យារជាទ្រព្យសកម្មនោះ អាចត្រូវបានយកប្រមូលមកវិញបាន។

ពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យសកម្ម និងបំណុល ត្រូវបានវាយតម្លៃផ្អែកលើអត្រាពន្ធ ដែលរំពឹងថានឹងយកមកប្រើប្រាស់សម្រាប់ឆ្នាំណាដែល ទ្រព្យសកម្មត្រូវបានទទួលស្គាល់ ឬបំណុលត្រូវបានទូទាត់ ដោយពឹងផ្អែកលើអត្រាពន្ធ (និងច្បាប់ពន្ធដារ) ដែលបានអនុម័ត ឬ ត្រូវបានប្រើប្រាស់យ៉ាងជាប់លាប់ក្នុងអំឡុងពេលនៃរបាយការណ៍នេះ។

ពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យសកម្ម និងពន្ធពន្យារលើប្រាក់ចំណូលជាបំណុលត្រូវបានកាត់កង ប្រសិនបើសិទ្ធិនៃច្បាប់ណាមួយចូរជាធរមានកើតឡើងដើម្បីកាត់កងទ្រព្យសកម្មពន្ធបច្ចុប្បន្ន ប្រឈមនឹងបំណុលពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន និងពន្ធពន្យារលើប្រាក់ចំណូលពាក់ពន្ធនឹង សហគ្រាសដែលជាប់ពន្ធដូចគ្នា និងអាជ្ញាធរពន្ធដូចគ្នា។

## 4. ស្តង់ដាថ្មី វិសោធនកម្ម និងការបកស្រាយស្តង់ដា

គោលនយោបាយគណនេយ្យដែលបានយកមកអនុវត្ត គឺស្របគ្នានឹងការិយបរិច្ឆេទមុន លើកលែងតែក្រុមហ៊ុនបានអនុវត្តការប្រើប្រាស់នូវសេចក្តីប្រកាសគណនេយ្យថ្មីៗ ដូចខាងក្រោម គិតចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2025។ ការអនុលោមតាមសេចក្តីប្រកាសទាំងនេះ មិនមានផលប៉ះពាល់ដ៏សំខាន់ទៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬការបង្ហាញរបស់ក្រុមហ៊ុននោះទេ។

- *កង្វះនៃការផ្លាស់ប្តូរ ៖ វិសោធនកម្មចំពោះ IAS 21*

  វិសោធនកម្មចំពោះ IAS 21 ផលប៉ះពាលនៃការផ្លាស់ប្តូរក្នុងអត្រាប្តូរប្រាក់បរទេសបាន បញ្ជាក់ពីរបៀបដែលក្រុមហ៊ុនមួយគួរវាយតម្លៃថាតើរូបិយប័ណ្ណមួយអាចប្តូរបានឬអត់ និងរបៀបដែលកំណត់អត្រាប្តូរប្រាក់ជាក់ស្តែង នៅពេលដែលគ្មានលក្ខខណ្ឌអាចបម្លែងបាន។

  វិសោធនកម្មនេះ ពុំមានផលប៉ះពាល់ទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទេ។

### *ស្តង់ដា និងបំណកស្រាយដែលបានចេញផ្សាយតែមិនទាន់មានប្រសិទ្ធភាព*

ស្តង់ដា និងការបកស្រាយ ដែលត្រូវបានចេញផ្សាយ ប៉ុន្តែមិនទាន់ចូលជាធរមាន រហូតដល់កាលបរិច្ឆេទនៃការចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានបង្ហាញដូចខាងក្រោម។ ក្រុមហ៊ុនមានបំណងអនុវត្តស្តង់ដាទាំងនេះបើអាចអនុវត្តបាន នៅពេលដែលវាចូលជាធរមាន។

*មានប្រសិទ្ធភាព នៅ ឬ ក្រោយ ថ្ងៃទី1 ខែមករា ឆ្នាំ2026*

- ចំណាត់ថ្នាក់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ - វិសោធនកម្មលើ CIFRS 9 និង CIFRS 7
- ការកែលម្អប្រចាំឆ្នាំលើស្តង់ដាគណនេយ្យ CIFRS - ភាគ 11
- កិច្ចសន្យាយោងទៅលើអគ្គិសនីដែលពឹងផ្អែកលើធម្មជាតិ - វិសោធនកម្ម IFRS 9 និង IFRS 7

*មានប្រសិទ្ធភាព នៅ ឬ ក្រោយ ថ្ងៃទី1 ខែមករា ឆ្នាំ2027*

- CIFRS 18៖ ការបង្ហាញ និងលាតត្រដាងក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- CIFRS 19៖ បុត្រសម្ព័ន្ធដែលពុំមានការទទួលខុសត្រូវជាសាធារណៈ ៖ ការលាតត្រដាង
- ការបកប្រែទៅជារូបិយប័ណ្ណបង្ហាញអតិផរណាខ្ពស់ (Hyperinflationary) - វិសោធនកម្ម IAS 21

*មានប្រសិទ្ធភាព នៅ ឬ ក្រោយ ថ្ងៃទី1 ខែមករា ឆ្នាំ2028*

ស្តង់ដាដែលបានចេញផ្សាយ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព ត្រូវបានរំពឹងថានឹងមានផលប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានដូចខាងក្រោម៖

CIFRS 17 *កិច្ចសន្យាធានារ៉ាប់រង*

នៅខែឧសភា ឆ្នាំ2017 ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (ហៅកាត់ថា “IASB”) បានចេញផ្សាយនូវ IFRS 17 *កិច្ចសន្យាធានារ៉ាប់រង* ដែលត្រូវបានបង្ហាញគោលការណ៍សម្រាប់ការទទួលស្គាល់ ការវាស់វែង ការបង្ហាញ និងការលាតត្រដាងនៃកិច្ចសន្យាធានារ៉ាប់រងក្នុងវិសាលភាពនៃ IFRS 17។ IFRS 17 បានចូលជាធរមានសម្រាប់ការិយបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំ នៅ ឬ ក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2023។ ការចូលជាធរមាននៃ IFRSs ដែលចេញដោយ IASB ត្រូវបានអនុម័តក្នុងពេលដំណាលគ្នាក្នុងប្រទេសកម្ពុជា ដែលសមមូលនឹង CIFRSs។ CIFRS 17 អនុវត្តចំពោះកិច្ចសន្យាធានារ៉ាប់រងគ្រប់ប្រភេទ (ឧទាហរណ៍ ជីវិត មិនមែនជីវិត ការធានារ៉ាប់រងដោយផ្ទាល់ និងការធានារ៉ាប់រងបន្ត) ដោយមិនគិតពីប្រភេទនៃអង្គភាព ដែលចេញផ្សាយនូវកិច្ចសន្យាធានារ៉ាប់រង ក៏ដូចជាការធានាជាក់លាក់ និងឧបករណ៍ហិរញ្ញវត្ថុដែលមានលក្ខណៈពិសេសនៃការចូលរួមដោយឆន្ទានុសិទ្ធ។ ការលើកលែងវិសាលភាពមួយចំនួននឹងត្រូវបានអនុវត្ត។ គោលបំណងរួមនៃ CIFRS 17 គឺដើម្បីផ្តល់នូវគំរូគណនេយ្យសម្រាប់កិច្ចសន្យាធានារ៉ាប់រងដែលមានប្រយោជន៍ជាង និងសង្គតភាពសម្រាប់អ្នកធានារ៉ាប់រង។

## 4. ស្តង់ដាថ្មី វិសោធនកម្ម និងការបកស្រាយស្តង់ដា (តពីទំព័រមុន)

*ស្តង់ដា និងបំណកស្រាយដែលបានចេញផ្សាយតែមិនទាន់មានប្រសិទ្ធភាព* (តពីទំព័រមុន)

CIFRS 17 *កិច្ចសន្យាធានារ៉ាប់រង (តពីទំព័រមុន)*

ផ្ទុយពីតម្រូវការក្នុង CIFRS 4 ដែលភាគច្រើនពឹងផ្អែកលើគោលនយោបាយគណនេយ្យក្នុងស្រុកពីមុនៗសម្រាប់គោលបំណងវាស់វែង CIFRS 17 ផ្តល់នូវគំរូពេញលេញសម្រាប់កិច្ចសន្យាធានារ៉ាប់រងដែលគ្របដណ្តប់ទៅលើគ្រប់ទិដ្ឋភាពគណនេយ្យដែលពាក់ព័ន្ធ។ ស្នូលនៃ CIFRS 17 គឺគំរូទូទៅដែលបន្ថែមដោយ៖

- ការសម្របខ្លួនជាក់លាក់មួយសម្រាប់កិច្ចសន្យា ដែលមានលក្ខណៈពិសេសនៃការចូលរួមដោយផ្ទាល់ (វិធីសាស្ត្រថ្លៃអថេរ)។
- វិធីសាស្ត្រសាមញ្ញ (វិធីសាស្ត្របែងចែកបុព្វលាភ) ជាចម្បងសម្រាប់កិច្ចសន្យារយៈពេលខ្លី។

នៅថ្ងៃទី24 ខែមីនា ឆ្នាំ2023 ន.គ.ស បានចេញសេចក្តីជូនដំណឹង ដែលអនុញ្ញាតឲ្យមានការពន្យារពេលក្នុងការអនុវត្តកាតព្វកិច្ចនៃ CIFRS 17 សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងឲ្យចូលជាធរមានសម្រាប់ការិយបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំ នា ឬ ក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2025។ នៅថ្ងៃទី23 ខែធ្នូ ឆ្នាំ2024 ន.គ.ស បានចេញសេចក្តីជូនដំណឹងមួយទៀត ដើម្បីពន្យារពេលការអនុវត្តរហូតដល់ថ្ងៃទី1 ខែមករា ឆ្នាំ2028។ ក្នុងអំឡុងពេលនៃការពន្យារពេលនេះ ក្រុមហ៊ុនធានារ៉ាប់រងត្រូវបន្តអនុវត្ត CIFRS ដែលមានប្រសិទ្ធភាព។

បច្ចុប្បន្នក្រុមហ៊ុនកំពុងវាយតម្លៃពីការអនុវត្ត និងផលប៉ះពាល់នៃការអនុម័តស្តង់ដាទាំងនេះ។

*CIFRS 9 ឧបករណ៍ហិរញ្ញវត្ថុ*

CIFRS 9 បានជំនួស CIAS 39 ឧបករណ៍ហិរញ្ញវត្ថុ៖ ការទទួលស្គាល់ និងការវាស់វែង។ ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុនបានជ្រើសរើសយកវិសោធនកម្មចំពោះ CIFRS 4 ដើម្បីអនុវត្តទៅលើការលើកលែងបណ្តោះអាសន្នពី CIFRS 9 ដោយពន្យារកាលបរិច្ឆេទអនុវត្តដំបូងនៃ CIFRS 9 ដើម្បីសម្របសម្រួលជាមួយនឹងការអនុវត្តដំបូងនៃ CIFRS 17។ ក្រុមហ៊ុនធ្វើសេចក្តីសន្និដ្ឋានថាក្រុមហ៊ុនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការពន្យារការអនុវត្ត CIFRS 9 ដោយសារតែសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន ទាក់ទងលើសលុបជាមួយធានារ៉ាប់រង និងមិនមានបម្រែបម្រួលខ្លាំងទៅលើសកម្មភាពរបស់ក្រុមហ៊ុនឡើយ។

## 5. ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ ការប៉ាន់ស្មាន និងការសន្មត

ការវិនិច្ឆ័យការប៉ាន់ស្មាន និងការសន្មតត្រូវបានវាយតម្លៃជាបន្តបន្ទាប់ហើយផ្អែកលើបទពិសោធន៍ ប្រវត្តិសាស្ត្រ និងកត្តាដទៃទៀតរួមទាំងការរំពឹងទុក នៃព្រឹត្តិការណ៍នាពេលអនាគតដែលត្រូវបានគេជឿជាក់ថាសមហេតុផលក្រោមកាលៈទេសៈ។

ក្រុមហ៊ុនធ្វើការប៉ាន់ស្មាន និងការសន្មតទាក់ទងនឹងអនាគត។ តាមនិយមន័យការប៉ាន់ស្មានគណនេយ្យនឹងកម្រស្មើនឹងលទ្ធផលជាក់ស្តែងដែលទាក់ទង។ ការប៉ាន់ស្មាន និងការសន្មតដែលមានហានិភ័យគួរឲ្យកត់សម្គាល់ ក្នុងការបង្កឲ្យមានការកែ សំរួលសម្ភារៈ ទៅនឹងចំនួនទឹកប្រាក់នៃទ្រព្យសកម្ម និងបំណុលក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់ត្រូវបាន ពិភាក្សាខាងក្រោម។

*រូបិយប័ណ្ណមុខងារ*

CIAS 21 តម្រូវឲ្យមានការគ្រប់គ្រងដើម្បីប្រើការវិនិច្ឆ័យរបស់ខ្លួនដើម្បីកំណត់រូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន ដូចជាវាបង្ហាញយ៉ាងស្មោះត្រង់នូវឥទ្ធិពលសេដ្ឋកិច្ច នៃប្រតិបត្តិការមូលដ្ឋានព្រឹត្តិការណ៍ និងលក្ខខណ្ឌដែលពាក់ព័ន្ធនឹងក្រុមហ៊ុន។

ក្នុងការធ្វើការវិនិច្ឆ័យនេះក្រុមហ៊ុនពិចារណាដូចតទៅ៖

(i) រូបិយប័ណ្ណដែលជះឥទ្ធិពលជាចម្បងលើតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ និងសេវាកម្ម (រូបិយប័ណ្ណនេះជារូបិយប័ណ្ណដែលតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ និងសេវាកម្មរបស់រូបិយប័ណ្ណនោះត្រូវបានបង្ហាញ និងទូទាត់)
(ii) រូបិយប័ណ្ណដែលទទួលបានពីសកម្មភាពហិរញ្ញប្បទាន និង
(iii) រូបិយប័ណ្ណពីការទទួលពីសកម្មភាពប្រតិបត្តិការតែងតែត្រូវបានរក្សាទុក។

## 5. ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ ការប៉ាន់ស្មាន និងការសន្មត (តពីទំព័រមុន)

*រូបិយប័ណ្ណមុខងារ* (តពីទំព័រមុន)

*ការប៉ាន់ស្មានអាយុកាលប្រើប្រាស់នៃទ្រព្យ និងបរិក្ខារ និងទ្រព្យអរូបី*

អាយុកាលប្រើប្រាស់របស់ទ្រព្យ និងបរិក្ខារ និងទ្រព្យអរូបីនីមួយៗរបស់ក្រុមហ៊ុន ត្រូវបានប៉ាន់ស្មានផ្អែកលើរយៈពេលដែលទ្រព្យសកម្មត្រូវបានគេរំពឹងថាអាចប្រើបាន។

ការប៉ាន់ស្មានបែបនេះ ផ្អែកលើការវាយតម្លៃសមូហភាពនៃអាជីវកម្មស្រដៀងគ្នា ការវាយតម្លៃ បច្ចេកទេសផ្ទៃក្នុង និងបទពិសោធន៍ជាមួយនឹងទ្រព្យសកម្មស្រដៀងគ្នា។ អាយុកាលប្រើប្រាស់នៃ ថ្លៃដើមនីមួយៗ ត្រូវបានពិនិត្យឡើងវិញជាប្រចាំ និងធ្វើបច្ចុប្បន្នភាព ប្រសិនបើការរំពឹងទុកខុសគ្នាពីការប៉ាន់ស្មានពីមុនដោយសារតែរូបវន្តផ្ទាល់ ការប្រើប្រាស់ ការខូចខាត ភាពហួសសម័យបច្ចេកទេស ឬពាណិជ្ជកម្ម និងដែនកំណត់ច្បាប់ ឬ ផ្សេងទៀតលើការប្រើប្រាស់ទ្រព្យសកម្ម និងបរិក្ខារ។

វាអាចទៅរួចដែលថាលទ្ធផលហិរញ្ញវត្ថុ នាពេលអនាគតអាចត្រូវបានប៉ះពាល់ដោយការផ្លាស់ប្តូរ បរិមាណ និងពេលវេលានៃការចំណាយដែលបានកត់ត្រាដែលកើតឡើងដោយការផ្លាស់ប្តូរកត្តាដែលបានរៀបរាប់ខាងលើ។ ការកាត់បន្ថយអាយុកាលប្រើប្រាស់ដែលបានប៉ាន់ស្មាននៃវត្ថុណាមួយនៃទ្រព្យសកម្ម និងបរិក្ខារ និងទ្រព្យអរូបីនឹងបង្កើនការកត់ត្រា ការចំណាយរំលស់ និងការថយចុះតម្លៃយោងគណនេយ្យ នៃទ្រព្យសកម្ម និងបរិក្ខារ និងទ្រព្យអរូបី។

*ពន្ធ*

ពន្ធត្រូវបានគណនាផ្អែកលើមូលដ្ឋាននៃការបកស្រាយបច្ចុប្បន្ននៃបទប្បញ្ញត្តិពន្ធ។ ទោះយ៉ាងណាបទប្បញ្ញត្តិទាំងនេះអាចមានការប្រែប្រួលតាមកាលកំណត់ ហើយការកំណត់ចុងក្រោយនៃការចំណាយពន្ធនឹងត្រូវធ្វើឡើងបន្ទាប់ពីមានការត្រួតពិនិត្យពីអាជ្ញាធរពន្ធដារ។

នៅពេលដែលលទ្ធផលចុងក្រោយនៃពន្ធខុសគ្នាពីចំនួនទឹកប្រាក់ដែលត្រូវបានកត់ត្រាដំបូង ភាពខុសគ្នាបែបនេះនឹងជះឥទ្ធិពលដល់ពន្ធលើប្រាក់ចំណូល និងបទប្បញ្ញត្តិស្តីពីពន្ធពន្យារក្នុងអំឡុងពេលដែលការកំណត់ បែបនេះត្រូវបានធ្វើឡើង។

*ការវាយតម្លៃលើបំណុលកិច្ចសន្យាធានារ៉ាប់រង*

ចំពោះកិច្ចសន្យាធានារ៉ាប់រង ការប៉ាន់ស្មានត្រូវតែធ្វើឡើងសម្រាប់ថ្លៃដើមនៃការទាមទារសំណងចុងក្រោយដែលត្រូវបានរាយការណ៍នៅកាលបរិច្ឆេទ នៃការរាយការណ៍ និងសម្រាប់ការទាមទារសំណងចុងក្រោយដែល រំពឹងទុក" កើតឡើងប៉ុន្តែមិនទាន់រាយការណ៍ (IBNR) នៅកាលបរិច្ឆេទនៃការរាយការណ៍។ វាអាចចំណាយពេលជាក់លាក់មួយមុនពេលការទាមទារសំណងចុងក្រោយអាចត្រូវបានបង្កើតឡើងដោយមានភាពប្រាកដប្រជា និងសម្រាប់ប្រភេទនៃគោលការណ៍ខ្លះ ការទាមទាររបស់ IBNR បង្កើតបានជាការទទួលខុសត្រូវភាគច្រើននៅក្នុងតារាងតុល្យការ។

ការចំណាយខ្ពស់បំផុត នៃសំណងកំពុងចរាចរ ត្រូវបានប៉ាន់ប្រមាណផ្អែកលើទិន្នន័យជាក់ស្តែងហើយការសន្មតបច្ចុប្បន្នតំណាងឲ្យការប៉ាន់ស្មានល្អបំផុត នៃការអះអាងនាពេលអនាគត។ ការសន្មតចម្បង គឺថាបទពិសោធន៍អភិវឌ្ឍន៍ការអះអាង ពីអតីតកាលរបស់ក្រុមហ៊ុនអាចត្រូវបានប្រើសម្រាប់ គម្រោងការអះអាងការអភិវឌ្ឍនាពេលអនាគតហើយដូច្នេះចំណាយលើការទាមទារចុងក្រោយ។

មិនមានការសន្និដ្ឋានជាក់លាក់ ណាមួយទាក់ទងនឹងអត្រាអតិផរណា នៃការអះអាងនាពេលអនាគតឡើយ។ ផ្ទុយទៅវិញការសន្មត គឺច្បាស់ក្នុងទិន្នន័យអភិវឌ្ឍន៍ការអះអាងជាប្រវត្តិសាស្ត្រដែលការព្យាករណ៍ផ្អែកលើ។ ការវិនិច្ឆ័យគុណភាពបន្ថែមត្រូវបានប្រើដើម្បីវាយតម្លៃវិសាលភាព ដែលនិន្នាការពីមុនអាចនឹងមិនអនុវត្តនាពេលអនាគត (ឧទាហរណ៍ ដើម្បីឆ្លុះបញ្ចាំងពីការកើតឡើង តែមួយដង ការផ្លាស់ប្តូរកត្តាខាងក្រៅ ឬ ទីផ្សារដូចជាតរិយាបថសាធារណៈចំពោះការទាមទារលក្ខខណ្ឌសេដ្ឋកិច្ចកម្រិត នៃអតិផរណានៃពាក្យបណ្ដឹង ការសម្រេចចិត្ត និងនីតិកម្មតុលាការ ក៏ដូចជាកត្តាផ្ទៃក្នុង ដូចជាការលាយផលប័ត្រគោលនយោបាយ និងនីតិវិធីដោះស្រាយបណ្ដឹងទាមទារសំណង) ដើម្បីឈានដល់ការចំណាយចុងក្រោយដែលប៉ាន់ស្មាន ដែលបង្ហាញពីលទ្ធផលដែលអាចកើតមានពីជួរនៃលទ្ធផលដែលអាចកើតមាន ពិចារណាពីភាពមិនច្បាស់លាស់ទាំងអស់ដែលពាក់ព័ន្ធ។

ការវិនិច្ឆ័យការប៉ាន់ស្មាន និងការសន្មតប្រហាក់ប្រហែលគ្នាត្រូវ បានប្រើក្នុងការវាយតម្លៃភាពគ្រប់គ្រាន់នៃបទប្បញ្ញត្តិសម្រាប់បុព្វលាភរ៉ាប់រង។ ការវិនិច្ឆ័យក៏ត្រូវបានទាមទារផងដែរក្នុង ការកំណត់ថាតើ គំរូនៃសេវាកម្មធានារ៉ាប់រងដែលផ្តល់ដោយកិច្ចសន្យា តម្រូវឲ្យមានការរំលស់ លើការបង់បុព្វលាភរ៉ាប់រងលើមូលដ្ឋានក្រៅពីការបែងចែកពេលវេលា។ ក្រុមហ៊ុនប្រើវិធីធានារ៉ាប់រងសុទ្ធចំនួន 1/365 ព្រោះវាជឿជាក់ថាវិធីសាស្ត្រនេះមានភាពពាក់ព័ន្ធជាងមុនក្នុងការគិតពីប្រាក់ចំណូលបុព្វលាភ ក្នុងរយៈពេល នៃកិច្ចសន្យាស្របតាមគំរូនៃសេវាកម្មធានារ៉ាប់រង ដែលបានផ្តល់ក្រោមកិច្ចសន្យា។

## 5. **ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ ការប៉ាន់ស្មាន និងការសន្មត** (តពីទំព័រមុន)

*ការប៉ាន់ស្មានអត្រាប្រាក់កម្ចីកើនឡើង (ហៅកាត់ថា "IBR") សម្រាប់បំណុលភតិសន្យា*

ក្រុមហ៊ុនមិនអាចកំណត់អត្រាការប្រាក់ឲ្យបានងាយស្រួល នៅក្នុងការជួលនេះបានទេដូច្នេះវាប្រើ IBR របស់ខ្លួនដើម្បីវាស់ស្ទង់បំណុលភតិសន្យា។ IBR សម្រាប់បំណុលភតិសន្យាគឺអត្រាការប្រាក់ដែលក្រុមហ៊ុន នឹងត្រូវបង់ដើម្បីខ្ចីក្នុងរយៈពេលស្រដៀងគ្នានេះ ហើយស្រដៀងគ្នា នឹងមូលបត្រ មូលនិធិដែលចាំបាច់ ដើម្បីទទួលបានទ្រព្យសកម្មដែលមានតម្លៃស្រដៀងគ្នាទៅ នឹងសិទ្ធក្នុងការប្រើប្រាស់ទ្រព្យសកម្ម (ROU) នៅក្នុងស្ថានភាពសេដ្ឋកិច្ចស្រដៀងគ្នានេះ។ ក្រុមហ៊ុនបានប៉ាន់ស្មានថា IBR សម្រាប់បំណុលភតិសន្យារដោយប្រើធាតុចូលដែលអាចសង្កេតបាន (ដោយយោងទៅលើអត្រាគ្មានហានិភ័យ) ដែលបានកែសម្រួល ដើម្បីពិចារណាពីហានិភ័យឥណទានរបស់ក្រុមហ៊ុន (ឧទាហរណ៍ មានការរីករាលដាលនៃឥណទាន)។

*ការវាស់វែងតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ*

នៅពេលវាស់តម្លៃទីផ្សារនៃទ្រព្យសកម្ម ឬបំណុល ក្រុមហ៊ុនប្រើប្រាស់ទិន្នន័យដែលអាចអង្កេតបានតាមទីផ្សារតាមដែលអាចធ្វើទៅបាន។ តម្លៃទីផ្សារ ត្រូវបានចាត់ថ្នាក់ទៅតាមកម្រិតផ្សេងៗគ្នាក្នុងឋានានុក្រមតម្លៃសមរម្យ ដោយផ្អែកលើធាតុចូលដែលបានប្រើក្នុងបច្ចេកទេសវាយតម្លៃខាងក្រោម៖

| | |
|---|---|
| កម្រិតទី 1៖ | តម្លៃដែលបានដកស្រង់ (មិនបានកែតម្រូវ) នៅក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬបំណុលដូចគ្នា។ |
| កម្រិតទី 2៖ | ធាតុចូលក្រៅពីតម្លៃ ដែលបានដកស្រង់ដែលបានរួមបញ្ចូលក្នុងកម្រិតទី1 ដែលអាចសង្កេតបានលើទ្រព្យសកម្ម ឬបំណុលដោយផ្ទាល់ (ឧ. ជាតម្លៃ) ឬដោយប្រយោល (ឧ. បានមកពីតម្លៃ)។ |
| កម្រិតទី 3៖ | ធាតុចូលនៃទ្រព្យសកម្ម ឬបំណុលដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចសង្កេតបាន (ធាតុដែលមិនអាចសង្កេតបាន)។ |

នៅពេលដែលតម្លៃទីផ្សារ នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលបានកត់ត្រាក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ មិនអាចវាស់វែងបានដោយផ្អែកលើតម្លៃដែលបានដកស្រង់នៅក្នុងទីផ្សារសកម្ម តម្លៃសមស្របរបស់ពួកគេត្រូវបានវាស់វែង ដោយប្រើបច្ចេកទេសវាយតម្លៃរួមទាំងលំហូរសាច់ប្រាក់អប្បហារ ("DCF")។ ធាតុចូលសម្រាប់ម៉ូឌែលទាំងនេះគឺត្រូវបានយកចេញពីទីផ្សារដែលអាច សង្កេតបាន (ប្រសិនបើអាចធ្វើទៅបាន) ប៉ុន្តែនៅពេលដែលវាមិនអាចទៅរួច កម្រិតនៃការវិនិច្ឆ័យគឺត្រូវបានតម្រូវឲ្យបង្កើតតម្លៃសមស្រប។ ការវិនិច្ឆ័យរួមមានការពិចារណាលើធាតុចូលដូចជា ហានិភ័យសន្ទនីយភាពសាច់ប្រាក់ ហានិភ័យឥណទាន និងម៉ូឌែលធាតុចូល ដូចជាការប្រែប្រួលសម្រាប់និស្សន្ទវត្ថុដែលមានកាលបរិច្ឆេទយូរជាង និងអត្រាអប្បហារ អត្រាការបង់ប្រាក់មុន និងការសន្មតអត្រាលំនាំដើមសម្រាប់មូលបត្រដែលផ្អែកលើទ្រព្យសកម្ម។

សម្រាប់ការវិភាគលំហូរសាច់ប្រាក់អប្បហារ ការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគត និងអត្រាអប្បហារ គឺផ្អែកលើព័ត៌មានទីផ្សារបច្ចុប្បន្ន និងអត្រាអនុវត្តចំពោះឧបករណ៍ហិរញ្ញវត្ថុដែលគុណភាពឥណទាន និងលក្ខណៈដែលដល់កាលកំណត់ស្រដៀងគ្នា។ ការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគតត្រូវបានជះឥទ្ធិពលដោយកត្តាដូចជា លក្ខខណ្ឌសេដ្ឋកិច្ច (រួមទាំងហានិភ័យជាក់លាក់របស់ប្រទេស) ការប្រមូលផ្តុំនៅក្នុងឧស្សាហកម្មជាក់លាក់ ប្រភេទឧបករណ៍ ឬរូបិយប័ណ្ណ សាច់ប្រាក់ងាយស្រួលទីផ្សារ និងលក្ខខណ្ឌហិរញ្ញវត្ថុរបស់ដៃគូ។ អត្រាអប្បហារត្រូវបានជះឥទ្ធិពលដោយមិនមានហានិភ័យអត្រាការប្រាក់ និងហានិភ័យឥណទាន។ បម្រែបម្រួលនៃការសន្មតទាក់ទងនឹងកត្តាទាំងនេះ អាចប៉ះពាល់ដល់តម្លៃទីផ្សារ ដែលបានរាយការណ៍នៅក្នុងឧបករណ៍ហិរញ្ញវត្ថុ។

## 6. អចលនទ្រព្យ និងបរិក្ខារ

| | *ការកែលំអរអគារជួល* | *បរិក្ខារការិយាល័យ* | *គ្រឿងសង្ហារឹម និងគ្រឿងបំពាក់* | *យានយន្ត* | *សរុប* |
|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| **ថ្លៃដើម** | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2025 | 207,774 | 294,682 | 184,878 | 89,749 | 777,083 |
| ការបន្ថែម | 8,402 | 910 | 1,408 | - | 10,720 |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025** | **216,176** | **295,592** | **186,286** | **89,749** | **787,803** |
| **ដកៈ រំលស់បង្គរ** | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2025 | 146,485 | 239,451 | 109,012 | 85,332 | 580,280 |
| រំលស់ | 33,422 | 25,671 | 32,260 | 4,417 | 95,770 |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025** | **179,907** | **265,122** | **141,272** | **89,749** | **676,050** |
| **តម្លៃយោងសុទ្ធ** | | | | | |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025** | **36,269** | **30,470** | **45,014** | **-** | **111,753** |
